# តម្លៃជីវិត

**From the English “ Why Pro-Life?”**
**By Randy Alcorn**

*រែនឌី អាល់ខន*

WHY PROLIFE?
English version published by Eternal Perspective Ministries Publishers, Inc.
© 2004 by Eternal Perspective Ministries

ភាសាខ្មែរ © រក្សាសិទ្ធិដោយ*ព្រះបន្ទូលនៃជីវិត និងវិទ្យាស្ថានអន់ទីយ៉ូក*, ឆ្នាំ ២០១០

A Training Book of
***Words of Life Ministries and***
***Antioch Institute***

យើងខ្ញុំស្វាគមមតិរិះគន់ស្ថាបនា និងយោបល់ផ្សេងៗពីលោកអ្នក។ ប្រសិនបើលោកអ្នក
ឃើញមានកំហុសណាមួយក្នុងសៀវភៅ សូមទំនាក់ទំនងយើងខ្ញុំតាមរយៈប្រអប់សំបុត្រ
២៥៨១ ភ្នំពេញ ៣ ឬតាមអ៊ីមេលៈ info@asiaforjesus.com សូមអរគុណ!

ជូនចំពោះ អរឌ្រី ស្តោត ( Audrey Stout )
ដែលថែទាំទារកមិនទាន់កើត
និងម្តាយរបស់ពួកគេ
និងបានថែទាំម្តាយរបស់ខ្ញុំ
ពេលគាត់កំពុងរងទុក្ខដោយសារជំងឺមហារីកនៅក្នុងឆ្នាំ ១៩៨១។
អំពើសប្បុរសរបស់អ្នក
នឹងមិនត្រូវបានបំភ្លេច
ដោយព្រះជាម្ចាស់ដែលប្រទានរង្វាន់ដល់
គ្រប់ទឹកត្រជាក់មួយពែងដែលឱ្យក្នុងព្រះនាមរបស់ព្រះអង្គនោះឡើយ។

## សូមអរគុណ...

...ចំពោះអ្នកជួយកែសម្រួល និងជាមិត្តភក្តិដ៏មានតម្លៃរបស់ខ្ញុំ គឺ រ៉ដ មរីស (Rod Morris) សម្រាប់ការងារកែលំអដ៏ប្រណិតរបស់គាត់។ ខេធី រេមី (Cathy Ramey) ដែលបានបំពេញការងារយ៉ាងល្អ ក្នុងការកាត់បន្ថយសំណៅដើមរបស់ខ្ញុំ និង បននី ហ៊ីស្តែន (Bonnie Hiestand) ដែលបានវាយបញ្ចូលការផ្លាស់ប្តូរពាក្យចុងក្រោយ ដែលខ្ញុំបានកែនៅលើសៀវភៅរបស់ខ្ញុំ។ សូមអរគុណដល់ ប្រាយអិន ស្មីត (Brian Smith), ប្រ៊ែន រូនី (Brent Rooney), គ្រីស្ទីណា ខោលធើរ (Kristina Coulter), ឃីមបើលី ប្រក់ (Kimberly Brock) និង ប្រាយអិន ថមមើស សិន (Brian Thomasson) សម្រាប់ជំនួយរបស់ពួកគេក្នុងគម្រោងនេះ និងសូមអរគុណដល់ ឌើ ហ្គា បើត (Doug Gabbert) សម្រាប់ការលើកទឹកចិត្តរបស់គាត់។ សូមអរគុណដល់ភរិយារបស់ខ្ញុំ នែនស៊ី (Nancy), រ៉ន (Ron) និងខេធី ណរឃ្វីស (Cathy Norquist), ជែណេត អាល់ បើរ (Janet Albers), លីនដា ចេហ្វរី (Linda Jefferies) និង ស៊ែរិន មីសិន ហ៊ីមើរ (Sharon Misenhimer)។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកទាំងអស់គ្នា សម្រាប់ភាពជាដៃគូដ៏មានតម្លៃរបស់អ្នកទាំងអស់គ្នា។ សូមអរគុណច្រើនផងដែរដល់ ហ្គេល អាត់ប៊ែរី (Gayle Atteberry), ល៉ែរី ហ្គាត់ បើរ (Larry Gadbaugh) និងអាលីស ហ្គ្រេ (Alice Gray), ដែលផ្តល់យោបល់ដ៏មានប្រយោជន៍ជាច្រើន សម្រាប់ច្បាប់ព្រៀងដំបូង។

«ការ បង្ហាញ ដ៏សង្ខេប ប៉ុន្តែ ទូលំទូលាយ របស់ រ៉េនឌី អាល់ ខន (Randy Alcorn) អំពីជំហរនៃការគាំទ្រជីវិត គឺជាធនធានដ៏មានតម្លៃមហិមាសម្រាប់អស់អ្នកប្រឆាំងនឹងការគាំទ្រការជ្រើសរើស នៅគ្រប់ទីកន្លែង ដែលមានចិត្តបើកចំហ ប៉ុន្តែជាញឹកញាប់ និយាយមិនចេញអំពីជំហររបស់ខ្លួន»។

—Frederica Matthewes Green អ្នក សរសេរ សារ ព័ត៌មាន អ្នក ធ្វើ សេចក្តីអត្ថាធិប្បាយ និងជាអ្នកនិពន្ធសៀវភៅ *ការជ្រើសរើសពិតប្រាកដ: ស្តាប់ស្ត្រី ស្វែងរកជម្រើស សម្រាប់ ការ រំលូតកូន* (*Real Choices: Listening to Women, Looking for Alternatives to Abortion*)។

«សៀវភៅដ៏គួរឱ្យយកចិត្តទុកដាក់នេះ កម្ចាត់ចោលនូវគំនិតរាក់កំផែលទាំងឡាយ ហើយវានឹងជួយព្យាបាលរបួសនៃទំនាស់ផ្ទៃក្នុងដ៏បន្ទាន់បំផុតរបស់សហរដ្ឋអាមេរិច»។

—លោកគ្រូ Daniel Lapin ប្រធាន *ឆ្ពោះ ទៅ រក ប្រពៃណី* (*Toward Tradition*) ជាសម្ព័ន្ធជាតិនៃយូដា និងគ្រិស្តបរិស័ទ។ អ្នកនិពន្ធ និងពិធីករកម្មវិធីវិទ្យុ។

«ករណីដ៏គួរឱ្យយកចិត្តទុកដាក់មួយ សម្រាប់បញ្ហាដ៏សំខាន់ជាងគេបំផុតមួយនៃជំនាន់របស់យើង។ ខ្ញុំមិនអាចដាក់សៀវភៅនេះចុះបានទេ»

—Andy Stanley ក្រុមជំនុំ សហគម ណស ភាញ់ (*North Point Community Church*)

«នេះគឺជាតឹកតាងទាំងអស់ដែលមនុស្សគ្រប់គ្នាត្រូវការ។ តឹកតាងនេះត្រូវបានបង្រួមមកនៅក្នុងសៀវភៅដ៏តូចនេះ ហើយវាជាចម្លើយដ៏គួរឱ្យយកចិត្តទុកដាក់ចំពោះមតិឥវ៉ាជាទូទៅរបស់អ្នកដែលគាំទ្រការជ្រើសរើសរ៉េនឌី អាល់ខន ផ្តល់ការរំឮកដ៏មានអំណាចមួយ គឺមនុស្សដែលព្រះជាម្ចាស់បង្កើតមកសក្តិសមនឹងទទួលសេចក្តីថ្លៃថ្នូរ សេរីភាព និងសិទ្ធិស្មើគ្នា។ ខ្ញុំជឿថា សៀវភៅនេះមានសមត្ថភាពក្នុងការបើកភ្នែកនឹងបំផ្លាស់បំប្រែចិត្តរបស់មនុស្សរាប់លាននាក់។ នេះគឺជាសៀវភៅដ៏មានអំណាចមួយដែលលោកអ្នកនឹងចង់ឱ្យដល់មនុស្សគ្រប់គ្នាដែលលោកអ្នកស្គាល់»។

—Nancy Stafford អ្នកសម្តែង និង អ្នក និពន្ធសៀវភៅ *ភាព អស្ចារ្យ នៃ សេចក្តីស្រឡាញ់ របស់ ព្រះអង្គ* និង *សោភ័ណភាព ដោយ សៀវភៅ* (*The Wonder of His Love* and *The Beauty by the Book*)។

«ដើម្បីបំផ្លាស់បំប្រែវប្បធម៌របស់យើង វាមិនគ្រប់គ្រាន់ទេដែលនិយាយថា យើងជាអ្នកប្រឆាំងនឹងការរំលូតកូននោះ យើងត្រូវតែពន្យល់ថា ហេតុអ្វីបានជាយើងគាំទ្រជីវិត។ សៀវភៅនេះគឺជាធនធានដ៏ល្អឥតខ្ចោះមួយ ដែលធ្វើការនោះ»។

—Fr. Frank Pavone នាយក ជាតិ នៃ សង្ឃ សម្រាប់ ជីវិត (*Priests for Life*) ប្រធាន ក្រុមប្រឹក្សាជាតិ ខាង សាសនា ប្រឆាំង នឹង ការរំលូត កូន (*National Pro-Life Religious Council*) ។

«ជា ការវិភាគ ដ៏ ម៉ត់ ចត់ និង លំអិត នៃ មូលហេតុ ដែល ការពារជីវិត របស់មនុស្សទាំងអស់ មិនមែនគ្រាន់តែជាជំហរត្រឹមត្រូវប៉ុណ្ណោះទេ ប៉ុន្តែវាជាជំហរតែមួយគត់ ដែលយើងក្នុងនាមជាសង្គមមួយ ត្រូវគាំទ្រ។ ខ្ញុំជឿថា គំនិតនឹងត្រូវបានបំផ្លាស់បំប្រែ បន្ទាប់ពីបានអានសៀវភៅនេះ»។

—Kristen Day អគ្គនាយក អ្នក ប្រជាធិបតេយ្យ សម្រាប់ ជីវិត នៃ សហរដ្ឋអាមេរិច (*Democrats for Life of America*)

«ហេតុអ្វីគាំទ្រជីវិត គឺជាធនធានដ៏មានតម្លៃមួយ សម្រាប់អ្នកដែលព្យាយាមជួយមិត្តភក្តិ ឬសមាជិកគ្រួសារ ឱ្យយល់អំពីទស្សនៈប្រឆាំងនឹងការរំលូតកូន។ ដោយប្រើភាសាច្បាស់ និងគួរឱ្យ យកចិត្តទុក ដាក់ វេនឌី អាល់ខន លាតត្រដាងករណីសម្រាប់ជីវិត ដោយប្រើអំណាចនៃហេតុផល និងអារម្មណ៍»។

—Charles W. Colson ប្រិយ សម្ព័ន្ធ ពន្ធនាគារ , វ៉ាស៊ីងតុន ឌី ស៊ី (*Prison Fellowship, Washington DC*) ។

«នេះ ជា សៀវភៅ មួយ ដ៏ គួរ ឱ្យយកចិត្តទុកដាក់ មាន កំណត់ត្រា ច្បាស់លាស់ និងមានអត្ថន័យទូលំទូលាយ ជាពិសេស ព្រោះវា ទាក់ទង នឹង ទារក ងាយ រងគ្រោះរបស់យើង»។

—Jennifer O'Neill អ្នកសម្តែង អ្នក និពន្ធ និង អ្នក នាំពាក្យ សម្រាប់ យុទ្ធនាការ ការ យល់ ដឹង អំពី ការ ឈប់ ស្ងៀម ស្ងាត់ តទៅ ទៀត (*Silent No More Awareness Campaign*) ។

# អារម្ភកថា

ជូនចំពោះបងប្អូនប្រជាជនកម្ពុជា!

ខ្ញុំមានកិត្តិយសដែលសៀវភៅរបស់ខ្ញុំដែលមានចំណងជើងថា *ហេតុអ្វីគាំទ្រជីវិត?* ត្រូវបានបោះពុម្ពផ្សាយនៅក្នុងប្រទេសរបស់លោកអ្នក។ ខ្ញុំជឿជាក់ថា យើងមិនត្រូវការជ្រើសរើសរវាងសុខុមាលភាពរបស់ស្ត្រី និងទារកមិនទាន់កើតឡើយ។ លើសពីនេះ យើងត្រូវធ្វើអ្វីដែលល្អបំផុតសម្រាប់ស្ត្រី និងទារកមិនទាន់កើត គឺអនុញ្ញាតឱ្យទារកមានជីវិត ហើយជួយម្តាយរបស់ពួកគាមវិធីដែលយើងអាចជួយបាន។

ខ្ញុំចងចាំច្បាស់នូវដំណើរទស្សនកិច្ចរបស់ខ្ញុំទៅប្រទេសកម្ពុជាកាលពីដប់ឆ្នាំមុន ដែលមានការប៉ះពាល់ចិត្តខ្ញុំយ៉ាងខ្លាំង។ ខ្ញុំបានជួបនឹងមនុស្សល្អៗជាច្រើននៅទីនោះ។ បុរសម្នាក់ និងស្ត្រីម្នាក់ដែលបានរួចជីវិតពីវាលពិឃាតបានប្រាប់ខ្ញុំអំពីរឿងរ៉ាវរបស់ពួកគេទាំងទឹកភ្នែក។ ប្រទេសដ៏ល្អស្អាតរបស់លោកអ្នកបានរៀនច្រើន តាមរយៈទុក្ខវេទនាដ៏អាក្រក់ដែលលោកអ្នកបានទ្រាំទ្រ។ ខ្ញុំសង្ឃឹម និងអធិស្ឋានសូមឱ្យសៀវភៅនេះជួយប្រយុទ្ធនឹងវប្បធម៌នៃសេចក្តីស្លាប់ ដែលតំណាងដោយការរំលូតកូន ហើយនឹងរំដោះប្រជាជាតិរបស់លោកអ្នកឱ្យរួចផុតពីទុក្ខវេទនាដ៏អាក្រក់នោះ។ សូមព្រះជាម្ចាស់ប្រទានពរដល់ ទារក និងកុមារដ៏មានតម្លៃរបស់ប្រទេសកម្ពុជា រួមទាំងទារកដែលមិនទាន់កើតផងដែរ។

មិត្តរបស់លោកអ្នក

រ៉ែនឌី អាល់ខន

# មាតិកា

## Table of Contents


| | | |
|---|---|---|
| ផ្នែកទី១: មូលដ្ឋានគ្រឹះ | | ១៣ |
| **Section 1: The Basics** | | |
| ជំពូកទី ១ | ហេតុអ្វីនិយាយអំពីការរំលូតកូន<br>**Why Talk About Abortion** | ១៥ |
| ជំពូកទី ២ | គាំទ្រស្ត្រី ឬគាំទ្រទារក<br>**Pro-Woman or Pro-Child** | ២១ |
| ផ្នែកទី២: | ទារក | ២៧ |
| **Section 2:** | **The Child** | |
| ជំពូកទី ៣ | តើទារកមិនទាន់កើតពិតជាមនុស្សឬ?<br>**Is the Unborn Really a Human Being?** | ២៩ |
| ជំពូកទី ៤ | តើអ្វីជាភាពខុសគ្នារវាងស៊ុត ស្ពែម (មេជីវិត) អំប្រីយ៉ុង (ទារកដែលទើបនឹងចាប់កំណើតដំបូង) និង គភ៌ (ទារកមិនទាន់កើតដែលមានរូបរាងពេញលក្ខណៈ)?<br>**What's the Difference Between Egg, Sperm, Embryo, and Fetus?** | ៣៥ |
| ជំពូកទី ៥ | តើទារកមិនទាន់កើតជាផ្នែកមួយនៃរូបកាយរបស់ស្ត្រីឬ?<br>**Is the Unborn Part of the Woman's Body?** | ៤១ |
| ជំពូកទី ៦ | តើរូបភាពទាំងមូលប្រាប់យើងពីអ្វី?<br>**What Do the Pictures Tell Us?** | ៤៧ |
| ជំពូកទី ៧ | តើអ្វីដែលធ្វើឱ្យជីវិតរបស់មនុស្សម្នាក់មានតម្លៃ?<br>**What Makes a Human Life "Meaningful"?** | ៥៣ |

ផ្នែកទី៣: ស្ត្រី ៥៩
Section 3: The Woman

ជំពូកទី ៨ តើការរំលូតកូនជាបញ្ហាសិទ្ធិរបស់ស្ត្រីឬ? ៦១
Is Abortion Really a Women's Rights Issue?

ជំពូកទី ៩ តើយើងមានសិទ្ធិដើម្បីជ្រើសរើសនូវអ្វីដែលយើងត្រូវធ្វើចំពោះរូបកាយរបស់យើងឬ? ៦៥
Do We Have the Right to Choose What We Do with Our Bodies?

ជំពូកទី ១០ តើការរំលូតកូនជាផ្នែកមួយនៃសិទ្ធិជាឯកជនឬ? ៦៩
Is Abortion Part of a Right to Privacy?

ជំពូកទី ១១ តើការរំលូតកូនមានគ្រោះថ្នាក់ដល់សុខភាពរាងកាយនិងសុខភាពខួរក្បាលរបស់ស្ត្រីឬ? ៧៣
Does Abortion Harm a Woman's Physical and Mental Health?

ជំពូកទី ១២ តើការរំលូតកូនជាការត្រឹមត្រូវឬ នៅពេលដែលការមានគភ៌ គឺជាគ្រោះថ្នាក់ចំពោះជីវិតរបស់ម្តាយនោះ? ៧៩
Is Abortion Right When Pregnancy Presents Risks to the Mother's Life?

ជំពូកទី ១៣ តើការរំលូតកូនជាការត្រឹមត្រូវឬ នៅពេលដែលការមានគភ៌ គឺជាលទ្ធផលដែលកើតមកពីការរំលោភ និងការរួមភេទជាមួយសាច់ញាតិជិតស្និទ្ធដែលច្បាប់ហាមនោះ? ៨១
Is Abortion Right When Pregnancy Is Due to Rape or Incest?

ផ្នែកទី៤: បញ្ហាសំខាន់ផ្សេងទៀត ៨៧
**Section 4: Other Important Issues**

ជំពូកទី ១៤ ចុះចំណែកឯមនុស្សពិការ និងកូនដែលគេមិនចង់បាន? ៨៩
**What About Disabled and Unwanted Children?**
ជំពូកទី ១៥ តើការរំលូតកូនទប់ស្កាត់ការរំលោភបំពានលើកុមារដែរឬទេ? ៩៥
**Does Abortion Prevent Child Abuse?**
ជំពូកទី ១៦ ខ្លួនផ្ទាល់ប្រឆាំងនឹងការរំលូតកូន ប៉ុន្តែគាំទ្រការជ្រើសរើសឬ? ៩៩
**Personally Opposed to Abortion, but Pro-Choice?**
ជំពូកទី ១៧ ចុះចំណែកឯការឱ្យកូនទៅគេចិញ្ចឹមវិញ? ១០១
**What About Adoption?**

ផ្នែកទី៥: ទស្សនៈខាងវិញ្ញាណ និងឱកាស ១០៧
**Section 5: Spiritual Perspectives and Opportunities**

ជំពូកទី ១៨ តើព្រះជាម្ចាស់អាចអត់ទោសឱ្យការរំលូតកូនដែរឬទេ? ១០៩
**Can God Forgive Abortions?**
ជំពូកទី ១៩ បញ្ហាគាំទ្រជីវិតៈ កិច្ចការដែលនាំឱ្យបែកចេញពីមហាបេសកកម្ម ឬជាមួយផ្នែករបស់មហាបេសកកម្ម? ១១៥
**Pro-Life Issues: Distraction from the Great Commission or Part of It?**
ជំពូកទី ២០ តើខ្ញុំអាចជួយទារកមិនទាន់កើត និងម្ដាយរបស់គេបានយ៉ាងដូចម្ដេច? ១២១
**How Can I Help Unborn Babies and Their Mothers?**

កំណត់សំគាល់ ១២៩
**Notes**

ផ្នែកទី១

# មូលដ្ឋានគ្រឹះ

# ជំពូកទី ១

## ហេតុអ្វីនិយាយអំពីការរំលូតកូន?

អ្នកតំណាងម្នាក់របស់សម្ព័ន្ធសកម្មភាពសិទ្ធិនៃការរំលូតកូនជាតិ (NARAL) បាននិយាយ នៅក្នុងថ្នាក់នៃវិទ្យាល័យមួយអំពីកុសលនៃការរំលូតកូន។ សិស្សម្នាក់បានសំណូមពរដល់គ្រូ ប្រសិនបើខ្ញុំអាចមកបង្ហាញអំពីគោលជំហរនៃការគាំទ្រជីវិត។ នៅពេលដែលខ្ញុំបានមកដល់ នៅមួយសប្តាហ៍ក្រោយមក គ្រូបង្រៀនដែលគាំទ្រការជ្រើសរើស បានជូនដំណឹងដល់ខ្ញុំថា សិស្សរបស់គាត់បានបោះឆ្នោត ២៣-១ សម្រាប់ជំហរគាំទ្រការជ្រើសរើស។

ខ្ញុំបានបង្ហាញករណីសម្រាប់មនុស្សជាតិ និងសិទ្ធិរបស់ទារកដែលមិនទាន់កើត។ ខ្ញុំបានបង្ហាញរូបថតទារកដែលនៅក្នុងស្បូន ដើម្បីចង្អុលបង្ហាញអំពីការវិវឌ្ឍន៍នៃទារកដែលមិនទាន់កើត នៅដំណាក់ដំបូងបំផុតដែលការរំលូតត្រូវបានធ្វើឡើង។

បន្ទាប់ពីថ្នាក់នោះចប់ គ្រូបង្រៀនរូបនោះបាននិយាយមកកាន់ខ្ញុំថា «ប្រសិនបើ យើងបោះឆ្នោតម្តងទៀត យើងនឹងបានលទ្ធផលខុសពីមុន។ គំនិតត្រូវបានផ្លាស់ប្តូរហើយ»។ បន្ទាប់មកគាត់បន្ថែមអ្វីមួយដែលគួរឱ្យចាប់អារម្មណ៍ជាទីបំផុតៈ «តើលោកដឹងទេ រហូតមកដល់ថ្ងៃនេះ ខ្ញុំមិនធ្លាប់ដែលបានឮជំហររបស់អ្នកគាំទ្រជីវិតសោះ»។

យើងមានមោទនភាពចំពោះខ្លួនយើង អំពីការដែលយើងមានគំនិតដែលបើកចំហ និងផ្តល់នូវការអប់រំដែលត្រឹមត្រូវ និងមានមូលដ្ឋានលើអំណះអំណាងពិត។ ប៉ុន្តែ នៅត្រង់នេះមានគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គមដែលមានអាយុ ៥៥ ឆ្នាំម្នាក់ដែល *មិនធ្លាប់បានឮជំហររបស់អ្នកគាំទ្រជីវិតសោះ សូម្បីតែមួយដង*។ គាត់បានព្រមទទួលយកដោយឥតរិះគន់នូវជំហរគាំទ្រការជ្រើសរើស ពីអ្នកដទៃ ហើយសិស្សរបស់គាត់ក៏បានធ្វើដូចគ្នា។

### ទំនោរដ៏គួរឱ្យភ្ញាក់ផ្អើល

មុននេះមិនយូរប៉ុន្មាន ជំហរគាំទ្រជីវិតហាក់បីដូចជាស្លាប់ដោយវ័យចាស់ជរា។ យុវជន យុវនារីទាំងឡាយហាក់បីដូចជាកំពុងតែលង់នៅក្នុងជំនឿមួយថាបទដ្ឋានសីលធម៌អាចប្រែប្រួលបានទៅតាមស្ថានភាព និងសង្គមក្រោយទំនើបមួយ ដែលទទួលឥទ្ធិពលពីការអត់ឱន ដែលទីបំផុតពួកគេហាក់បីក្លាយទៅជាអ្នកគាំទ្រការជ្រើសរើសព្រមៗគ្នា។ ប៉ុន្តែការវិវឌ្ឍន៍ដ៏គួរឱ្យភ្ញាក់ផ្អើលថ្មីៗនេះគឺ យុវជន យុវនារីកាន់តែច្រើនឡើងដែលគាំទ្រជីវិត ជាជាងឪពុកម្ដាយរបស់ពួកគេ។

ការស្ទង់មតិថ្មីៗមួយរបស់ ហ្គាលអិប (Gallup) នៅក្នុងចំណោមក្មេងជំទង់បានរកឃើញថា ៧២ ភាគរយជឿថា ការរំលូតកូនគឺជារឿងខុសសីលធម៌។ មានតែ ១៩ ភាគរយប៉ុណ្ណោះដែលជឿថា ការរំលូតកូនគួរជារឿងមួយដែលគួរតែស្របច្បាប់នៅក្នុងគ្រប់កាលៈទេសៈទាំងអស់ បើប្រៀបធៀបទៅនឹង ១៧ ភាគរយនៃមនុស្សពេញវ័យ។ ប្រហែលជា ៣២ ភាគរយនៃក្មេងជំទង់ ប្រៀបធៀបទៅនឹង ១៧ ភាគរយនៃមនុស្សពេញវ័យ គិតថាការរំលូតកូនគួរតែមិនត្រូវបានអនុញ្ញាតទេ[១]។

ការនេះត្រូវបានបញ្ជាក់ដោយការស្ទង់មតិជាតិ ដែលកើតឡើងបន្ទាប់ពីនោះ[២] និងមានតឹកតាងតាមរយៈចំនួនដ៏ធំនៃក្មេងជំទង់ដែលបានចូលរួមនៅក្នុង ក្បួនព្យុះហយាត្រាជាតិមួយ ឈ្មោះថា ក្បួនព្យុះហយាត្រាដើម្បីជីវិត (March for Life)[៣]។ គេហទំព័រនាសម័យបច្ចុប្បន្នដែលឈោងចាប់ដល់យុវជនយុវនារី កំពុងលើកទឹកចិត្តពួកគេឱ្យជ្រើសរើសជីវិត[៤]។ យុវជនយុវនារីជាច្រើនកំពុងតែបដិសេធមិនទទួលការការពាររបស់វប្បធម៌របស់ពួកគេចំពោះការរំលូតកូន។

នៅក្នុងសៀវភៅ *ហេតុអ្វីគាំទ្រជីវិត?* ខ្ញុំនឹងបង្ហាញហេតុផលដែលជាការពិតនិងប្រកបដោយក្ដីអាណិតអាសូរ ដែលពន្យល់ និងបញ្ជាក់តម្លៃរបស់ចលនានេះ ឱ្យចៀសចេញឆ្ងាយពីពួកអ្នកគាំទ្រការជ្រើសរើស ហើយបែរទៅរកទស្សនៈគាំទ្រជីវិតវិញ។

## បញ្ហាដែលត្រូវបានបង្ហាញនៅក្នុងសម័យរបស់យើង

ការរំលូតកូនគឺជាការវះកាត់ដែលត្រូវបានធ្វើឡើងជាញឹកញាប់ជាងគេលើស្ត្រី នៅក្នុងសហរដ្ឋអាមេរិច។ ទារកដែលបានចាប់កំណើតម្នាក់ក្នុងចំណោមទារកបួននាក់ត្រូវបានរំលូតដោយការវះកាត់ ដោយប្រើសារធាតុគីមី ដែលមិនដឹងចំនួនពិតប្រាកដ ប៉ុន្តែជាចំនួនមួយដែលកំពុងតែកើនឡើង[៥]។ ដោយព្រោះ ៥០ ភាគរយនៃការមានគភ៌ សុទ្ធតែឥតបានគ្រោងទុក នោះមានន័យថា ពាក់កណ្ដាលនៃការមានគភ៌ដែលឥតគ្រោងទុកត្រូវបានបញ្ចប់ដោយការរំលូត។ មានការរំលូតកូនដែលត្រូវបាន

រាយការណ៍ ចំនួន ប្រហែល ១.៣៧ លាន ករណី ជា រៀង រាល់ ឆ្នាំ នៅ ក្នុង សហរដ្ឋអាមេរិច[៦]។ នៅក្នុងសហរដ្ឋអាមេរិច ៤៣ ភាគរយនៃស្ត្រីដែលមានអាយុអាចមានគភ៌ ធ្លាប់បាន ឬនឹងរំលូតកូននៅថ្ងៃខាងមុខ[៧]។ ជាក់ស្តែង គ្រប់គ្រួសារ ក្នុងកម្រិតខ្លះត្រូវបានប៉ះពាល់ដោយការរំលូតកូន។

កម្រិតនៅក្នុងបញ្ហានេះមានលក្ខណៈខ្ពស់លើសពីធម្មតា។ ប្រសិនបើជំហរគាំទ្រការជ្រើសរើសជាជំហរត្រឹមត្រូវ នោះសេរីភាពនៅក្នុងការជ្រើសរើសការរំលូតកូនគឺជាសិទ្ធិបវេណីមូលដ្ឋានមួយ។ ប្រសិនជំហរគាំទ្រជីវិតជាជំហរត្រឹមត្រូវ នោះការរំលូតកូនចំនួន ៣៧៥៣ ករណីដែលកើតឡើងជារៀងរាល់ថ្ងៃនៅក្នុងសហរដ្ឋអាមេរិចសុទ្ធតែជាអ្នករងគ្រោះ ដែលមានចំនួនច្រើនជាងជីវិតដែលបានបាត់បង់នៅក្នុងការបំផ្លាញ មជ្ឈមណ្ឌល ពាណិជ្ជកម្ម ពិភពលោក (*World Trade Center*) កាល ពី ថ្ងៃ ទី ១១ ខែកញ្ញា ឆ្នាំ ២០០១ ទៅទៀត។

ការរំលូតកូនគឺជា «គន្លឹះក្តៅ» បំផុតមួយ។ វាគឺជាពាក្យដែលបង្កឱ្យមានអារម្មណ៍ខ្លាំងក្លាឡើង។ នៅក្នុងចំណោមបញ្ហាទាំងឡាយដែលមនុស្សគិតគូរច្រើន ការរំលូតកូនស្ថិតនៅក្នុងលំដាប់ទីមួយ គឺពីលើការប្រឆាំងនឹងជនជាតិអ៊ីស្រាអែល បញ្ហាដែលកើតឡើងពីការសេពសុរាហួសកម្រិត ភាពគ្មានជម្រកស្នាក់នៅ ទោសប្រហារជីវិត រឿងអាសអាភាស និងការដុតទង់ជាតិ[៨]។

ការស្ទង់មតិថ្មីៗមួយរបស់ ហ្គាលអិប (Gallup) ចង្អុលបង្ហាញថា ប្រជាជនអាមេរិច ២៦ ភាគរយនិយាយថា ពួកគេគាំទ្រជាដាច់ខាតចំពោះជំហរគាំទ្រការជ្រើសរើស ក្នុងខណៈពេលដែល ២៩ ភាគរយនិយាយថា ពួកគេគាំទ្រជាដាច់ខាតចំពោះជំហរគាំទ្រជីវិត។ សរុបបញ្ចូលគ្នា នោះមានន័យថា ប្រជាជនអាមេរិច ៥៥ភាគរយមានទស្សនៈយល់ឃើញចំពោះការរំលូតកូន ហើយមានជំនឿគាំទ្រ និងប្រឆាំងស្ទើរតែស្មើគ្នា[៩]។

ដោយព្រោះប្រជាជន ៤៥ ភាគរយទៀតមិនមានជំហរច្បាស់លាស់ ហើយដោយព្រោះមនុស្សជាច្រើនដែលមានជំហរមាំមួននៅពេលមួយបានផ្លាស់ប្តូរជំនឿរបស់ខ្លួន នោះទំនងជាមានប្រជាជនអាមេរិចជាងពាក់កណ្តាលដែលនៅតែអាចទទួលឥទ្ធិពលនៅក្នុងការគិតរបស់គេអំពីការរំលូតកូន។

## ទស្សនៈគ្រិស្តបរិស័ទ

អ្នកអានជាគ្រិស្តបរិស័ទខ្លះអាចគិតថា «សៀវភៅនេះមិនមែនសម្រាប់យើងទេ គឺវាសម្រាប់មនុស្សដែលមិនដែលទៅព្រះវិហារ ដែលមានការរំលូតកូន»។ តាមការពិត ៤៣ ភាគរយនៃស្ត្រីដែលទទួលការរំលូតកូនបានផ្ដល់អត្តសញ្ញាណខ្លួនគេថាជាអ្នកមានជំនឿខាងប្រូតេស្តង់ ហើយ ២៧ ភាគរយផ្ដល់អត្តសញ្ញាណខ្លួនថាជាអ្នកមានជំនឿខាងកាតូលិក។ ដូច្នេះពីរភាគបីនៃការរំលូតកូននៅក្នុងសហរដ្ឋអាមេរិចត្រូវបានទទួលដោយអស់អ្នកដែលមានជំនឿគ្រិស្តបរិស័ទ។ ដប់ប្រាំបីភាគរយនៃការរំលូតកូនទាំងអស់នៅក្នុងសហរដ្ឋអាមេរិច ត្រូវបានធ្វើឡើងលើស្ត្រីដែលផ្ដល់អត្តសញ្ញាណខ្លួនថាជាគ្រិស្តបរិស័ទដំណឹងល្អ ឬគ្រិស្តបរិស័ទដែលបានកើតជាថ្មី[១០]។ នោះស្មើនឹងជិត២៥ ម៉ឺនករណីជារៀងរាល់ឆ្នាំនៅតាមបណ្ដាក្រុមជំនុំដែលជឿលើព្រះគម្ពីរ។

បញ្ហានៃការរំលូតកូន គឺមិនមែនជារឿងមួយដែលក្រុមជំនុំត្រូវការនិយាយទៅកាន់ពិភពលោកនោះទេ។ វាគឺជារឿងមួយដែលក្រុមជំនុំត្រូវការនិយាយទៅកាន់ខ្លួនឯងជាមុនសិន រួចទើបនិយាយទៅកាន់ពិភពលោក។

ទោះបើខ្ញុំជាគ្រិស្តបរិស័ទក៏ដោយ ក៏ខ្ញុំមិនលើកអំណះអំណាងច្រើនចេញពីព្រះគម្ពីរដែរ នៅក្នុងសៀវភៅនេះ (ខ្ញុំបានធ្វើដូច្នោះនៅកន្លែងផ្សេងទៀត[១១])។ ករណីដែលខ្ញុំបង្ហាញជូនលោកអ្នក មានមូលដ្ឋាននៅលើវិទ្យាសាស្ត្រវេជ្ជសាស្ត្រ និងការសិក្សាខាងចិត្តសាស្ត្រដែលអាចទុកចិត្តបាន។ ប្រភពទាំងអស់នេះគួរតែអាចទុកចិត្តបានចំពោះអ្នកដែលមិនជឿលើព្រះជាម្ចាស់ដែលគោរពសេចក្ដីពិត ក៏ដូចជាចំពោះគ្រិស្តបរិស័ទ។ ពិតណាស់ មានអ្នកមិនមែនគ្រិស្តបរិស័ទជាច្រើនដែលប្រឆាំងនឹងការរំលូតកូន។

ខ្ញុំជាអ្នកមានជំនឿមុតមាំទៅលើសិទ្ធិស្ត្រី។ ខ្ញុំមានការគោរពយ៉ាងជ្រាលជ្រៅចំពោះភរិយា និងកូនស្រីរបស់ខ្ញុំ ដែលខ្ញុំបានបង្រៀនឱ្យពួកគេចេះគោរពខ្លួនឯង និងមានចិត្តកត្តញ្ញូចំពោះព្រះជាម្ចាស់ដែលបង្កើតគេមកជាស្ត្រី។ ខ្ញុំមិនចង់និយាយស្រាលចំពោះរបួសផ្លូវចិត្តដែលស្ត្រីត្រូវឆ្លងកាត់ នៅក្នុងការធ្វើការសម្រេចចិត្តផ្សេងៗដែលទាក់ទងនឹងការរំលូតកូននោះឡើយ។ គ្មាននរណាម្នាក់យល់បាននូវការរងទុក្ខដូចជាព្រះយេស៊ូគ្រិស្ត ដែលពេញដោយព្រះគុណ និងសេចក្ដីពិតនោះឡើយ។ ជំពូកនិយាយអំពីការស្វែងរកការលើកលែងទោសពីព្រះជាម្ចាស់ (ជំពូក ១៨) គឺជាជំពូកមួយដែលខ្ញុំត្រូវការខ្លាំងដូចជាអ្នកឯទៀតៗដែរ។

សៀវភៅនេះបង្ហាញនូវអំណះអំណាងពិត និងតក្កភាព បញ្ចូលជាមួយព្រះគុណ និងក្តីអាណិតអាសូរ ដែលអាចជួយយើងឱ្យចាក់ឫសជំនឿរបស់យើងទៅក្នុងការពិត។

## សំណូមពររបស់ខ្ញុំចំពោះមិត្តអ្នកអាន

ប្រសិនបើលោកអ្នកជាអ្នកគាំទ្រការជ្រើសរើស ហើយកំពុងតែអានសៀវភៅមួយដែលមានចំណងជើងថា *ហេតុអ្វី គាំទ្រជីវិត?* នោះគឺជាការល្អសម្រាប់លោកអ្នកហើយ។ ខ្ញុំសង្ឃឹមថា ការនេះបញ្ជាក់ថា លោកអ្នកជាអ្នកមានគំនិតបើកចំហ។ ប្រសិនបើខាងគាំទ្រជីវិត បញ្ជាក់ថា មិនសមហេតុផល ដូចដែលលោកអ្នកត្រូវបាននាំឱ្យជឿ នោះមិនមានបញ្ហាទេ។ លោកអ្នកអាចបដិសេធសៀវភៅនេះតែម្តងតាមដែលវាសក្តិសម។ ប៉ុន្តែបើវាបញ្ជាក់សមហេតុផល នោះខ្ញុំលើកទឹកចិត្តលោកអ្នកឱ្យពិចារណាឡើងវិញអំពីជំហររបស់លោកអ្នក។

ប្រសិនបើលោកអ្នកជាមនុស្សម្នាក់នៅក្នុងចំណោមមនុស្សជាច្រើន ដែលកំពុងនៅកណ្តាលរវាងជំហរទាំងពីរ ដែលកំពុងតែមានអារម្មណ៍ចម្រុះ នោះខ្ញុំសុំឱ្យលោកអ្នកធ្វើឱ្យសៀវភៅនេះជាផ្នែកមួយនៃការស្វែងរកសេចក្តីពិត។ លោកអ្នកអាចស្តាប់ជំហរគាំទ្រការជ្រើសរើសនៅគ្រប់ទីកន្លែង គឺគ្រាន់តែបើកទូរទស្សន៍ ឬអានសារព័ត៌មានប៉ុណ្ណោះ។ ប៉ុន្តែនេះអាចជាឱកាសតែមួយគត់របស់លោកអ្នកក្នុងការពិនិត្យមើលជំហរគាំទ្រជីវិត។

ប្រសិនបើលោកអ្នកជាអ្នកគាំទ្រជីវិត ខ្ញុំសុំឱ្យលោកអ្នកពិចារណាអំពីជំហររបស់លោកអ្នក។ វាមិនល្អគ្រប់គ្រាន់ទេ ដែលនិយាយថា «ខ្ញុំដឹងថា ខ្ញុំមានជំហរត្រឹមត្រូវ ប៉ុន្តែខ្ញុំមិនដឹងច្បាស់សោះថា ហេតុអ្វី»។ យើងគួរតែផ្អែកជំនឿរបស់យើងនៅលើភស្តុតាង។ ប្រសិនបើយើងយល់ខុសនៅត្រង់ចំណុចណាមួយ ចូរយើងពិចារណាឡើងវិញអំពីជំហររបស់យើង។ ប្រសិនបើយើងមានជំហរត្រឹមត្រូវ យើងត្រូវការរៀនអំពីរបៀបជូនដំណឹងដល់អ្នកដទៃដោយប្រណីសន្តោស និងដោយភាពវៀងវៃ។

ការមួយដែលច្បាស់គឺ ប្រសិនការរំលូតកូនពិតជាសម្លាប់ទារក និងធ្វើឱ្យមានគ្រោះថ្នាក់ដល់ស្ត្រី នោះពិតជាមានការប្រថុយប្រថានដ៏មានគ្រោះថ្នាក់យ៉ាងច្រើនក្នុងការឈរនៅលើគែម ហើយមិនធ្វើអ្វីមួយនោះសោះ។

# ជំពូកទី ២
# គាំទ្រស្ត្រី ឬគាំទ្រទារក?

ភរិយារបស់ខ្ញុំ និងខ្ញុំបានចូលរួមនៅក្នុងការងារគាំទ្រជីវិត ដោយព្រោះយើងមានការព្រួយបារម្ភចំពោះស្ត្រីដែលត្រូវបានខ្ទេចខ្ទាំដោយសារការរំលូតកូន។ នៅឆ្នាំ ១៩៨១ យើងបានបើកចំហផ្ទះរបស់យើង សម្រាប់ក្មេងស្រីជំទង់មានគភ៌ម្នាក់។ ខ្ញុំបម្រើនៅក្នុងក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលសម្រាប់ស្ត្រីមានគភ៌នៅតំបន់ឆ្នេរខាងលិច ដែលផ្តល់ជំនួយដល់ស្ត្រីមានគភ៌ ដែលមានសេចក្តីត្រូវការ មានចិត្តច្របូកច្របល់ និងអស់សង្ឃឹម។ គោលដៅរបស់យើងគឺជួយដល់ស្ត្រីតាមគ្រប់វិធីដែលអាចជួយបាន។ វិធីល្អបំផុតដើម្បីជួយដល់ស្ត្រីទាំងនេះគឺផ្តល់ដល់ពួកគេនូវជម្រើសក្រៅពីការរំលូតកូន។

នៅពេលដែលពេលវេលាកន្លងទៅ ខ្ញុំក៏បានចូលរួមនៅក្នុងការផ្តល់ការអប់រំខាងការគាំទ្រជីវិត សកម្មភាពខាងនយោបាយ និងអន្តរាគមដោយអហិង្សា នៅខាងក្រៅមន្ទីររំលូតកូននានា។ ព័ន្ធកិច្ចខ្លះខាងការគាំទ្រជីវិត ផ្តោតច្រើនទៅលើការសង្គ្រោះទារកដែលមិនទាន់កើត ព័ន្ធកិច្ចខ្លះទៀតផ្តោតច្រើនលើការជួយស្ត្រីមានគភ៌។ ខ្ញុំរកឃើញថា ការខិតខំប្រឹងប្រែងទាំងពីរយ៉ាងសុទ្ធតែចាំបាច់ និងអាចដាក់ចូលគ្នាបាន។

## ចលនាដែលលោកអ្នកអាចនឹងមិនដឹង

មានរឿងមិនពិតរាប់មិនអស់ តែត្រូវបានភ្ជាប់ជាមួយនឹងចលនាគាំទ្រជីវិត។ ឧទាហរណ៍មួយគឺការប្រកាសច្រំដែលៗថា «ពួកអ្នកគាំទ្រជីវិតមិនខ្វល់ពីស្ត្រីមានគភ៌ ឬទារកទៀតឡើយ បន្ទាប់ពីទារកកើតហើយ»។ អ្នករាយការណ៍ឱ្យទូរទស្សន៍ម្នាក់ដែលមានម៉ាស៊ីនថតរូបភាពរេចុះរេឡើង បានចូលមកជិតខ្ញុំក្នុងពេលមានព្រឹត្តិការណ៍គាំទ្រជីវិតមួយ និងសុំឱ្យខ្ញុំឆ្លើយតបទៅចំពោះការចោទប្រកាន់ទាំងឡាយ។ ខ្ញុំនិយាយថា «ភរិយារបស់ខ្ញុំ និងខ្ញុំបានបើកចំហផ្ទះរបស់យើង សម្រាប់ក្មេងស្រីមានគភ៌ម្នាក់ និងចេញថ្លៃចំណាយទាំងប៉ុន្មានក្នុងពេលដែលនាងរស់នៅជាមួយយើង។ យើងបាន

ឧបត្ថម្ភដល់នាង នៅពេលដែលនាងសម្រេចចិត្តឱ្យកូនទៅគេចិញ្ចឹម។ ហើយដោយព្រោះតែអ្នកនាងសួរ យើងឱ្យបានផ្តល់ប្រាក់ចំណូលរបស់យើងមួយភាគធំដើម្បីជួយដល់ស្ត្រីក្រីក្រ និងទារក»។

បន្ទាប់មក ខ្ញុំក៏ណែនាំនាងចំពោះមិត្តភក្តិជាគ្រូគង្វាលម្នាក់ដែលកំពុងឈរនៅជិតខ្ញុំ ដែលរួមជាមួយភរិយាគាត់ ពួកគេបានចិញ្ចឹមកុមារដប់ប្រាំបួននាក់ ហើយមានកុមារខ្លះនៅក្នុងចំណោមពួកគេមានជំងឺរោគសញ្ញាដោន និងមានសេចក្តីត្រូវការពិសេសផ្សេងៗទៀត។ អ្នករាយការណ៍ឱ្យទូរទស្សន៍រូបនោះធ្វើសញ្ញាឱ្យអ្នកថតឈប់ថត។ ខ្ញុំសួរនាងប្រសិនបើនាងចង់សម្គាល់មិត្តរបស់ខ្ញុំ។ នាងក៏គ្រវីក្បាល និងបន្តដំណើរទៅមុខទៀត។

ការពិតគឺៈ មានអង្គការគាំទ្រជីវិតរាប់ពាន់អង្គការនៅពាសពេញប្រទេស និងនៅទូទាំងពិភពលោកដែលផ្តល់ដោយឥតគិតថ្លៃ នូវការសាកល្បងរកមើលការមានគភ៌ ការថតឆ្លុះគភ៌ ការប្រឹក្សា ក្រុមគាំទ្រ ថ្នាក់បង្រៀនអំពីការថែរក្សាកូន ការអប់រំអំពីការចាត់ចែងហិរញ្ញវត្ថុ ការមើលក្មេង ខោសម្រាប់ទារក សម្លៀកបំពាក់ក្មេង និងជម្រក។ បន្ថែមពីលើនេះ មានក្រុមជំនុំរាប់ពាន់ដែលបានធ្វើអំណោយជាពេលវេលា លុយ អាហារ ការជួសជុលផ្ទះ និងជំនួយផ្សេងទៀតដល់ស្ត្រីមានគភ៌ ដែលខ្វះខាត ម្តាយដែលនៅតែម្នាក់ឯង និងគ្រួសារដែលមានប្រាក់ចំណូលទាប។ មានអ្នកគាំទ្រជីវិតរាប់មិនអស់តែទទួលក្មេងយកធ្វើជាកូនចិញ្ចឹម បើកចំហផ្ទះរបស់ពួកគេ និងស្ម័គ្រចិត្តជួយទារកក្រោយពីពួកគេកើតហើយ។ ការខិតខំប្រឹងប្រែងទាំងអស់នេះរួមគ្នាបង្កើតបានជាចលនាអ្នកស្ម័គ្រចិត្តនៃពលរដ្ឋសាមញ្ញតែមួយដ៏ធំជាងគេបំផុតនៅក្នុងប្រវត្តិសាស្ត្រ។

ក្នុងពេលដែលអស់អ្នកផ្តល់សេវារំលូតកូន ទាមទារឱ្យស្ត្រីបង់ប្រាក់ អស់អ្នកដែលផ្តល់នូវជម្រើសក្រៅពីការរំលូតកូនផ្តល់ជំនួយដល់ពួកគេដោយឥតគិតថ្លៃ ដោយសេចក្តីស្រឡាញ់ និងស្ទើរតែពីខាងក្រោយឆាកទាំងស្រុង។ ផ្ទុយពីរូបភាពខ្លះ មនុស្សទាំងនេះមិនគ្រាន់តែគាំទ្រការផ្តល់កំណើតប៉ុណ្ណោះទេ ពួកគេក៏ជាអ្នកគាំទ្របន្ទាប់ការផ្តល់កំណើតដែរ។ ពួកគេយកចិត្តទុកដាក់ចំពោះទារក និងម្តាយរបស់ទារក ហើយពួកគេនៅទីនោះដើម្បីជួយពួកគេមិនគ្រាន់តែនៅមុនទារកកើតប៉ុណ្ណោះទេ ប៉ុន្តែនៅពេលក្រោយពីទារកកើតផងដែរ។

## ជម្រើជាតិរបស់យើង

ទោះជាមានការបែងចែកដែលស្ទើរតែស្មើគ្នានៅក្នុងចំណោមអស់អ្នកដែលហៅខ្លួនគេថា ជាអ្នកគាំទ្រការជ្រើសរើស និងអ្នកគាំទ្រជីវិតក៏ដោយ ក៏ពីរភាគបីនៃប្រជាពលរដ្ឋអាមេរិចនិយាយថា ពួកគេជឿថា ការរំលូតកូនគឺជារឿង «ខុសសីលធម៌»[១]។អ្នកតស៊ូមតិខាងគាំទ្រជីវិតខ្លះបានបកស្រាយត្រង់នេះថា មិនចាំបាច់ប្រកែកតវ៉ាថា ទារកដែលមិនទាន់កើតជាមនុស្សដែរ ឬថាការរំលូតកូនគឺជារឿងខុសនោះទៀតទេ។ ការសង្កត់ធ្ងន់របស់យើងគួរតែទៅលើការជួយស្ត្រីឱ្យមើលឃើញថា ការរំលូតកូនមិនមែនជាផលប្រយោជន៍ល្អបំផុតរបស់ពួកគេទេ។

ខ្ញុំយល់ព្រមថា យើងគួរជួយស្ត្រីមានគភ៌ដែលចង់បាន ឱ្យមើលឃើញថាការរំលូតកូននឹងធ្វើឱ្យពួកគេឈឺចាប់ គឺមិនមែនជួយពួកគេទេ។ ស្ត្រីជាច្រើនជឿថាការរំលូតកូនគឺជារឿងខុស ប៉ុន្តែនៅគឺជារឿងអាក្រក់ដែលតូចជាងគេបំផុត ហើយពួកគេគិតថា វានៅតែជាជម្រើសល្អជាងការមានកូន ចិញ្ចឹមកូន ឬឱ្យកូនទៅគេចិញ្ចឹម[២]។

យើងត្រូវតែបង្ហាញពួកគេថា ក្នុងពេលដែលជម្រើសផ្សេងទៀតជាជម្រើសពិបាក ការរំលូតកូនគឺជាជម្រើសតែមួយគត់ដែលសម្លាប់មនុស្សស្លូតត្រង់។ ច្បាស់ណាស់ ដោយព្រោះតែវាធ្វើដូច្នោះ វាផ្តល់នូវផលលំបាកអវិជ្ជមានច្រើនជាងគេបំផុតនៅក្នុងជីវិតរបស់ស្ត្រី។

ទោះជាយ៉ាងណាក្តី មនុស្សជាច្រើននៅក្នុងចំណោមមនុស្សដដែល ដែលជឿថាទារកមិនទាន់គឺជាមនុស្ស ហើយថា ការរំលូតកូនគឺជាអំពើអសីលធម៌ ពួកគេនៅតែជ្រើសរើសរំលូតកូន ហើយការពារការរំលូតកូនថាជាអំពើស្របច្បាប់។ ការនេះបញ្ជាក់ថា ពួកគេមិនជឿថា ទារកដែលមិនទាន់កើតគឺជាមនុស្សទេ គឺដូចគ្នាដែលពួកគេជឿថា ក្មេងអាយុបីឆ្នាំគឺជាមនុស្ស។ ពួកគេមិនជឿថា ការរំលូតកូន គឺជាអំពើអសីលធម៌ តាមរបៀប ដែល ពួកគេជឿថា ការ សម្លាប់ ក្មេង អាយុ បីឆ្នាំ គឺ ជា អំពើអសីលធម៌យ៉ាងដូច្នោះដែរ។

ការស្ទង់មតិក៏ចង្អុលបង្ហាញផងដែរថា មនុស្សជាច្រើន នៅក្នុងចំណោមមនុស្សដដែល ដែលជឿថាការរំលូតកូនគឺជាអំពើអសីលធម៌ ប៉ុន្តែនៅតែជឿថា វាគួរតែធ្វើឱ្យស្របច្បាប់។ វាយុត្តិធម៌ ដែលសន្មតថា មនុស្សទាំងនេះជឿថា ការរំលោភខាងផ្លូវភេទ ការចាប់ពង្រត់ ការរំលោភបំពានលើកុមារ និងអំពើមនុស្សឃាត សុទ្ធតែជាអំពើអសីលធម៌ ប៉ុន្តែពួកគេនឹងមិនប្រកែកតវ៉ាថា ការរំលោភខាងផ្លូវភេទ និងអំពើ

មនុស្សឃាតគួរតែជាអំពើស្របច្បាប់នោះឡើយ។ ការនេះចង្អុលបង្ហាញឱ្យឃើញនូវភាពខុសគ្នាជាមូលដ្ឋានរវាងអ្វីដែលពួកគេចង់និយាយទាក់ទងនឹងការរំលោភខាងផ្លូវភេទថាជា «អំពើអសីលធម៌» និងទាក់ទងនឹងការរំលូតកូនថាជា «អំពើអសីលធម៌»។

គ្មាន នរណាម្នាក់ដែលរាប់ ទារក ដែល មិន ទាន់ កើត ថា ជា បុគ្គល ដែល ពេញ លក្ខណៈ អាច ការ ពារ សិទ្ធិស្របច្បាប់ ក្នុង ការ រំលូត បាន ដោយ សមហេតុផល នោះ ទេ គឺ ទាល់តែពួកគេការ ពារសិទ្ធិស្របច្បាប់ក្នុងការ សម្លាប់មនុស្សផ្សេងទៀតជាមុនសិន។ ក្រៅពីនេះ រាល់ការតវ៉ាសម្រាប់ការរំលូតកូនដែល ទាក់ទាញចំពោះភាពមិនសុខស្រួល ទម្ងន់ផ្លូវចិត្ត និងការលំបាកខាងហិរញ្ញវត្ថុរបស់ម្ដាយ ការតវ៉ានេះអាចត្រូវបាន ធ្វើឡើង ដោយ គួរ ឱ្យ ជឿ ជាក់ គឺអំពី កូន អាយុដប់ពីរ ឆ្នាំ របស់ នាង ឬ ប្ដី របស់នាង ឬឪពុកម្ដាយរបស់នាង។ នៅក្នុងករណីជាច្រើន ក្មេងដែលមានអាយុច្រើន ត្រូវការ មានលុយ ច្រើនដើម្បីចិញ្ចឹម និងមានការ ទាមទារ ច្រើនពីម្ដាយរបស់ពួកគេ ជាងក្មេងដែលមិនទាន់កើត។ ប៉ុន្តែ មនុស្សទទួលស្គាល់ភ្លាមៗ នូវការតវ៉ាទាំងអស់នោះថាគ្មានសុពលភាព នៅពេលដែលវានិយាយដល់ការសម្លាប់ក្មេងដែលមានអាយុច្រើន។

ជាញឹកញាប់ស្ត្រីៗច្រើននិយាយថា នៅពេលដែលពួកគេរំលូតកូន ពួកគេមិនដឹងសោះថានរណាកំពុងនៅក្នុងខ្លួនគេ។ អ្នកខ្លះដឹង ដោយអនុសម្បជញ្ញៈថាពួកគេកំពុងតែពរពោះទារកម្នាក់ ប៉ុន្តែពួកគេប្រកាន់ខ្ជាប់តាមវោហាដ៏គួរឱ្យជឿជាក់របស់ពួកអ្នក គាំទ្រ ការ ជ្រើសរើសដែល ទម្លាក់តម្លៃរបស់មនុស្ស។ ឥឡូវនេះ ពួកគេមានការសោកស្ដាយយ៉ាងសង្វេគចំពោះការនេះ។ ពួកគេគិតអំពីអ្វីដែលពួកគេបានធ្វើថាជាអំពើលេលាបណ្ដោះអាសន្ន ដែលជួយដោយមិត្តភក្តិ ឬគ្រួសារដែលមានគោលបំណងល្អ ប៉ុន្តែមានការគិតខុស។ ពួកគេប្រាថ្នាចង់ឱ្យមាននរណាម្នាក់ដែលព្យាយាមនិយាយជាមួយពួកគេ កុំឱ្យជ្រើសរើសជម្រើសមួយដែលឥឡូវនេះមកលងគេវិញ។

យើង គួរ ស្រឡាញ់ និង យកចិត្ត ទុកដាក់ ចំពោះ ស្ត្រី មាន គភ៌ ដែល មាន អារម្មណ៍ទទួលសម្ពាធឱ្យគិតឆ្ពោះទៅរកការរំលូតកូន។ យើងក៏គួរស្រឡាញ់ស្ត្រីដែលធ្លាប់បានរំលូតកូនផងដែរ និងធ្វើអ្វីៗទាំងអស់ដែលយើងអាចធ្វើបាន ដើម្បីជួយពួកគេឱ្យជាពីរបួសផ្លូវចិត្តដែលកើតឡើងដោយសារការរំលូតកូន។

សៀវភៅពីបុរាណគឺគម្ពីរសុភាសិត និយាយថា ការ ជ្រើសរើស ត្រឹមត្រូវ គឺតែងតែ ជាប្រាជ្ញា និង នាំមក នូវ លទ្ធផល ល្អ រីឯ ការជ្រើសរើស ខុស តែងតែ ជា រឿង លេលា និងនាំមកនូវលទ្ធផលអាក្រក់។

## ការបែងចែកក្លែងក្លាយ

វាមិនមែនជារឿងមួយដែលផ្តល់ផលប្រយោជន៍ល្អបំផុតសម្រាប់អស់នរណាម្នាក់ក្នុងការសម្លាប់ក្មេងម្នាក់នោះទេ។ នៅពេលដែលទារកម្នាក់ត្រូវឈឺចាប់ដោយសារម្តាយរបស់ខ្លួន វាមិនមែននាំគ្រោះថ្នាក់សម្រាប់តែទារកប៉ុណ្ណោះទេ ប៉ុន្តែគឺសម្រាប់ម្តាយផងដែរ។ វាមិនអាចទៅរួចទេ ក្នុងការបំបែកសុខុមាលភាពរបស់ស្ត្រីពីកូនរបស់ខ្លួន។ ច្បាស់ណាស់ ដោយព្រោះតែទារកដែលមិនទាន់កើតគឺជាក្មេងម្នាក់ផលវិបាកនៃការសម្លាប់ក្មេងនោះធ្ងន់ធ្ងរណាស់។ វាគឺជាអត្តសញ្ញាណនៃជនរងគ្រោះដំបូង គឺក្មេងនោះឯង ដែលនាំឱ្យមានគ្រោះថ្នាក់ដល់ជនរងគ្រោះទីពីរ គឺជាម្តាយនោះឯង។ ហេតុនោះហើយបានជាយើងត្រូវការចាប់ផ្តើមការដោះស្រាយបញ្ហានៃការរំលូតកូន ជាមួយនឹងអត្តសញ្ញាណរបស់ទារកមិនទាន់កើត។

# ផ្នែកទី២

# ទារក

# ជំពូកទី ៣

# តើទារកមិនទាន់កើតពិតជាមនុស្សឬ?

ពួកអ្នកតស៊ូមតិខាងអ្នកគាំទ្រការជ្រើសរើស ជាទូទៅតែងប្រកាសថា «វាមិនប្រាកដសោះ ចំពោះពេលដែលជីវិតរបស់មនុស្សចាប់ផ្ដើម នោះគឺជាសំណួរខាងសាសនាដែលវិទ្យាសាស្ត្រមិនអាចឆ្លើយបាន»។ មនុស្សភាគច្រើនបានបោះបង់ជំហរនេះចោល ព្រោះវាត្រូវបានប្រឆាំងដោយភស្តុតាងខាងវិទ្យាសាស្ត្រដែលត្រូវបានរកឃើញអស់រយៈពេលរាប់ទសវត្សកន្លងមក។ ទោះជាយ៉ាងណាក្ដី ជំនឿដែលហួសសម័យកាលនេះ បានជ្រួតជ្រាបចូលយ៉ាងជ្រៅទៅក្នុងព្រលឹងជាតិរបស់យើង ដែលត្រូវបានគេទទួលយកយ៉ាងទូលំទូលាយ។

វិធីតែមួយគត់ដើម្បីតក្កភាពនៃជំហរគាំទ្រការជ្រើសរើសអាចឈ្នះបាន គឺប្រសិនបើមនុស្សជឿថា ទារកដែលមិនទាន់កើតមិនទាន់ជាមនុស្សពេញលេញនៅឡើយទេ។ តើពួកគេពិតជាមិនទាន់ក្លាយជាមនុស្សពេញលេញមែនឬ?

## អ្វីដែលវិទ្យាសាស្ត្រនិយាយ

លោកបណ្ឌិត អាល់ប្រេត អិម. ប៊ុងហ្គីយ៉ូអានី (Alfred M. Bongioanni) សាស្ត្រាចារ្យខាងការសម្រាលកូន នៅសាកលវិទ្យាល័យ ផេនស៊ីលវេនា (Unversity of Pennsylvania) បានថ្លែងថា «ខ្ញុំបានរៀនពី ការអប់រំ ខាងវេជ្ជសាស្ត្រដំបូងបំផុតរបស់ខ្ញុំ ថា ជីវិតមនុស្សចាប់ផ្ដើមនៅពេលមានការបង្កកំណើតដំបូងបំផុត... ជីវិតមនុស្សមានវត្តមាននៅពាសពេញដំណាក់កាលទាំងមូលចាប់តាំងពីពេលបង្កកំណើតកំណើតរហូតដល់ពេញវ័យ... ការរំខានណាមួយកើតឡើងនៅចំណុចណាមួយ នៅពាសពេញពេលនេះ នាំឱ្យមានការបញ្ចប់នៃជីវិតមនុស្ស»។

និយាយអំពីដំណាក់កាលដំបូងៗនៃការវិវឌ្ឍន៍របស់ទារកនៅក្នុងផ្ទៃ លោកសាស្ត្រាចារ្យ ប៊ុងហ្គីអូអានី (Bongioanni) និយាយថា «ខ្ញុំលែងហ៊ាននិយាយទៀតហើយថា ដំណាក់កាលដំបូងៗទាំងអស់នេះ តំណាងឱ្យមនុស្សដែលមិនទាន់គ្រប់លក្ខណៈនោះ ហើយខ្ញុំក៏លែងហ៊ាននិយាយទៀតដែរថា កូនក្មេងនៅមុនពេល

អានុភាពដ៏អស្ចារ្យនៃការលូតលាស់ជាមនុស្សពេញវ័យនោះមិនមែនជាមនុស្ស។ នេះគឺជាជីវិតមនុស្សនៅគ្រប់ដំណាក់កាល»[១]។

លោកបណ្ឌិត យ៉េរូម លីជូន (Jerome LeJeune) ជាសាស្ត្រាចារ្យខាងពូជមនុស្សនៅឯសាកលវិទ្យាសាស្ត្រ ដេកា (University of Descartes) ក្នុងទីក្រុងប៉ារីបានថ្លែងថា «បន្ទាប់ពីការផ្សំកំណើតកើតឡើង នោះមនុស្សថ្មីម្នាក់បានចាប់កំណើតឡើងហើយ»។ គាត់និយាយថា «វាលែងជារឿងមតិ ឬរសជាតិទៀតហើយ។ មនុស្សម្នាក់ៗមានការចាប់ផ្តើមដ៏ប្រសើរ នៅពេលចាប់កំណើត»[២]។

សាស្ត្រាចារ្យ មីសេលីន មែធីវ រ៉ស (Micheline Matthews-Roth) នៃសាលាវេជ្ជសាស្ត្រសាកលវិទ្យាល័យ ហាវើឌ (Harvard University Medical School) បាននិយាយថា «វាជារឿងត្រឹមត្រូវខាងវិទ្យាសាស្ត្រ ដែលនិយាយថា ជីវិតមនុស្សម្នាក់ចាប់ផ្តើមនៅពេលចាប់កំណើត»[៣]។

ខណៈពេលនៃការបង្កើតមនុស្សម្នាក់ គឺជាខណៈពេលដេលគេចាប់កំណើតនោះឯង។ មុនពេលខណៈនោះ មនុស្សម្នាក់នោះ (ជាមួយនឹង ឌីអិនអេ-DNA ពិសេសរបស់ខ្លួន) មិនទាន់មាននៅឡើងទេ។ ចាប់ពីខណៈពេលនោះមក ទើបមនុស្សម្នាក់មាន។

វាមិនមែនជារឿងមួយដែលមានតែមនុស្សដែលគាំទ្រជីវិតប៉ុណ្ណោះ ដែលជឿលើការនេះទេ។ ម្ចាស់មន្ទីររំលូតកូនធំជាងគេបំផុតនៅរដ្ឋអរីហ្គិន បានផ្តល់សក្ខីកម្មដោយសម្បថថា «*ពិតណាស់* ជីវិតមនុស្សចាប់ផ្តើមនៅពេលបង្កកំណើត»[៤]។ សៀវភៅមិនមែនគ្រិស្តបរិស័ទដែលបានទទួលរង្វាន់ ដែលមានចំណងជើងថា *ចាប់ពីពេលបង្កកំណើតរបស់ដល់ពេលកើត (From Conception to Birth)* បានកត់ត្រាការចាប់ផ្តើមរបស់ទារក នៅពេលបង្កកំណើត និងចលនារបស់ទារករហូតដល់ពេលកើត[៥]។

តើភស្តុតាងដែលបញ្ជាក់ថាជីវិតមនុស្សចាប់ផ្តើមនៅពេលបង្កកំណើតនោះច្បាស់យ៉ាងណា? គឺច្បាស់ណាស់ដែលសភារដ្ឋមីស៊ូរី (Missouri General Assembly) បានអនុម័តដោយមតិលើសលប់នូវច្បាប់ឆ្នាំ ២០០៣ ដែលចែងថា «សភានៃរដ្ឋនេះរកឃើញថា (១) ជីវិតរបស់មនុស្សម្នាក់ៗចាប់ផ្តើមនៅពេលបង្កកំណើត (២) ទារកដែលមិនទាន់កើតមានផលប្រយោជន៍ដែលត្រូវការពារនៅក្នុងជីវិត សុខភាព និងសុខុមាលភាព ពាក្យថា ទារកមិនទាន់កើត ត្រូវរាប់បញ្ចូលទារកមិនទាន់កើត ឬកូនជាតំណវង្សរបស់មនុស្សចាប់តាំងពីខណៈពេលបង្កកំណើត រហូតដល់ពេលកើត នៅគ្រប់ដំណាក់កាលនីមួយៗ នៃការវិវឌ្ឍន៍ខាងជីវសាស្ត្រ»[៦]។

## ភាពស្មុគស្មាញ និងមនុស្ស

ស៊ុតដែលទើបនឹងទទួលការផ្សំកំណើត មានផ្ទុកនូវចំនួនព័ត៌មានពូជ ដែលល្មមគ្រប់គ្រាន់ដើម្បីគ្រប់គ្រងលើកការរីកចម្រើន និងការវិវឌ្ឍន៍របស់មនុស្សម្នាក់ៗ សម្រាប់ពេញមួយជីវិតរបស់ពួកគេ។ ឌីអិនអេ (DNA) តែមួយសសៃយកចេញពីកោសិការបស់មនុស្សផ្ទុកនូវព័ត៌មាន ដែលស្មើនឹងបណ្ណាល័យមួយដែលមានសៀវភៅមួយពាន់ក្បាល[៧]។

កោសិកាទាំងឡាយរបស់មនុស្សដែលទើបនឹងកំណើតថ្មីៗ បែងចែក និងពង្រីកជាពហុគុណយ៉ាងឆាប់រហ័ស ដែលនាំឱ្យមានការរីកចម្រើនដ៏អស្ចារ្យ មានការរីកចម្រើន ព្រោះមានជីវិត។ ក្នុងរយៈពេលយ៉ាងយូរមុនពេលដែលស្ត្រីដឹងថា ខ្លួនមានគភ៌ គឺនៅក្នុងខ្លួននាងមានមនុស្សដែលកំពុងតែរីកចម្រើនឡើងទៅហើយ។ ក្នុងរវាងពីប្រាំទៅប្រាំបួនថ្ងៃបន្ទាប់ពីការបង្កកំណើត មនុស្សដែលទើបនឹងចាប់កំណើតថ្មីៗ ធ្វើរូងទៅក្នុងជញ្ជាំងស្បូន ដើម្បីសុវត្ថិភាព និងការបំប៉ន។ ភេទរបស់ទារកនោះអាចត្រូវបានស្គាល់រួចទៅហើយ តាមវិធីខាងវិទ្យាសាស្ត្រ។ លុះបានដប់ថ្ងៃ ទារកផលិតអ័រម៉ូនដែលទប់លំហូររដូវរបស់ម្តាយ។ វាត្រូវការរយៈពេលពីរសប្តាហ៍ទៀត មុនពេលដែលទម្រង់រូបរាងមនុស្សច្បាស់ត្រូវបានសង្កេតឃើញ ហើយបីខែទៀតទើបរូបរាងនោះលេចឡើងកាន់តែច្បាស់។ ប៉ុន្តែទារកនោះនៅតែជាសមាជិកពេញលក្ខណៈនៃមនុស្សជាតិ។

នៅពេលបង្កកំណើត ទារកមិនទាន់កើតមិនមានទំនងជាមនុស្សឡើយ ចំពោះយើងដែលធ្លាប់តែវិនិច្ឆ័យមនុស្សជាតិដោយសំបកខាងក្រៅ។ ទោះជាយ៉ាងណាក្តី នៅក្នុងន័យខាងវិទ្យាសាស្ត្រ ទារកនោះជាមនុស្សនៅក្នុងគ្រប់ចំណុចទាំងអស់ដូចជាកុមារដែលមានអាយុច្រើនជាងនោះ ឬមនុស្សពេញវ័យដែរ។ ទារកនោះមើលទៅដូចជាមនុស្សនៅក្នុងដំណាក់កាលនៃការវិវឌ្ឍន៍របស់ខ្លួន។

នៅដប់ប្រាំបីថ្ងៃបន្ទាប់ពីការបង្កកំណើត បេះដូងត្រូវបានលេចចេញជារូបរាងឡើង ហើយភ្នែកក៏ចាប់ផ្តើមចេញជារូបរាងដែរ។ នៅថ្ងៃទីម្ភៃមួយ បេះដូងចាប់ផ្តើមបាញ់បញ្ជូនឈាមទៅពាសពេញរាងកាយ។ នៅថ្ងៃទីម្ភៃប្រាំបី ទារកមិនទាន់កើតបានលេចចេញជាពន្លកដៃ និងជើង។ ដល់ថ្ងៃទីសាមសិប ទារកនោះមានខួរក្បាល ហើយបានពង្រីកទំហំខ្លួនរាប់ម៉ឺនដង។

ដល់ថ្ងៃទីសាមសិបប្រាំ មាត់ ត្រចៀក និងច្រមុះចាប់ផ្តើមចេញជារូបរាង។

នៅថ្ងៃទីសែសិប ចរន្តខួរក្បាលរបស់ទារកមិនទាន់កើតនោះអាចត្រូវបានកត់ត្រាហើយ ចង្វាក់បេះដូង ដែលបានចាប់ផ្តើមតាំងពីបីសប្តាហ៍មុន អាចត្រូវបានស្តាប់ដោយម៉ាស៊ីនឆ្លុះរួចទៅហើយ។ ដល់ថ្ងៃទីសែសិបពីរ ឆ្អឹងរបស់ទារកបានកឡើង ហើយខួរក្បាលរបស់ទារកកំពុងតែគ្រប់គ្រងលើចលនារបស់សាច់ដុំ និងសរីរាង្គផ្សេងៗ។

មិនថាទារកនោះមើលទៅមានរូបរាងយ៉ាងណាទេ ទារកនៅតែជាទារក។ ហើយជានិច្ចកាល ការរំលូតកូនគឺជាការបញ្ចប់ជីវិតរបស់ទារកនោះ។ មធ្យោបាយមុនបំផុតដើម្បីបង្កឱ្យមានការរំលូតកូន រាប់បញ្ចូលទាំងថ្នាំ Mifepristone (RU-486) និងថ្នាំរំលូតកូនទាំងអស់ សុទ្ធតែយឺតពេលក្នុងការចៀសវាងសម្លាប់ជីវិត។

## ល្ខោននៃជីវិត

អ្នកថតរូបក្នុងស្បូនដ៏ល្បីល្បាញឈ្មោះ ឡិនណាត នៀលសិន (Lennart Nilsson) ដែលត្រូវបានគេស្គាល់ច្បាស់តាមរយៈរូបថតរៀបរាប់របស់គាត់នៅក្នុងទស្សនាវដ្តី *ជីវិត (Life)* និងសៀវភៅរបស់គាត់ដែលមានចំណងជើងថា *ទារកកើតហើយ (A Child Is Born)*។ នៅក្នុងសៀវភៅ«ល្ខោននៃជីវិតមុនពេលកើត» របស់គាត់ គាត់និយាយអំពីទារកមិនទាន់កើតនៅសែសិបប្រាំថ្ងៃក្រោយពីពេលបង្កកំណើត (គឺមុនពេលដែលស្ត្រីជាច្រើនដឹងថាខ្លួនមានគភ៌ទៅទៀត) ថា៖ «ទោះបើទារកដែលទើបនឹងបង្កកំណើតឥឡូវនេះមានទម្ងន់ត្រឹមតែប្រហែលមួយក្រាមក៏ដោយ ក៏ទារកនោះមានសរីរាង្គខាងក្នុងទាំងអស់ដូចជាមនុស្សពេញវ័យ នៅក្នុងដំណាក់កាលផ្សេងៗនៃការវិវឌ្ឍន៍។ ទារកមានមាត់តូចដែលមានបបូរមាត់ និងអណ្តាត និងពន្លកសម្រាប់ធ្មេញទឹកដោះ។ សរីរាង្គបន្តពូជបានចាប់ផ្តើមចេញពន្លកឡើង»[៨]។

មកដល់សប្តាហ៍ទីប្រាំបី ដៃ និងជើងស្ទើរតែមានរូបរាងពេញលក្ខណៈ។ មកដល់សប្តាហ៍ទីប្រាំបួន ទារកនឹងចាប់ផ្តើមដាក់ម្រាមដៃនៅជុំវិញវត្ថុមួយដែលដាក់នៅលើបាតដៃ។ ក្រចកដៃកំពុងតែលេចចេញមក ហើយទារកកំពុងតែជញ្ជក់មេដៃរបស់ខ្លួន។ ទារកអាយុប្រាំបួនសប្តាហ៍ «ចេះក្រឡាប់ខ្លួនចុះឡើងយ៉ាងស្ទាត់ជំនាញ» រួចទៅហើយ[៩]។

ទារកមិនទាន់កើតឆ្លើយទៅនឹងអ្វីដែលធ្វើឱ្យប៉ះពាល់អារម្មណ៍ ហើយអាចនឹងមានសមត្ថភាពទទួលអារម្មណ៍ឈឺចាប់ដែរ[១០]។ ប៉ុន្តែការរំលូតកូននៅដំណាក់កាលនេះ នៅតែត្រឹមបានគេហៅថា «ការរំលូតនៅដំណាក់កាលដំបូង»។

មកដល់សប្តាហ៍ទីដប់ ទារកចេះធ្មេចភ្នែក លេប និងជ្រួញចិញ្ចើម។ មកដល់សប្តាហ៍ទីដប់មួយ ទារកចាប់ផ្តើមបន្ទោបង់ បង្ហាញទឹកមុខច្រើនយ៉ាង ថែមទាំងចេះញញឹមទៀតផង[១១]។ មកដល់សប្តាហ៍ទីដប់ពីរ ទារកចាប់ផ្តើមធាក់ បង្វិលជើងរបស់ខ្លួន បត់ចុះឡើង និងកម្រើកម្រាមជើង ក្តាប់ដៃ និងកម្រើកមេដៃ បត់កដៃ និងបើកមាត់របស់ខ្លួន[១២]។

ការទាំងអស់នេះកើតឡើងនៅក្នុងត្រីមាសទីមួយ គឺរយៈពេលបីខែដំបូងនៃជីវិត។ នៅក្នុងរយៈពេលនៅសល់ប្រាំមួយខែទៀតនៅក្នុងផ្ទៃម្តាយ គ្មានអ្វីថ្មីទៀតដែរ វិវឌ្ឍន៍ ឬចាប់ផ្តើមដំណើរការទេ។ ទារកដែលមានរូបរាងពេញលក្ខណៈ គ្រាន់តែរីកលូតលាស់ និងចម្រើនវ័យ បើជីវិតរបស់ទារកនោះមិនបានបាត់បង់ដោយសារតែការរលូត ឬត្រូវបានដកយកតាមរយៈការរំលូតកូនទេនោះ។

វាគឺជាការពិតខាងវិទ្យាសាស្ត្រដែលមិនអាចប្រកែកបានដែលគ្រប់ការវះកាត់រំលូត កូន នីមួយៗ នៅ សហរដ្ឋ អាមេរិច គឺ ជា ការ បញ្ឈប់ បេះដូង ដែល កំពុង មានចលនា និងបញ្ឈប់ចរន្តខួរក្បាលដែលអាចវាស់វែងបាន។

តើយើងហៅថាដូចម្តេច នៅពេលដែលមនុស្សម្នាក់លែងមានចលនាបេះដូង ឬចរន្តខួរក្បាល? គឺស្លាប់។

តើ យើង ហៅ ថា ដូចម្តេច នៅ ពេល ដែល មាន ចង្វាក់ បេះដូង និង នៅ ពេល មានចរន្តខួរក្បាល? គឺជីវិត។ គ្រប់ការរំលូតកូនគឺជាការបញ្ចប់ជីវិតមនុស្ស។

**SLED**

លោក ស្កត់ គ្លូសិនដូហ្វ (Scott Klusendorf) និយាយថា «ចម្លើយចំពោះសំណួរ តើវាគឺជាអ្វី ឈ្នះលើការពិចារណាផ្សេងទៀតទាំងអស់»[១៣]។ គាត់ចង្អុលបង្ហាញថា មានភាពខុសគ្នាតែបួនប៉ុណ្ណោះ រវាងទារកមិនទាន់កើត និងទារកដែលកើតហើយ។ គេអាចចងចាំអំពីភាពខុសគ្នាទាំងបួនតាមរយៈពាក្យជាភាសាអង់គ្លេសថា SLED[១៤] ដែលត្រូវបានសង្ខេបដូចខាងក្រោមនេះ:

*Size (ទំហំ):* តើទំហំរបស់អ្នកកំណត់នូវលក្ខណៈរបស់អ្នកឬ?

*Level of development (កម្រិតនៃការវិវឌ្ឍន៍):* តើអ្នកមានអាយុម្ភៃឆ្នាំ មានលក្ខណៈជាមនុស្សច្រើនជាងអ្នកមានអាយុដប់ឆ្នាំ ដោយព្រោះពួកគេឆ្លាតជាង និងខ្លាំងជាងឬ?

*Environment (បរិស្ថាន):* តើការស្ថិតនៅក្នុងផ្ទះ ធ្វើឱ្យអ្នកក្លាយជា

តើខ្ញុំដែលជាអ្នកមានជំងឺទឹកនោមផ្អែមពឹងផ្អែកលើសារធាតុអ៊ីនស៊ូលីន មិនមែនជាមនុស្សពេញលក្ខណៈទេឬអី? នៅពេលដែលខ្ញុំចាប់ផ្តើមមានជំងឺនេះតើវាធ្វើឱ្យខ្ញុំទៅជាអន់ជាងមនុស្សធម្មតាឬ?

ក្មេងអាយុបីខែ មានមាឌតូចជាងក្មេងអាយុដប់ឆ្នាំ មិនមានការវិវឌ្ឍន៍ច្រើនទេ ហើយក៏គ្មានសមត្ថភាពនឹងថែរក្សាខ្លួនដូចជាទារកដែលមិនទាន់កើតដែរ។

សំណួរគឺមិនមែនស្ថិតនៅលើថាតើទារកមិនទាន់កើតមានអាយុប៉ុន្មាន មានមាឌធំ ឬវៃឆ្លាត ឬពិបាកនោះទេ ប៉ុន្តែគឺស្ថិតនៅថាតើពួកគេជានរណា?

ចម្លើយគឺសាមញ្ញ ពួកគេជាមនុស្ស។

# ជំពូកទី ៤
# តើអ្វីជាភាពខុសគ្នារវាងស៊ុត (Egg) ស្ពែម ឬមេជីវិត (Sperm) អំប្រីយ៉ុង ឬទារកដែលទើបនឹងចាប់កំណើតដំបូង(Embryo) និង គភ៌ ឬទារកមិនទាន់កើតដែលមានរូបរាងពេញលក្ខណៈ (Fetus)?

រយៈពេលពីរឆ្នាំមុនពេលដែលការរំលូតកូនត្រូវបានធ្វើឱ្យស្របច្បាប់នៅក្នុងសហរដ្ឋអាមេរិច អ្នកតស៊ូមតិខាងអ្នកគាំទ្រការរំលូតកូនម្នាក់បានណែនាំគិលានុប្បដ្ឋាក គិលានុបដ្ឋាយិកាទាំងឡាយ នៅ ក្នុង ទិនានុប្បវត្តិ វេជ្ជសាស្ត្រ ដ៏ ល្បីល្បាញ មួយ ថា «តាមរយៈការបណ្ដុះបណ្ដាលសាធារណជន ការប្រើភាសា គោលគំនិត និង បញ្ញត្តិច្បាប់ គំនិតនៃការរំលូតកូន អាចត្រូវបានញែកចេញពីគំនិតនៃការសម្លាប់»[១]។ នៅឆ្នាំដដែលនោះ សន្និសីទនៅក្រុងឡូស អេនជើឡេសមួយ បានផ្ដល់នូវការបណ្ដុះបណ្ដាលនេះ៖ «ប្រសិនបើអ្នកនិយាយថា បឺតទារកចេញ អ្នកអាចបង្កើត ឬបង្កើននូវរបួសផ្លូវចិត្ត ដូច្នេះត្រូវនិយាយថា សំអាតស្បូន ឬ យើងនឹងកោសសំអាតស្រទាប់ខាងក្នុងនៃស្បូន ប៉ុន្តែមិនត្រូវនិយាយថា យើងនឹងកោសយកទារកចេញនោះទេ»[២]។

ភាសាមិនគ្រាន់តែជាការសម្ដែងចេញនូវគំនិតប៉ុណ្ណោះទេ ប៉ុន្តែវាជាអ្នកសូនគំនិតដែរ។ របៀបដែលភាសាត្រូវបានប្រើប្រាស់ ជះឥទ្ធិពលទៅលើការទទួលយកគំនិតរបស់យើង សូម្បីតែគំនិតដែលនៅពេលចែកចាយដោយប្រើពាក្យត្រង់ៗ នោះជាគំនិតដែលគួរឱ្យស្អប់ខ្ពើមក៏ដោយ។

ពាក្យទាំងឡាយដែលផ្ដោតលើការមានគភ៌ និងលើស្បូន នាំការយកចិត្តទុកដាក់ឱ្យចេញឆ្ងាយពីបុគ្គលដែលរស់នៅក្នុងស្បូន។ ប៉ុន្តែមិនថាជាយើងនិយាយអំពីការនេះដោយរបៀបណានោះទេ ទោះជា «សំអាតស្បូន» ឬ «ការបញ្ចប់ការមានគភ៌» ការទាំងនេះគឺជាការយកជីវិតមនុស្សហើយ។

អ្នកគាំទ្រជីវិត និងជាអ្នកស្ត្រីនិយមម្នាក់និយាយថា «ពួកអ្នកប្រឆាំងនឹងការ

រំលូតកូន មិនជំទាស់អ្វីទៅនឹងការបញ្ចប់ការមានគភ៌នោះទេ។ ការមានគភ៌ ត្រូវតែមានរយៈពេលមួយខ្លីប៉ុណ្ណោះ។ យើងចូលចិត្តបញ្ចប់ការមានគភ៌ក្នុងកំឡុងពេលប្រាំបួនខែ។ ការប្រឆាំងជំទាស់នោះគឺសម្រាប់ការសម្លាប់កូនក្មេង»[៣]។

## តើគភ៌ ឬទារកមិនទាន់កើតដែលមានរូបរាងពេញលក្ខណៈមានន័យដូចម្ដេច?

គឺដូចជា *កូនក្មេង* និង *មនុស្សពេញវ័យ* ពាក្យថា អំប្រីយ៉ុង ឬទារកទើបនឹងចាប់កំណើត និងគភ៌ ឬទារកមិនទាន់កើតដែលមានរូបរាងពេញលក្ខណៈ មិនមែននិយាយសំដៅទៅលើអ្វីដែលមិនមែនជាមនុស្សនោះឡើយ ប៉ុន្តែគឺនិយាយសំដៅទៅលើមនុស្ស ដែលកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការវិវឌ្ឍន៍ជាក់លាក់។ ពាក្យថា « Fetus» ដែលបកប្រែជាខ្មែរថា «គភ៌» ឬទារកមិនទាន់កើតដែលមានលក្ខណៈពេញរូបរាង គឺជាពាក្យឡាតាំង ដែលត្រូវបានបកប្រែថា «កូនចៅ» ឬ «កូនតូច»។

វាជារឿងមួយដែលមិនត្រឹមត្រូវខាងវិទ្យាសាស្ត្រដែលនិយាយថា អំប្រីយ៉ុងរបស់មនុស្ស ឬគភ៌ មិនមែនជាមនុស្ស ដោយព្រោះតែពួកគេស្ថិតនៅក្នុងដំណាក់កាលវិវឌ្ឍន៍មួយមុនពេលទារកដែលកើតហើយ។ ត្រង់នេះគឺដូចជាការនិយាយថា កូនក្មេងតូចមិនមែនជាមនុស្សទេ ព្រោះវាមិនទាន់ក្លាយជាមនុស្សពេញវ័យ។ កូនស្រីម្នាក់ក្នុងចំណោមកូនស្រីរបស់ខ្ញុំ មានអាយុច្រើនជាងកូនស្រីរបស់ខ្ញុំម្នាក់ទៀតពីរឆ្នាំ។ តើនេះមានន័យថាកូនស្រីនេះល្អជាងកូនស្រីមួយទៀតពីរឆ្នាំឬ? តើមនុស្សម្នាក់ក្លាយជាមនុស្សកាន់តែពេញលក្ខណៈ នៅពេលដែលពួកគេកាន់តែធំឬ? ប្រសិនបើដូច្នោះមែន នោះមានន័យថា មនុស្សពេញវ័យ មានលក្ខណៈជាមនុស្សច្រើនជាងកូនក្មេង ហើយអ្នកលេងបាល់ទាត់ មានលក្ខណៈជាមនុស្សច្រើនជាងអ្នកជិះសេះប្រណាំង។ អ្វីមួយដែលមិនមែនជាមនុស្ស មិនក្លាយទៅជាមនុស្ស ដោយសារតែវាមានវ័យកាន់តែចាស់ និងមានមាឌកាន់តែធំនោះទេ អ្វីដែលជាមនុស្ស គឺជាមនុស្សតាំងពីដំបូងមក។

## តើស៊ុត ឬមេជីវិតជាមនុស្សឬ?

លោក ខាល សេហ្គិន (Carl Sagan) បានចំអកឱ្យអ្នកដែលប្រឆាំងនឹងការរំលូតកូនដោយសួរថា «តើហេតុអ្វីបានជាការបំផ្លាញមេជីវិត ឬស៊ុត មិនមែនជាអំពើមនុស្សឃាត?»[៤] ចម្លើយ ដូចដែលអ្នកវិទ្យាសាស្ត្រគ្រប់រូបគួរដឹង គឺ មានភាពខុសគ្នាជាមូលដ្ឋានរវាងមេជីវិត និងស៊ុតដែលមិនបានបង្កកំណើត ហើយម្យ៉ាងទៀតជាមួយ

នឹងស៊ុតដែលបានបង្កកំណើតហើយ។

ដូចជាកោសិកាសក់ ឬបេះដូងរបស់មនុស្ស ទាំងស៊ុត ទាំងមេជីវិត សុទ្ធតែគ្មានសមត្ថភាពក្លាយទៅជាអ្វីមួយផ្សេងនោះឡើយ។ ប៉ុន្តែ នៅពេលដែលស៊ុត និងមេជីវិតត្រូវបានភ្ជាប់គ្នា ជីវិតមនុស្សដែលមានលក្ខណៈសម្គាល់ខាងសេនេទិចពិសេសតែមួយ ហើយដែលអាចមានសមត្ថភាពវិវឌ្ឍន៍យ៉ាងអស្ចារ្យនោះចាប់ផ្តើម។ ជីវិតនោះមិនមែនជាមេជីវិត និងមិនមែនជាស៊ុត ហើយក៏មិនមែនគ្រាន់តែជាការផ្សំគ្នារវាងមេជីវិត និងស៊ុតនោះដែរ។ ស៊ុតដែលបង្កកំណើតហើយ គឺជាមនុស្សដែលទើបនឹងចាប់កំណើតហើយ។ នោះគឺជាមនុស្សម្នាក់ ដែលមានជីវិតផ្ទាល់ ទាំងមានការវិវឌ្ឍន៍ដោយខ្លួនឯងដោយជំហានមួយយ៉ាងរហ័ស។ ចាប់តាំងពីខណៈពេលនៃការបង្កកំណើត កោសិកាដំបូងតែមួយនោះ មានគ្រោងសេនេទិចទាំងមូលរួចជាស្រេចនៅក្នុងនោះ។ ត្រង់នេះរួមមានគ្រប់ទាំងសេចក្តីលំអិតនៃការវិវឌ្ឍន៍របស់មនុស្ស ក៏រាប់បញ្ចូលនូវភេទរបស់ទារក ពណ៌សក់ និងពណ៌ភ្នែក កំពស់ និងសប្បុរស្បែក[៥]។ បើសិនជាគេយកកោសិកាតែមួយនៃមនុស្សដែលទើបនឹងបង្កកំណើតនោះ ហើយដាក់នៅក្បែរកោសិការបស់ស្វា អ្នកឯកទេសខាងសេនេទិច អាចសម្គាល់បានយ៉ាងងាយស្រួលថា កោសិកាណាមួយជាកោសិការបស់មនុស្ស។ ភាពជាមនុស្សនៃកោសិកានោះលេចចេញមកយ៉ាងច្បាស់[៦]។

ផលិតផល នៃ ការ បង្ក កំណើត (Product of Conception or POC) គឺ ជាការបន្ថោកតម្លៃជាទូទៅដល់ទារកមិនទាន់កើត។ តាមការពិត ទារក ក្មេងអាយុដប់ឆ្នាំ និងមនុស្សពេញវ័យសុទ្ធតែជាផលិតផលនៃការបង្កកំណើត មិនមែនគ្រាន់បើ ឬអន់ជាងគភ៌នោះឡើយ។ ដូចជាលទ្ធផលនៃការបង្កកំណើតរបស់សេះ ដែលតែងតែចេញមកជាសេះ នោះលទ្ធផលនៃការបង្កកំណើតរបស់មនុស្ស គឺតែងតែចេញមកជាមនុស្សដែរ។

ទំនាស់អំពី កោសិកាមេនៃអំប្រីយ៉ុង (Embryonic Stem Cells) គឺជាឧទាហរណ៍មួយនៃអំណាច។ កោសិកាមេគឺជាកោសិកាដ៏ឆ្លាតវៃដែលបង្កើតបានជាសរីរាង្គជាច្រើននៅក្នុងរូបកាយមនុស្ស។ កោសិកានេះត្រូវបានរាប់ថាជាសម្ភារៈចម្បងសម្រាប់ការស្រាវជ្រាវខាងជីវវេជ្ជសាស្ត្រ កោសិកាទាំងនេះមានប្រភពចេញពីមនុស្ស រាប់បញ្ចូលទាំងមនុស្សពេញវ័យដែលយល់ស្រប ឈាមនៃទងផ្ចិត និងសុក។ ប៉ុន្តែអ្នកវិទ្យាសាស្ត្រជាច្រើនប្តេជ្ញាចិត្តនឹងប្រើកោសិកាមេយកចេញពីទារកដែលទើបនឹងបង្កកំណើត ដែលបានបាត់បង់ជីវិតនៅពេលគេដកយកកោសិកានេះចេញ។ ទំនាស់អំពីសីលធម៌នេះ មាន ការជំពាក់ជំពិនយ៉ាងធ្ងន់ធ្ងរ សម្រាប់របៀបដែលយើងមើលទៅមនុស្សជាតិ និងថាតើ

ទារកទាំងនោះគ្មានតម្លៃនឹងរក្សាទុក គឺដើម្បីអាចបម្រើដល់មនុស្សដទៃទៀត[៧]។

ជាការមួយគួរឱ្យចាប់អារម្មណ៍ដែល វិទ្យាស្ថានសុខាភិបាលជាតិ (National Institute of Health) បានរកឃើញថា សាធារណជនមានប្រតិកម្មប្រឆាំងនឹង «ការស្រាវជ្រាវកោសិកាមេដែលយកចេញពីទារកមនុស្សដែលទើបនឹងបង្កកំណើត» នោះគឺជាការបំផ្លាញទារកដោយការធ្វើពិសោធន៍។ ដូច្នេះ វិទ្យាស្ថានសុខាភិបាលជាតិបានជ្រើសរើសពាក្យថ្មីមួយ ដើម្បីពិពណ៌នាអំពីសេចក្ដីដូចគ្នាគឺៈ «ការស្រាវជ្រាវកោសិកាមេរបស់មនុស្សដែលមានពហុសមត្ថភាព»។ ពាក្យថ្មីបំបាំងការពិតនៃទារកដែលទើបនឹងបង្កកំណើតដំបូង គឺជាវត្ថុសម្រាប់ពិសោធន៍[៨]។ ជាជាងការបញ្ឈប់ដំណើរការអសីលធម៌មួយ ពួកគេរកឈ្មោះថ្មីមកជំនួស។

## គ្មានការសង្ស័យ

ប្រសិនបើការបង្កើតមនុស្សចម្លង បានសម្រេច នោះមនុស្សម្នាក់នឹងចូលទៅក្នុងជីវិតដែលតតតដាច់ នៅចំណុចមួយបន្ទាប់ពីការបង្កកំណើត។ ការនេះនឹងមិនអាចធ្វើអ្វីមួយដើម្បីផ្លាស់ប្ដូរស្ថានភាពរបស់ពួកគេឡើយ។ គឺវត្តមានរបស់មនុស្សម្នាក់នៅក្នុងតំណនៃជីវិតមនុស្សនោះដែលសំខាន់ មិនមែនជារបៀបដែលគេទៅដល់ទីនោះទេ។

បណ្ឌិត ថូម៉ាស ហ៊ីលហ្គើរ (Thomas Hilgers) ថ្លែងថា «គ្មានរូបកាយណាមួយដែលមានជីវិតរស់នៅ អាចក្លាយជាមនុស្សបានឡើយ បើវាមិនមែនជាមនុស្សរួចទៅហើយទេនោះ។ គ្មានរបស់មានជីវិតណាមួយដែលអាចក្លាយទៅជាអ្វីមួយផ្សេងក្រៅពីខ្លួនឯងនោះឡើយ»[៩]។

ពួកអ្នកផ្ដល់សេវាកម្មរំលូតកូនបានពន្យល់យ៉ាងត្រង់ៗ ទទួលសារភាពនូវអ្វីដែលកើតឡើងនៅក្នុងពេលរំលូតកូន។ បណ្ឌិត វ៉ារិន ហ៊ើន (Warren Hern) ដែលបង្រៀនពួកវេជ្ជបណ្ឌិតឱ្យចេះរំលូតកូន បានពិពណ៌នាការងាររបស់គាត់ថាៈ

> ខ្ញុំចាប់ផ្ដើមការរំលូតកូន ដោយធ្វើទៅលើនារីវ័យក្មេងម្នាក់ដែលមានគភ៌អាយុ ១៧ សប្ដាហ៍... នៅពេលនោះខ្ញុំស៊កតំបៀតរបស់ខ្ញុំចូលទៅក្នុងស្បូន ហើយដាក់ពីលើក្បាលរបស់ទារកមិនទាន់កើតនោះ ដែលវានៅមានជីវិតនៅឡើយ ដោយព្រោះតែការចាក់ថ្នាំរំលូតកូនមិនត្រូវបានធ្វើឡើងនៅដំណាក់កាលនៃការមានគភ៌នោះ។ខ្ញុំបិទតំបៀតនោះរួចវាក៏កម្ទេចលលាដ៍ក្បាលរបស់ទារក

ហើយខ្ញុំក៏ដកតំបៀតនោះចេញមកវិញ។ ទារកនោះក៏ស្លាប់
ហើយចេញមកដោយនៅរូបរាងទាំងមូល។[១០]

បុរសម្នាក់នេះ ដែលឧទ្ទិសជីវិតរបស់ខ្លួនក្នុងការរំលូតកូន ហើយបង្រៀនឱ្យអ្នកដទៃចេះធ្វើដូចខ្លួន គ្មានសង្ស័យបន្តិចណាសោះថា ការរំលូតកូនគឺជាការសម្លាប់ទារក។

តើអ្នកដឹងអ្វីមួយដែលគាត់មិនដឹងដែរឬទេ?

# ជំពូកទី ៥
# តើទារកមិនទាន់កើត ជាផ្នែកមួយនៃរូបកាយរបស់ស្ត្រីឬ?

ដូចជាមនុស្សជាច្រើនផ្សេងទៀតដែរ ទស្សនវិទូ មរទីមើ អាដលើរ (Mortimer Adler)បានប្រកាសថា ទារកមិនទាន់កើតគឺជា «ផ្នែកមួយនៃរូបកាយរបស់ម្តាយ ក្នុងន័យដូចជាដៃ ឬជើងរបស់មនុស្សម្នាក់ គឺជាផ្នែកមួយនៃសរីរាង្គដែលមានជីវិត។ ការសម្រេចចិត្តរបស់មនុស្សម្នាក់ៗ ក្នុងការកាត់ដៃ ឬជើងចេញ គឺស្ថិតនៅក្នុងភាពឯកជនរបស់គេ គឺជាសេរីភាព ដែលមនុស្សម្នាក់អាចប្រព្រឹត្តការនេះតាមចិត្តរបស់ខ្លួន ក្នុងគ្រប់ការទាំងអស់ដែលមិនធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃ ឬដល់សុខុមាលភាពសាធារណៈ»[១]។

## ពិត ឬមិនពិត?

សរីរាង្គមួយនៃរូបកាយ ត្រូវបានសម្គាល់ដោយកូដសេនេទិច (Genetic Code) ដូចគ្នា ទៅនឹងសរីរាង្គផ្សេងទៀតនៅក្នុងរូបកាយ។ គ្រប់កោសិកាទាំងអស់នៃដុំអាកមីដាល់ (ដុំសាច់នៅលើបំពង់ក) ខ្នែងពោះវៀន បេះដូង និងសួតរបស់ម្តាយ គឺសុទ្ធដែលមានកូដសេនេទិចដូចៗគ្នា។ ទារកដែលមិនទាន់កើត ក៏មានកូដសេនេទិចដែរ ប៉ុន្តែវាខុសគ្នាស្រឡះពីកូដសេនេទិចរបស់ម្តាយ។ គ្រប់កោសិកាទាំងអស់របស់ទារកគឺជាកោសិកាប្លែកពីកោសិការបស់មនុស្សឯទៀតៗ ហើយក៏ខុសប្លែកពីកោសិកានីមួយៗរបស់ម្តាយរបស់វាដែរ។ ជាញឹកញាប់ក្រុមឈាមរបស់ទារកក៏ខុសពីក្រុមឈាមរបស់ម្តាយដែរ ហើយភេទរបស់ទារកប្រហែលជា ៥០ភាគរយដែលខុសពីភេទរបស់ម្តាយ។

ប្រសិនបើរូបកាយរបស់ស្ត្រីតែមួយគត់ដែលពាក់ព័ន្ធនឹងការមានគភ៌ នោះចូរពិចារណាអំពី សរីរាង្គដែលនាងត្រូវមានគឺ ច្រមុះពីរ ជើងបួន ស្មាម ម្រាមដៃពីរឈុត ខួរក្បាលពីរ ប្រព័ន្ធរបត់ឈាមពីរ និងប្រព័ន្ធគ្រោងឆ្អឹងពីរ។ នាងក៏ត្រូវតែមានប្រដាប់ភេទបុរសផងដែរ ព្រោះប្រហែលជា ៥០ ភាគរយនៃការមានគភ៌ជាកូនប្រុស។ ប្រសិនបើ ស្ត្រីមិនអាចមានប្រដាប់ភេទជាបុរសទេ នោះក្មេងប្រុសដែលកំពុងស្ថិតនៅក្នុងពោះរបស់នាង មិនអាចជាផ្នែកមួយនៃរូបកាយរបស់នាងបានឡើយ។

ទារកទើបនឹងបង្កកំណើតជនជាតិចិន ដែលត្រូវបានយកទៅដាក់ភ្ជាប់នៅក្នុងស្ត្រីជនជាតិស៊ុយអែត នឹងជាជនជាតិចិនជារៀងរហូត គឺមិនអាចជាជនជាតិស៊ុយអែតបានឡើយ ព្រោះអត្តសញ្ញាណរបស់វា គឺផ្អែកលើកូដសេនេទិចរបស់វាផ្ទាល់ មិនមែនផ្អែកលើរូបកាយដែលវាកំពុងនៅនោះទេ។

ទារកអាចស្លាប់ ហើយម្តាយរស់ ឬទារកអាចរស់ ហើយម្តាយស្លាប់ នេះបញ្ជាក់ថា ពួកគេគឺជាមនុស្សពីរនាក់ផ្សេងពីគ្នា[២]។

នៅក្នុងការវះកាត់ទារកកំពុងនៅក្នុងផ្ទៃ ទារកនោះដែលនៅតែជាប់នឹងម្តាយតាមរយៈទងសុក ត្រូវបានយកចេញ និងផ្តល់ថ្នាំសន្លប់ រួចត្រូវបានវះកាត់ រួចដាក់បញ្ចូលទៅក្នុងផ្ទៃរបស់ម្តាយវិញ។ ទារកនោះត្រូវបានហៅថាជាអ្នកជម្ងឺ និងត្រូវបានវះកាត់ ហើយមានកំណត់ត្រាវេជ្ជសាស្ត្រផ្ទាល់របស់វា ដែលចង្អុលបង្ហាញអំពីប្រភេទក្រុមឈាម និងសញ្ញាផ្សេងៗទាក់ទងនឹងជីវិត។

នៅឆ្នាំ ១៩៩៩ ទារកមិនទាន់កើតម្នាក់ឈ្មោះ សាំយូអែល អារម៉ាស (Samuel Armas) ត្រូវបានវះកាត់ លើជម្ងឺឆ្អឹងខ្នង (spina bifida)។ រូបថតរបស់ទារកនេះនៅក្នុងទស្សនាវដ្តី *ជីវិត* បានទាក់ទាញចំណាប់អារម្មណ៍របស់ពិភពលោក។ នៅពេលដែលគ្រូពេទ្យវះកាត់កំពុងតែរៀបនឹងដេរភ្ជិតទៅវិញ ទារកសាំយូអែលបានលូកដៃចេញពីផ្ទៃម្តាយមក ហើយចាប់ម្រាមដៃរបស់គ្រូពេទ្យ។ អ្នកថតរូបសារព័ត៌មាន ឈ្មោះម៉ៃឃើល ឃ្លែនស៊ី (Michael Clancy) បានចាប់សកម្មភាពដ៏អស្ចារ្យនេះនៅរូបថត។ (សូមមើលរូបភាពដែលបានឈ្នះរង្វាន់ស្រដៀងគ្នានេះ គឺរូបភាពរបស់ទារកមិនទាន់កើត សារ៉ា ម៉ារី ស្វីតហ្សើរ (Sarah Marie Switzer) នៅលើក្របខាងខ្នងនៃសៀវភៅនេះ។ លោកឃ្លែនស៊ីបានរាយការណ៍ថា «រំពេចនោះ ដៃទាំងមូលបានលូកចេញមកពីក្នុងផ្ទៃរួចក៏ដកទៅវិញ រហូតនៅសល់ត្រឹមបាតដៃ និងម្រាមដៃដ៏តូច ដែលបង្ហាញនៅពេលនោះ។ លោកគ្រូពេទ្យក៏លូកដៃទៅលើកដៃក៏តូចនោះ វាក៏មានប្រតិកម្ម និងច្របាច់ម្រាមដៃរបស់គ្រូពេទ្យ។ ដូចជាការសាកល្បងកម្លាំងដូច្នោះ គ្រូពេទ្យក៏អង្រួនកណ្តាប់ដៃតូចនោះ។ សាំយូអែលក៏កាន់យ៉ាងជាប់។ ខ្ញុំក៏ថតយករូបភាពនោះ! អស្ចារ្យមែន!»[៣]។

សាំយូអែល អារម៉ាស ក៏ត្រូវបានដេរភ្ជិតចូលទៅក្នុងផ្ទៃរបស់ម្តាយវិញ ហើយបន្ទាប់មក ក៏កើតក្នុងរយៈពេលជិតបួនខែក្រោយមក។ តើការដែលមើលឃើញសាំយូអែលចាប់ម្រាមដៃរបស់គ្រូពេទ្យនោះប៉ះពាល់ឃ្លែនស៊ីយ៉ាងដូចម្តេចខ្លះ? «នៅខណៈនោះ ឃ្លែនស៊ី បានចេញពីគាំទ្រការរំលូតកូន ទៅរកការប្រឆាំងនឹងការរំលូត

កូន។ គាត់និយាយថា ខ្ញុំភាំងស្មារតីអស់រយៈពេលពីរម៉ោង បន្ទាប់ពីការវះកាត់ ឥឡូវនេះខ្ញុំដឹងហើយថា ការរំលូតកូនគឺជាអំពើខុសឆ្គង គឺវាពិតជាខុសទាំងស្រុង»[៤]។

តើគ្រប់គ្នាពិតជាជឿថា អ្នកជម្ងឺដែលមានអារម្មណ៍ដឹងឈឺ និងចេះស្រវាចាប់ម្រាមដៃនេះ គ្រាន់តែជាផ្នែកបន្ថែមមួយនៃរូបកាយរបស់ម្ដាយវាឬ? តើគេអាចឥវ៉ាដោយជឿជាក់បានដែរឬទេថា នៅពេលដែលវាត្រូវបានដាក់បញ្ចូលទៅក្នុងរូបកាយម្ដាយរបស់វាវិញ វាគួរតែជារឿងស្របច្បាប់ ក្នុងសម្លាប់អ្នកជម្ងឺម្នាក់នោះ ពេលណាក៏បានក្នុងអំឡុងពេលនៅសល់បួនខែទៀតរហូតដល់ពេលវាកើត?

## ភាពខុសៗគ្នានៅគ្រប់ទីកន្លែង

នៅឯសាកលវិទ្យាល័យវេជ្ជសាស្ត្រនៃការ៉ូលីណាខាងត្បូង (Medical University of South Carolina) ប្រសិនបើការពិនិត្យទឹកមូត្ររបស់ស្ត្រីមានគភ៌ណាម្នាក់ឃើញថាមានការប្រើសារធាតុកូកាអ៊ីន នាងអាចត្រូវបានចាប់ខ្លួន ដោយព្រោះការចែកចាយថ្នាំញៀនដល់កុមារ។ ស្រដៀងគ្នានេះ នៅរដ្ឋអ៊ីលីណយ (Illinois) ស្ត្រីមានគភ៌ដែលប្រើថ្នាំខុសច្បាប់អាចត្រូវបានផ្ដន្ទាទោសពីបទ «ផ្ដល់សារធាតុខុសច្បាប់ដល់កុមារ»។ នេះគឺជាការទទួលស្គាល់ដ៏ជាក់ច្បាស់ថា ទារកដែលមិនទាន់កើតគឺជាមនុស្សដែលមានសិទ្ធិ និងសក្ដិសមនឹងទទួលការការពារ សូម្បីតែការពារពីម្ដាយរបស់ខ្លួន។

ទោះជាយ៉ាងណាក្ដី ស្ត្រីដដែលនោះដែលត្រូវបានផ្ដន្ទាទោស និងដាក់ពន្ធនាគារ ដោយព្រោះធ្វើឱ្យមានគ្រោះថ្នាក់ដល់កូនរបស់ខ្លួន ក៏មាន*សេរីភាពក្នុងការរំលូតកូននោះ* ចោលដែរ។ នៅសហរដ្ឋអាមេរិចសព្វថ្ងៃនេះ ការដែលបង្កឱ្យមានគ្រោះថ្នាក់ដល់កូនដែលមិនទាន់កើតនោះគឺជារឿងខុសច្បាប់ ប៉ុន្តែ វាគឺជារឿងស្របច្បាប់ទាំងស្រុងក្នុងការសម្លាប់ទារកនោះ។ នៅគ្រប់កន្លែងបម្រើសុរាក្នុងរដ្ឋអរីហ្គិន (Oregon) ត្រូវបានតម្រូវឱ្យបិទសញ្ញានេះ:



ប្រសិនបើសុរាធ្វើឱ្យមានគ្រោះថ្នាក់ដល់ទារកមិនទាន់កើត តើការរំលូតធ្វើអ្វីដល់ពួកគេវិញ?

សភាសហរដ្ឋអាមេរិច បានបោះឆ្នោតជាឯកច្ឆន្ទ ក្នុងការពន្យារពេលទោសប្រហារជីវិតដល់ស្ត្រីមានគភ៌រហូតទាល់តែនាងសម្រាលកូនហើយ។ សមាជិកសភាគ្រប់រូប សូម្បីតែអ្នកគាំទ្រការរំលូតកូន បានដឹងថា ទារកដែលមិនទាន់កើតនេះ គឺជាមនុស្សម្នាក់ដោយឡែក មិនពាក់ព័ន្ធអ្វីទៅនឹងបទឧក្រិដ្ឋរបស់ម្ដាយឡើយ។ គ្មានការពន្យារពេលប្រហារជីវិតណាមួយត្រូវបានស្នើឡើងសម្រាប់ដុំសាច់បំពង់ក បេះដូង ឬតម្រងនោមរបស់ម្ដាយឡើយ។

រដ្ឋជាច្រើន បានអនុម័តច្បាប់ប្រឆាំងនឹងការធ្វើឃាតទារក ដែលប្រកាសថាវាគឺជាអំពើមនុស្សឃាតសម្រាប់មនុស្សទាំងអស់ លើកលែងតែម្ដាយដែលមានចេតនាយកជីវិតរបស់ទារកដែលមិនទាន់កើត។ ច្បាប់ទាំងនេះសុទ្ធតែជាការបញ្ជាក់យ៉ាងច្បាស់ថា ទារកនោះគឺជាមនុស្ស ។ នៅឆ្នាំ ២០០៤ សភាបានអនុម័តច្បាប់ «ទារកមិនទាន់កើតរងគ្រោះដោយអំពើហិង្សា (Unborn Victims of Violence Act)» ដែលចែងថា អ្នកណាដែល «សម្លាប់ដោយចេតនា ឬប៉ុនប៉ងសម្លាប់ទារកមិនទាន់កើតត្រូវទទួលទោសពីបទមនុស្សឃាតដោយចេតនា ឬប៉ុនប៉ងសម្លាប់មនុស្ស»[៥]។

ចូរពិចារណាអំពីការជំពាក់ជំពិនដ៏ចម្លែកនៃបទដ្ឋានពីរត្រួតគ្នានេះ។ ប្រសិនបើស្ត្រីម្នាក់ដល់ពេលត្រូវទៅរំលូតកូន ប៉ុន្តែនៅតាមផ្លូវទៅកាន់មន្ទីររំលូតកូន កូនរបស់នាងត្រូវបានសម្លាប់ទាំងនៅក្នុងផ្ទៃ អ្នកសម្លាប់ទារកនោះនឹងត្រូវបានផ្ដន្ទាទោសពីបទមនុស្សឃាត។ ប៉ុន្តែបើអំពើមនុស្សឃាតនេះមិនបានកើតឡើងទេ មួយម៉ោងក្រោយមកគ្រូពេទ្យនឹងបានទទួលថ្លៃសម្រាប់ការសម្លាប់ដែលស្របច្បាប់ *គឺទារកដដែលនោះ* (តាមរបៀបមួយដែលប្រហែលជាគួរឱ្យខ្ពើមរអើមជាង)។

ចំពោះទារកនោះ តើមានអ្វីខុសគ្នាចំពោះអ្នកដែលសម្លាប់វា?

## មេរៀនមួយពី លូអ៊ីស ប្រោន (Louise Brown)

ការស្ថិតនៅក្នុងអ្វីមួយ មិនមែនជារឿងមួយដូចជាការស្ថិតនៅជាផ្នែកនៃអ្វីមួយនោះឡើយ។ (រថយន្តមួយមិនមែនជាផ្នែកមួយនៃយានដ្ឋាន ដោយសារតែវាចតនៅទីនោះ នោះឡើយ)។ លូអ៊ីស ប្រោន ជាទារកដំបូងបំផុតដែលត្រូវបានបង្កកំណើតនៅក្នុងបំពង់ពិសោធន៍ ដែលត្រូវបានបង្កកំណើតឡើងនៅពេលដែលមេជីវិត និងស៊ុត

ត្រូវបានភ្ជាប់គ្នានៅលើចាននៃបន្ទប់ពិសោធន៍។ តើទារកនោះក្លាយជាផ្នែកមួយនៃរូបកាយរបស់ម្តាយនាង នៅពេលដែលនាងត្រូវបានគេដាក់ទៅក្នុងផ្ទៃរបស់ម្តាយនាងឬ? គឺដូចជានៅពេលដែលនាងកំពុងស្ថិតនៅលើចាននៃបន្ទប់ពិសោធន៍ដូច្នោះដែរ គឺនាងមិនមែនជាផ្នែកមួយនៃចាននោះឡើយ។

មនុស្សមិនគួរត្រូវគេរើសអើងដោយព្រោះតែទីកន្លែងដែលគេរស់នៅនោះឡើយ។ គ្មានអ្វីមួយនៅពេលកើត ដែលធ្វើឱ្យទារកម្នាក់ខុសគ្នាពីពេលដែលវាមិនទាន់កើតនោះឡើយ។ គ្មានមន្តអាគមណាអាចផ្លាស់ប្តូរលក្ខណៈរបស់ទារក នៅពេលដែលវាចេញពីខាងក្នុងម្តាយរបស់វា មកខាងក្រៅនោះឡើយ។

# ជំពូកទី ៦

# តើរូបភាពទាំងមូលប្រាប់យើងពីអ្វី?

សំណាងអាក្រក់បំផុតរបស់ទារកដែលមិនទាន់កើត គឺដោយសារមិនមានបង្អួចមើលទៅក្នុងស្បូនបាន។ ជោគវាសនារបស់គាត់ គឺនៅក្នុងកណ្តាប់ដៃរបស់អស់អ្នកដែលមិនអាចឃើញគាត់។ ប៉ុន្តែ នៅក្នុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ការនេះបានផ្លាស់ប្តូរទាំងស្រុង។ ទស្សនាវដ្តី *ថាម (Time)* នៅឆ្នាំ ២០០២ និងទស្សនាវដ្តី *នូស្វីគ (Newsweek)* នៅឆ្នាំ ២០០៣ បានសរសេរនៅខាងទំព័រមុខ អំពីភាពអស្ចារ្យនៃរូបភាពរបស់ទារក មិនទាន់កើត[១]។ និងទស្សនាវដ្តី *នូស្វីគ* បានសួរនៅលើទំព័រនោះថា «តើទារកនៅក្នុងផ្ទៃ គួរមានសិទ្ធិដែរឬទេ?» និងរបៀបដែលវិទ្យាសាស្ត្រផ្លាស់ប្តូរការជជែកតស៊ូមតិរបស់ខ្លួន។ រាល់ការជជែកតវ៉ាទាំងអស់ ត្រូវបានទទួលស្គាល់អំពីការពិតនៃក្មេងដែលមិនទាន់កើត។

## អំណាចនៃបច្ចេកវិទ្យាឆ្លុះមើលទារកនៅក្នុងផ្ទៃ

រេបេកា ណានខារ៉ូវ (Rebekah Nancarrow) ទទួលបានការថតឆ្លុះមើលទារកនៅក្នុងផ្ទៃដែលមានតម្លៃ ៨០ ដុល្លារ នៅឯមជ្ឈមណ្ឌលធ្វើមាតាបិតាដោយមានគម្រោង (Planned Parenthood) ប៉ុន្តែមិនបានអនុញ្ញាតិអោយឃើញលទ្ធផល (រូបភាព) ទេ ពីព្រោះគេនិយាយថា «នោះវានឹងធ្វើអោយអ្នកពិបាកខ្លាំងឡើង»។ ដោយមិនអាចដោះស្រាយបាន នាងបានទៅមជ្ឈមណ្ឌលធនធានស្ត្រីមានគភ៌ (Pregnancy Resource Center) នៅកន្លែងនោះនាងអាចថតឆ្លុះដោយឥតគិតថ្លៃ ហើយក៏បានឃើញរូបភាពរបស់ទារកទៀត។ នាងបាននិយាយថា «បើសិនជាខ្ញុំមិនមានឃើញរូបភាពនោះទេខ្ញុំប្រហែល ជា រំលូត កូន នោះ ចោល ហើយ។ ប៉ុន្តែ រូបភាព នោះ បាន បញ្ជាក់ អះ អាង ១០០% ឱ្យខ្ញុំដឹងច្បាស់ថា មានជីវិតមួយនៅក្នុងខ្ញុំ គឺមិនមែនជាជាលិកានិងដុំមូលមួយទេ»[២]។

យោងតាមលោក ថូម៉ាស់ ក្លេសនើរ (Thomas Glessner) បានឱ្យដឹងថា «មុនពេល ដែល មាន បច្ចេកវិទ្យា ពិនិត្យ មើល រូបភាព មជ្ឈមណ្ឌល ស្ត្រី មាន គភ៌ បាន រាយ

ការណ៍ឱ្យដឹងថា ស្ត្រីដែលមានគំនិត រំលូតកូន ដែលបានមកដើម្បីពិនិត្យផ្ទៃពោះនិង ប្រឹក្សាយោបល់គឺមានប្រហែលជា ២០-៣០% សម្រេចចិត្តទុកកូនរបស់ខ្លួន។ប៉ុន្តែ នៅពេលដែល មជ្ឈមណ្ឌលមានម៉ាស៊ីនថតឆ្លុះមើលទារកក្នុងផ្ទៃ របាយការណ៍បាន ឱ្យដឹងថា ស្ត្រីដែលសម្រេចចិត្តទុកកូន (មិនរំលូត) កើនដល់ ៨០-៩០%»[៣]។

អូឌ្រី ស្តោត (Audrey Stout) ជាគិលានុបដ្ឋាយិកាបានប្រាប់ខ្ញុំអំពីការដែល នាងបានពិនិត្យមើលរូបភាព។ នេះគឺជាពេលដ៏ជាក់លាក់ដែលក្មេងបើកឬបិទមាត់ របស់ខ្លួនញ្ញើក ដេកផ្អែកដូចដេកនៅលើកៅអីមាត់សមុទ្រ លាតជើងដ៏តូចរបស់ខ្លួន។ ម្តាយអាចមើលឃើញកូននោះ»។

នៅពេលដែល អូឌ្រី ពិនិត្យរួចហើយ នាងសួរទៅស្ត្រីជាម្តាយនោះថា តើនាង មានគម្រោងយ៉ាងណា «នាងបានឆ្លើយថា ខ្ញុំនឹងទុកកូននោះអោយកើត។ ខ្ញុំក៏សួរ នាងទៀតថា បើសិនជាការថតឆ្លុះនេះធ្វើឱ្យមានភាពខុសប្លែក។ នាងឆ្លើយថា «នេះ ជាជោគជ័យមួយ ។ ខ្ញុំគ្រាន់តែមកពិនិត្យ ដើម្បីបញ្ជាក់ថាខ្ញុំមាន គភ៌ ឬ គ្មានដើម្បី ឱ្យខ្ញុំអាចទៅរំលូតចោល..»[៤]។

មានរឿងរ៉ាវបែបនេះរាប់ពាន់ចេញមកពីមជ្ឈមណ្ឌលសម្រាប់ស្ត្រីមានគភ៌ ចាប់ តាំងពីពេលដែលមានម៉ាស៊ីនថតឆ្លុះមក។ តាមប្រព័ន្ធ អ៊ីនធឺណែតបានបង្ហាញអោយ ឃើញ រូបភាពដ៏អស្ចារ្យ គឺមានរូបភាពខ្លះញញឹម ស្ទាបសន្ទឹងដៃជើង និងដេក[៥]។ ប៉ុន្តែ នៅតែមានការបដិសេធយ៉ាងខ្លាំងក្លា។ នៅពេលដែលខ្ញុំបង្ហាញរូបភាពទារកនៅ ក្នុងស្បូនដែលទើបបាន ៨សប្តាហ៍ ដល់អ្នកគាំទ្រការជ្រើសរើសដែលជាសិស្សរៀនចប់ ថ្នាក់មហាវិទ្យាល័យ នាងបានសួរខ្ញុំថា «តើអ្នកគិតថា អ្នកនឹងធ្វើអោយមនុស្សគ្រប់គ្នា ឆ្គួតជាមួយអ្នក ជាមួយនឹងរូបភាពបោកប្រាស់នេះឬ?»។ ខ្ញុំប្រាប់ទៅនាងវិញថាអ្នក គួរទៅអានសៀវភៅសិក្សានៅ សាលាវេជ្ជសាស្ត្រនៃសាកលវិទ្យាល័យហាវើឌ (Harvard University Medical School) មហាវិទ្យាល័យ ពេទ្យ គឺ ទស្សនាវដ្តី *ជីវិត*[៦] ឬសៀវភៅ របស់លោកនីលសិន *ទារកកើតហើយ*[៧] *(A Child Is Born)* នោះអ្នកនឹងឃើញរូបភាព ដូចនេះបេះបិទ។ នាងមិនចង់ស្តាប់ទេ។ ហេតុអ្វី? ពីព្រោះនាងជានិយាយថា«នោះ ពិតជារូបទារកម្នាក់មែន ហើយដោយសារតែខ្ញុំមិនចង់ជឿថា ការរំលូតកូនគឺជាការ ដែល សម្លាប់ក្មេងនោះ ខ្ញុំក៏ បដិសេធថានោះ មិនមែន ជា រូប ភាព ពិតប្រាកដតែ ម្តង ទៅ»។

## អ្វីដែលនៅតែបន្តចន្លុលបន្ទាញ

ខ្សែភាពយន្តមួយដែលមានចំណងជើងថា «អំណោយនៃការជ្រើសរើស (The Gift of Choice)» បានប្រកាសថា ទារកដែលមិនទាន់កើតគឺជា «ភាពពិតប្រាកដនៃមនុស្សម្នាក់នៅថ្ងៃអនាគត» ប៉ុន្តែមានអ្វីដែលនៅសល់បន្ទាប់ពីការ រំលូតកូនដែលនៅតូចនោះ តែមានរូបរាងពិតប្រាកដហើយដូចជា ដៃ ជើង បាតដៃ បាតជើងដងខ្លួននិងក្បាល។រូបរាងនេះនៅតែបង្ហាញពីពេលចុងក្រោយមិនមែនជាអ្វីមួយដែលអាចមានជីវិតទេ ប៉ុន្តែជាជីវិតមួយដ៏ពិតប្រាកដ។ បើសិនជាអ្នកមិនជឿទេ សូមពិនិត្យមើលអ្វីនៅសល់ពីការរំលូត[៨]។ បើសិនជាអ្នកមិនហ៊ានមើល ចូរសួរទៅខ្លួនឯងថា តើមកពីមូលហេតុអ្វី?បើសិននេះគ្រាន់តែជា ជាលិកា មិនមែនជាផ្នែកតូចៗរបស់ទារក វាមិនមែនជាអ្វីដែលគួរអោយខ្លាចមើលទេ តើមែនទេ?

នៅក្នុងសៀវភៅក្បួនរបស់បណ្ឌិត វ៉ារិន ហ៊ើន (Warren Hern) អំពីការ រំលូតកូន បាននិយាយឱ្យដឹងថា «ប្រើកន្ត្រៃកោងវែងដើម្បីកាត់ចុងម្ខាង (អាចជាក្បាល) ចេញ និង បំបែកគភ៌នោះជាតូចៗ[៩]។ គភ៌នោះត្រូវមានក្បាល ទើបគេអាចកាត់ក្បាលចេញបានហើយត្រូវមានដងខ្លួន ទើបគេអាចបំបែកជាចំណែកតូចៗបាន។ ដុំរូបរាងនិងជាលិកាឈាមមិនអាចកាត់ក្បាលចេញឬបំបែកជាបំណែកៗបានទេ។

ហេតុអ្វីបានជាមនុស្សតែម្នាក់ដែលមើលភាពយន្តរឿងដែលសម្លាប់បង្ហូរឈាមគ្នា និងរឿងវះពិនិត្យសពដែលគួរឱ្យខ្ពើម បែរជាមិនចង់មើលរូបភាព រំលូតកូនដូច្នេះ? អ្នកគាំទ្រការជ្រើសរើសបាននិយាយពីរូបភាព រំលូតកូនដោយទទួលស្គាល់ថា:

> មានអ្នកគាំទ្រការជ្រើសរើសជាច្រើន បានតស៊ូមតិថា រូបភាពនេះបំផុសបំផុលឱ្យមានចលនាផ្សព្វផ្សាយឡើង។ មានភាពត្រឹមត្រូវមួយនៅក្នុងចំណោមយើងចូរយើងសម្តែងភាពស្មោះត្រង់រូបភាពដែល គួរ ឱ្យ ស្អប់ ខ្ពើម នោះ គឺជា កម្ម សិទ្ធិរបស់ អ្នក គាំទ្រ ជីវិត ហើយវាតំណាងឱ្យភាពឃោរឃៅនៃការស្រមើស្រមៃដែលអាចនឹងផ្តល់ឱកាសខ្លះធ្វើអោយពិភពលោករបស់យើងធ្លាក់ចូលទៅក្នុងភាពភ័យខ្លាចនិងក្រោមការគាបសង្កត់។«មនុស្សដូចជាពួកយើង» ចាត់ទុករូបភាពនោះថាជារូបភាពអាសអាភាសរបស់ចលនាគាំទ្រជីវិត។ ប៉ុន្តែចលនាស្ត្រីនិយមគេជឿថា អ្វីដែលប្រសើរបំផុតនោះ គឺអាស្រ័យនៅលើអ្វីដែលពិតប្រាកដ។ ក្នុង

ខណៈពេលដែលរូបភាពនោះ បង្ហាញពីភាពឃោរឃៅដល់ការស្លាប់របស់គភ៌ គឺគាំទ្រដល់ការខិតខំតស៊ូរបស់អ្នកគាំទ្រជីវិត។ រូបភាពនោះមិនមែនជា ហេតុនាំឱ្យមានការជំទាស់គ្នានោះទេ ប៉ុន្តែវាជាការពិតខាងជីវសាស្ត្រ។ យើងដឹងពីការនេះ[១០]។

## សិទ្ធិដើម្បីស្ថិតនៅក្នុងភាពល្ងង់ខ្លៅ

នៅពេលដែលតំណាងអ្នកគាំទ្រជីវិតនិយាយក្នុងកម្មវិធីទូរទស្សន៍អំពីការរំលូតកូនគេបានខឹងគាត់យ៉ាងខ្លាំង។នៅក្នុងកម្មវិធី *ព័ត៌មានពេលល្ងាចរបស់ទូរទស្សន៍ស៊ីប៊ីអែស (CBS Evening News)* អ្នកសារព័ត៌មានបានប្រកាសថាការជជែកវែកញែកអំពីការរំលូតកូនបានឈានដល់ដំណាក់កាលនៃភាព «គ្មានខ្លឹមសារថ្មីមួយ»។ ប៉ុន្តែវាចម្លែកណាស់ ដែលមិនមានអ្នកណាខឹងថាទារកទាំងនោះត្រូវគេសម្លាប់ទេ។ គឺមានតែអស់អ្នកដែលមានភាពក្លាហានទេ ដែលហ៊ានប្រាប់ឱ្យគេដឹងថាទារកទាំងនោះកំពុងត្រូវគេសម្លាប់។សំណួរដែលយើងគួរតែសួរនោះគឺមិនមែន «ហេតុអ្វីបានជាអ្នកគាំទ្រជីវិតបង្ហាញរូបភាពទាំងនេះទេ?»។ ប៉ុន្តែ «ហេតុអ្វីបានជាមនុស្សគ្រប់គ្នាប្រឆាំងនឹងអ្វីដែលបានបង្ហាញនៅក្នុងរូបភាពទាំងនេះ?»។ ការបារម្ភពិតប្រាកដអំពីរូបភាពនៃទារកដែលមិនទាន់កើតនោះគឺមិនមែនជាអ្វីដែលគួរឱ្យខ្ពើមនោះទេប៉ុន្តែពួកគេកំពុងតែបង្ហាញភាពពិតប្រាកដនៃជំហររបស់អ្នកគាំទ្រជីវិត។ រូបភាពកូនដែលនៅក្នុងស្បូន និងរូបភាព មិនមែនគួរឱ្យខ្ពើមនោះទេ ប៉ុន្តែជារូបមួយដ៏ស្រស់ស្អាត និងគួរឱ្យស្រឡាញ់។ដូច្នេះ តើក្រុមអ្នកគាំទ្រការជ្រើសរើសខិតខំតស៊ូមតិដើម្បីស្វាគមន៍រូបភាពទាំងនេះឬ?មិនមែនទេ។ អង្គការរក្សាសិទ្ធិការរំលូតកូន បាននិយាយថា រូបភាព គឺជាអាវុធមួយនៅក្នុងកណ្តាប់ដៃរបស់ចលនាគាំទ្រជីវិត [១១]។ បច្ចុប្បន្ននេះពេលខ្លះនៅតាមក្លីនិច និងអ្នកជំនួញ បានផ្តល់នូវរូបភាព3D (ជួនកាលហៅថា 4D) យ៉ាងច្បាស់របស់ទារកដែលមិនទាន់កើត កំពុងតែញញឹម កំពុងកណ្តាស់ និងពត់ពែនខ្លួន (សូមមើលរូបភាពរបស់ទារកមិនទាន់កើតនៅទំព័រខាងក្រោយសៀវភៅនេះ)។ នៅក្នុងការពិភាក្សារបស់ ភីប៊ីអែស មានសមាជិកក្នុងក្រុមម្នាក់បានបានប្រកាសថា រូបភាពប្រភេទនោះបានឆ្លុះបញ្ចាំងពី «ការគិតមិនត្រឹមត្រូវមួយអំពីទារក»[១២]។ សូមកត់សំគាល់ពាក្យនេះ «ទារក»[១២]។ បច្ចេកវិទ្យារូបភាពនេះបានជួយគាំទ្រដល់ការខិតខំតស៊ូរបស់អ្នកគាំទ្រជីវិត តើនោះជាទារក មែនឬមិនមែន? ពេលនោះមនុស្សចាប់ផ្តើមនិយាយថា «តើអ្នកកំពុងតែនិយាយអំពីអ្វី? មែនហើយ នោះគឺជា ទារក ចូរគ្រាន់តែ*មើល*ចុះ!»។

## យកឈ្នះការបដិសេធ

របបប្រល័យពូជសាសន៍របស់ពួកណាស៊ីអាល្លឺម៉ង់ អាក្រក់ខ្លាំងណាស់ គឺមិនអាចរកពាក្យណាមកពិពណ៌នាបានឡើយ។ការពិពណ៌នាអំពីជំរំមរណៈរបស់ពួកណាស៊ីអាល្លឺម៉ង់ ត្រូវបានបោះពុម្ពផ្សាយជាយូរមកហើយនៅក្នុងសារព័ត៌មានអាមេរិក ប៉ុន្តែនៅពេលដែល សារព័ត៌មាននេះចាប់ផ្តើមបោះពុម្ព រូបភាពមនុស្សដែល ត្រូវគេសម្លាប់ ទីបំផុត សាធារណៈជនអាមេរិកបានភ្ញាក់ខ្លួនឡើង។ បើសិនជាមិនមានរូបភាពនេះ នៅសព្វថ្ងៃនេះប្រហែលជាមនុស្សភាគច្រើនមិនជឿថាមានរបបប្រល័យពូជសាសន៍ទេ។

ខ្ញុំបានទៅលេងនៅទីធ្លានៃមហាវិទ្យាល័យមួយ ដែលពួកអ្នកគាំទ្រជីវិតបានដាក់តាំងបង្ហាញនូវទារកដែលត្រូវបានរំលូតជាមួយនឹងការបង្ហាញជនរងគ្រោះដែលត្រូវគេសម្លាប់នៅជំរំរបស់ពួកណាស៊ី វាលពិឃាត រឿងទាសករនៅអាមេរិក និងរឿងប្រវត្តិសាស្ត្រ ដ៏ យោរយៅ ជា ច្រើន ទៀត។ ស្លាក សញ្ញា ជាមួយ នឹង ការ ព្រមាន អំពី រូបភាពត្រូវ បានបិទបង្ហាញយ៉ាងច្បាស់ដូច្នេះ មនុស្សទាំងអស់អាចជ្រើសរើសដើម្បីមើល បាន។ ខ្ញុំ សូម ធ្វើ សាក្សី ថា វា មាន ប្រសិទ្ធភាព យ៉ាង ខ្លាំង ចំពោះ និស្សិត និង សាស្ត្រាចារ្យ រួមទាំងអស់អ្នកដែលមិនចង់ជឿលើអ្វីដែលពួកគេកំពុងតែមើលផង។

ក្រុមអ្នក ការពារ សិទ្ធិ សត្វ បាន និយាយ ថា ដើម្បី បង្ហាញ ពី ករណី របស់ ពួកគេ គេត្រូវតែបង្ហាញរូបភាពណាដែលអាក្រក់ៗ ដូចជាកូនភេសមុទ្រត្រូវគេយកដំបងវាយ សម្លាប់ ។ បើសិនជា មានកន្លែង ដើម្បី មើលរូបភាពបែប នោះ តើមិនមាន កន្លែង ដើម្បីមើលរូបភាពទារកដែលត្រូវគេរំលូតទេឬ? ហើយបើសិនជាការរំលូត មិនមែនជាការសម្លាប់ទារកទេនោះ ហេតុអ្វីបានជារូបភាពទាំងនេះធ្វើឱ្យរំខានដល់ពួកគេ?

តើដំណោះស្រាយចំពោះរបបប្រល័យពូជសាសន៍ គឺត្រូវហាមប្រាមមិនឱ្យបញ្ចាំង រូបភាពគួរអោយខ្ពើមទាំងនោះឬ? ឬដំណោះស្រាយ ដោយបញ្ឈប់ការសម្លាប់?

តើដំណោះស្រាយចំពោះការរំលូតកូន គឺត្រូវកម្ទេចរូបភាពទារកស្លាប់ទាំងអស់ចោលឬ? ឬត្រូវបញ្ចប់សកម្មភាពដែលធ្វើឱ្យទារកស្លាប់?

# ជំពូកទី ៧
# តើអ្វីដែលធ្វើជីវិតរបស់មនុស្សម្នាក់"មានតម្លៃ"?

បណ្ឌិត វីលៀម ហារីសុន (William Harrison) ជា អ្នកគាំទ្រ ការ ជ្រើស រើស បាននិយាយថា «បញ្ហាពិតប្រាកដនៃការជជែកយកឈ្នះយកចាញ់នៅពេលបច្ចុប្បន្ននេះ មិនមែនអំពីនៅពេលជីវិតដែលចាប់ផ្ដើមនោះទេ ប៉ុន្តែគឺសីលធម៌នៃជីវិតមានតម្លៃ»[១]។ តើនរណាជាអ្នកដែលកំណត់ថា ជីវិតមួយមានតម្លៃ ហើយជីវិតមួយទៀតគ្មានតម្លៃនោះ? ចម្លើយនោះគឺតែងតែយ៉ាងដូច្នេះ ៖ មនុស្សដែលមានអំណាច អ្នកមានទ្រព្យសម្បត្តិ ជាអ្នកសម្រេចថា ជីវិតរបស់មនុស្សដែលខ្សោយជាង និងក្រជាងខ្លួននោះ មានតម្លៃ ឬមិនមាន។

## បទដ្ឋានពីរត្រួតគ្នា

លោក ភីធើរ ស៊ីងង៉ើរ (Peter Singer) ជាសាស្ត្រាចារ្យផ្នែកសីលធម៌នៅសាកលវិទ្យាល័យ ព្រីនស្ដិន (Princeton) បានសរសេរថា «ជីវិតរបស់គភ៌ មិនមានតម្លៃលើសជាង ជីវិតសត្វដែលនៅក្នុងកម្រិតស្រដៀងគ្នា ដូចជា ញាណ សម្បជញ្ញៈនិងសមត្ថភាពក្នុងការមាន អារម្មណ៍ ។ល។»[២] (មានឪពុកម្ដាយជាច្រើនបានចំណាយលុយឱ្យកូនរបស់ពួកគេចូលរៀនជាមួយប្រហែលជាពួកគេគិតថា លោកស៊ីងង៉ើរនោះក៏ជឿថា មានហេតុផលខាងសីលធម៌ ដើម្បីសម្លាប់មនុស្សចាស់ដែរ)។

លោក ជីម នូហល (Jim Newhall) អ្នកជំនាញខាងរំលូតកូន នៅ ផតឡិន (Portland) ក្នុងរដ្ឋអរីហ្គិន (Oregon) បាននិយាយថា «មិនមែនមនុស្សគ្រប់គ្នាត្រូវតែកើតមកនោះទេ។ ខ្ញុំជឿថា សម្រាប់ទារកម្នាក់ ជីវិតចាប់ផ្ដើមនៅពេលដែលម្ដាយរបស់គេត្រូវការគេ»[៣]។ ដូច្នេះ តើជីវិតរបស់មនុស្សម្នាក់ ក្លាយជាជីវិតពិតប្រាកដ តែនៅពេលដែលមនុស្សផ្សេងឱ្យតម្លៃដល់គេមែនឬ?

នៅឆ្នាំ ១៩៧៣ ការសម្រេចក្ដីក្នុងករណី *រ៉ូ វី វ៉េដ (Roe v. Wade)* តុលាការកំពូលបានសួរថា តើទារកមិនទាន់កើតពិតជាមានជីវិតដែលមានអត្ថន័យឬ? ប៉ុន្តែ*តើមានអត្ថន័យចំពោះអ្នកណា?*។ តើមិនមែនគ្រប់គ្នាដែលជាមនុស្សចាត់ទុកថា ជីវិត

មានអត្ថន័យ ក្នុងពេលដែលខ្លួននៅក្នុងផ្ទៃម្តាយរបស់ខ្លួនមែនទេ..បើសិនជាគេត្រូវម្តាយរំលូតចោល ឥឡូវនេះគេក៏គ្មានជីវិតរស់នៅដែរ?

ពួកស្បែកស បានចាត់ទុកថា ពួកស្បែកខ្មៅ ជាមនុស្សមិនពេញជាមនុស្សទេ។ បុរសចាត់ទុកថា ស្ត្រីមានសិទ្ធិតិចតួចប៉ុណ្ណោះ។ ពួកណាស៊ី (Nazis) ចាត់ទុកថា ជីវិតរបស់ជនជាតិយូដា គ្មានអត្ថន័យទេ។ ឥឡូវនេះ មនុស្សដែលមានអំណាច ចាត់ទុកថា មនុស្សដែលគ្មានអំណាច អ្នកក្រ មិនមានអត្ថន័យគ្រប់គ្រាន់ដើម្បីទទួលសិទ្ធិរបស់ខ្លួនទេ។

ភាពជាបុគ្គលម្នាក់មិនមែនជាអ្វីមួយដែលត្រូវបានផ្តល់ឱ្យដល់មនុស្សដោយក្រុមសាស្ត្រាចារ្យនៃក្រុមអាយវី លីក(Ivy League) ដែលចង់កម្ចាត់សង្គមមួយដែលមានសុទ្ធតែមនុស្សឥតបានការនោះឡើយ។ ភាពជាបុគ្គល មានតម្លៃជាប់មកជាមួយ ដែលមកពីការដែលគេជាសមាជិកម្នាក់នៃមនុស្សជាតិ។ នៅក្នុងព្រះគម្ពីរនិយាយថា មនុស្សគឺជាផ្នែកមួយ ដែលត្រូវបានបង្កើតឡើងតាមរូបអង្គរបស់ព្រះជាម្ចាស់។

## តើវិទ្យាសាស្ត្រនិយាយអ្វីអំពី "អត្ថន័យ"?

តើអ្វីដែលជាធាតុផ្សំនៃជីវិត «មានអត្ថន័យ»? អំណះអំណាងការពិតខាងវិទ្យាសាស្ត្រ បានប្រាប់ថា ទារកចេះគិតតាំងពីនៅក្នុងផ្ទៃ(មិនទាន់កើត)ម្ល៉េះ។ សារព័ត៌មានមួយឈ្មោះ អាសូស៊ីអេធីត ប្រេស (Associated Press) បានរាយការណ៍ថា មានការសិក្សាមួយបង្ហាញឱ្យឃើញថា «ទារកចាប់ផ្តើម រៀនភាសារបស់ខ្លួនតាំងពីមុនពេលដែលខ្លួនកើតមកម្ល៉េះ»។ មានការសិក្សាជាច្រើនបង្ហាញអោយឃើញថា ពេលនៅក្នុងផ្ទៃម្តាយរបស់ខ្លួន «ទារកបានឮ ដឹង ស្តាប់ និងរៀនការខ្លះៗផងដែរ»[៤]។

សារព័ត៌មាន នូស្វ៊ីគ (Newsweek) សរសេរថា «ជីវិតដែលនៅក្នុងផ្ទៃ តំណាងពី ព្រំដែនបន្ទាប់មួយទៀត សម្រាប់ការសិក្សានៃការអភិវឌ្ឍន៍របស់មនុស្ស ហើយការសិក្សាស្វែងរកដំបូងៗនៃ ព្រំដែនបន្ទាប់...បាននាំមកនូវការសិក្សាស្វែងរកដ៏ភ្ញាក់ផ្អើលមួយ»[៥]។ មានអត្ថបទមួយសរសេរថា «ទារកនៅក្នុងផ្ទៃអាចស្គាល់ មានសតិសម្បជញ្ញៈ និងមានអារម្មណ៍»។ អត្ថបទនោះក៏បានសរសេរផងដែរថា វិទ្យាសាស្ត្រ បានកំណត់អារម្មណ៍របស់ទារកបាននៅក្នុងត្រីមាសទីពីរ[៦]។ សមត្ថភាពដ៏អស្ចារ្យរបស់ទារកដែលមិនទាន់កើត ត្រូវបានចងក្រងជាឯកសារយ៉ាងត្រឹមត្រូវ ដោយការសិក្សារបស់វិទ្យាសាស្ត្រអស់រយៈពេលច្រើនឆ្នាំ[៧]។

នៅដើមត្រីមាសទីពីរ ទារកចាប់ផ្តើមចេះយកដៃមកបាំងភ្នែករបស់ខ្លួនពីពន្លឺ ដែល ចាំងឆ្លងកាត់រាងកាយរបស់ ម្តាយ ។«ទារកអាច ប្រតិកម្មទៅនឹងរលក សម្លេង ខ្លាំង ឬខ្សោយ»[៨]។ ចេះស្តាប់តន្ត្រី ហើយចេះយកដៃមកបិទត្រចៀក នៅពេលដែល ឮសម្លេងខ្លាំងមកពីខាងក្រៅ។ នៅសប្តាហ៍ទី ១៧ ទារកចាប់ផ្តើមធ្វើចលនាភ្នែករបស់ខ្លួនយ៉ាងឆាប់រហ័ស ចេះដេក គឺមិនមែនគ្រាន់តែដេកទេ គេក៏ចេះយល់សប្តិដែរ[៩]។តើយើងអាចនិយាយថា តើមនុស្សម្នាក់អាចយល់សប្តិ ទាំងខ្លួនមិនទាន់ចេះគិតបានដែរ ឬទេ?។

ដោយមិនមានសង្ស័យទេថា ការរំលូតកូន ចាប់ពីត្រីមាសទីពីរឡើងទៅបាន សម្លាប់មនុស្សម្នាក់ដែលចេះគិត។ នៅចុងត្រីមាសទីពីរ «ខួរក្បាល សរសៃប្រសាទ គឺដូចជាទារកដែលទើបនឹងកើតដូច្នោះដែរ»[១០]។ មិនយល់ទាល់តែសោះថាមនុស្សគ្រប់គ្នាបានដឹងអំពីការពិតអាចទៅការពារ ច្បាប់ក្នុងពេលបច្ចុប្បន្ន ដែលអនុញ្ញាតិឱ្យរំលូតកូននៅក្នុងត្រីមាសទីពីរនិងត្រីមាសទីបីនោះ។ ប៉ុន្តែ អ្នកគាំទ្រការជ្រើសរើសនៅតែបានខំតស៊ូមតិដោយមិនព្រមចុះចាញ់ដើម្បីការពារការរំលូតកូនប្រភេទនេះ។

ប៉ុន្តែ តើការរំលូតកូនដែលទើបនឹងចាប់កំណើត (៣ខែចុះ) ប្រសើរជាងការរំលូតកូនដែលមានអាយុចាប់ពី៣ខែឡើងមែនទេ? ទោះបីក្នុករណីរំលូតកូនចាប់ពី៣ខែចុះ ដែលបានសម្លាប់ជីវិតមុនពេលដែលទារកចាប់ផ្តើមចេះគិត សេចក្តីស្លាប់នោះគឺជាការពិត និងជាសារៈសំខាន់។ ព្រោះបើធ្វើយ៉ាងនេះ ទារកដែលមានជីវិតនោះនឹងមិនអាចមានឈ្មោះមានគ្រួសារ និងជីវិតបានទេ។

## សីលធម៌ខុសឆ្គង

លោក ស៊ីងង៉េរ (Singer) និយាយថា «បើសិនជាយើងប្រៀបធៀបយ៉ាងផ្ចិតផ្ចង់ រវាងទារកម្នាក់ ជាមួយនឹងសត្វ (ឧទាហរណ៍ៈ ឆ្កែ ជ្រូកជាញឹកញាប់យើងតែងតែឃើញថា សត្វមានសត្ថភាពជាងទារកមនុស្ស ទាំងភាពជាក់ស្តែង និងសក្តានុពលចេះគិត មានសតិសម្បជញ្ញៈ ទំនាក់ទំនង និងអ្វីៗផ្សេងទៀត ដែលគួរតែត្រូវបានពិចារណាភាពត្រឹមត្រូវខាងសីលធម៌»[១១]។

ស៊ីងង៉េរ ក៏បាននិយាយផងដែរថា មនុស្សម្នាក់ដែលមានតម្លៃ គឺអាស្រ័យលើភាពមានប្រយោជន៍របស់អ្នកនោះ ចំពោះអ្នកផ្សេងទៀត៖ «បើសិនជា សេចក្តីស្លាប់របស់ទារកពិការម្នាក់ នាំទៅរកការចាប់កំណើតរបស់ទារកម្នាក់ផ្សេងទៀត ដែលគិតថាជាអ្នកដែលមានជីវិតដ៏រីករាយ នោះវាមានសុភមង្គលប្រសើរជាងដែលទារក

ពិការនោះកើតមក។ ការបាត់បង់ជីវិតរីករាយរបស់ទារកទីមួយគឺ មិនសំខាន់ដូចជាការដែលបានទទួលនូវជីវិតដ៏មានសុភមង្គលជាងរបស់ទារកទីពីរទេ។ ដូច្នេះ បើសិនជាការសម្លាប់ ទារកពិការ មិនមានផលអាក្រក់ដល់អ្នកផ្សេងទេ ដូច្នេះ ចំពោះទស្សនៈទូទៅ ការដែលសម្លាប់ទារកពិការនោះមិនមែនជារឿងខុសទេ»[១២]។

នៅពេលដែល ស៊ីងង៉េរ ទៅបង្រៀននៅ ព្រីនស្តុន គាត់ត្រូវបានក្រុមដែលមានឈ្មោះថា មិនទាន់ស្លាប់ទេ (Not Dead Yet) ដែលជាក្រុមការពារសិទ្ធិមនុស្សពិការពីកំណើត បាននាំគ្នាមកដើម្បីធ្វើការប្រឆាំងនឹងគាត់។ ពួកគេប្រឆាំងនឹង អ្វីដែលស៊ីងង៉េរ បាននិយាយ នៅក្នុងសៀវភៅរបស់គាត់ថា ច្បាប់គួរតែអនុញ្ញាតិឱ្យសម្លាប់ទារកដែលពិការក៏ដូចជាក្មេងៗ និងមនុស្សចាស់ណាដែល មានភាពពិការយ៉ាងធ្ងន់ធ្ងរ។

គំនិតចម្បងរបស់ ក្រុមអ្នកគាំទ្រការជ្រើសរើសចាប់ផ្ដើមជាមួយ ការរំលូតកូន ប៉ុន្តែវាមិនបានឈប់តែត្រឹមនោះទេ ។ នៅពេលណាដែលទទួលយល់ព្រមឱ្យមានការសម្លាប់ក្មេងដែលមិនទាន់កើត គឺមិនមានមនុស្សទន់ទាប (ខ្សោយ ក្រ) និង ជនងាយរងគ្រោះណាមួយរស់នៅដោយសុវត្ថិភាពទេ។ តើជីវិតរបស់មនុស្សពិការមានតម្លៃដែរឬទេ? ចុះចំណែកមនុស្សចាស់វិញ? បើសិនជាអស់អ្នកដែលមិនអាចគិត (ពិការ) មិនសក្តិសមនឹងរស់នៅ ចុះអស់អ្នកដែលគិតមិនបានត្រឹមត្រូវវិញយ៉ាងណាដែរ?

បណ្ឌិត ឆាលស៍ ហាតស៊ន (Charles Hartshorne) នៃ សាកលវិទ្យា ល័យរដ្ឋតិចសាស់(University of Texas) បានយល់ស្របទៅនឹង ក្រមសីលធម៌របស់ ស៊ីងង៉េរ ថា «ជាការពិតណាស់ ទារកម្នាក់មិនទាន់ក្លាយជាមនុស្សពេញលក្ខណៈទេ...ខ្ញុំមានការអាណិតដល់គំនិតដែលថា ទារកឃាតគ្រាន់តែជាឃាតកម្មក្នុងរូបភាពមួយផ្សេងទៀត។ មនុស្សដែល ចេះគិត និងចេះធ្វើអ្វីៗទាំងអស់ហើយ មានសិទ្ធច្រើនជាងទារក»[១៣]។

## តើមនុស្សទាំងអស់មានសុវត្ថិភាពឬ?

លោក ដាវិឌ ប៊ូនីន (David Boonin) និយាយថា ការរំលូតកូនគឺ «អាចទិតៀនបានបើនិយាយពីសីលធម៌» ប៉ុន្តែ «អាចអនុញ្ញាតបានបើនិយាយពីសីលធម៌»។ គាត់និយាយថា ការរំលូតកូន អាចអនុញ្ញាតឱ្យធ្វើបាន ពីព្រោះ ការរំលូតកូនអាចជាសក្តានុពលនាំមកនូវ «សុភមង្គលជាទូទៅ»[១៤]។ ប៊ូនីន ក៏ដូចជា ស៊ីងង៉េរ ដែរ គាត់បានមើលរំលងការពិតដែលថា គំនិតនៃសុភមង្គល (ជាការវាស់វែងដោយ ភាពស្រណុកស្រួល និងការបំបាត់ភាពតប់ប្រមល់ និងរួចផុតពីបញ្ហាថវិកា) បានដោយសារការសម្លាប់ជីវិតរបស់

អ្នកផ្សេង គឺមិនត្រឹមតែ មនុស្សដែលមិនទាន់កើតតែប៉ុណ្ណោះទេ។ នៅពេលដែលអ្វីមួយត្រូវបានចាត់ទុកថា អាចអនុញ្ញាតបានបើនិយាយពីសីលធម៌ ពីព្រោះតែវាអាចនាំមកនូវសុភមង្គល គឺមិនមានអ្វីដែលអាចស្មើរនឹងការនោះទេ។

អាថ៌កំបាំងដែលស្ថិតនៅពីក្រោមនៃការសម្រេចចិត្ត នៃអ្វីដែលជាធាតុផ្សំដើម្បីធ្វើឱ្យមានជីវិតមានតម្លៃ គឺជាអ្នកដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន។ តើមនុស្សពិការខាងគំនិត និង រាងកាយ ឬមនុស្សដែលគ្មានឱកាស មានប្រយោជន៍ដល់មនុស្សដែលមានសុខភាពល្អ មានកម្លាំង ឬក៏ពួកគេជាបន្ទុកសម្រាប់យើង? ដូចជាក្រុមដែលគាំទ្រសិទ្ធិស្ត្រីមួយក្រុមចង្អុលបង្ហាញថា បើសិនជាក្មេងដែលមិនទាន់កើតមិនមានសុវត្ថិភាពទេ គឺគ្មានមនុស្សណាម្នាក់រស់នៅដោយសុវត្ថិភាពឡើយ៖

> បើសិនជាយើង យកជីវិតក្រុមមនុស្សដែលមានលក្ខណៈដូចគ្នាដាក់នៅកន្លែងមួយក្រៅពីការ ការពារដោយច្បាប់នោះយើងបានកាត់បន្ថយករណីនៃការរើសអើងប្រឆាំងនឹងមនុស្សផ្សេងៗគ្នាហើយ។ កុមារ មានសិទ្ធិស្របច្បាប់ រាល់ទង្វើ ដែលប្រព្រឹត្តិចំពោះពួកគេ គឺថា ពួកគេបានក្លាយជាសមាជិកនៃក្រុមមួយហើយមានសិទ្ធិគ្រប់គ្រាន់ក្នុងការក្លាយជាសមាជិកនៃសហគមន៍មនុស្ស ដោយមិន គិតពីជាតិសាសន៍ ភេទ ពិការភាព អាយុកម្រិតនៃការអភិវឌ្ឍន៍ កម្រិតនៃការពឹងលើខ្លួនឯង ទីកន្លែងកំណើត ឬចំនួនទ្រព្យសម្បត្តិដែលពួកគេមានទេ»[១៥]។

ការរំលូតកូន បានដាក់យើងនៅលើប្រធានបទដ៏គ្រោះថ្នាក់មួយ។ យើងគួរតែភ្ញាក់ស្មារតីឡើងវិញ ហើយត្រលប់ចេញពីចំណោតដ៏រអិលនោះទៅ។ ឬយើងអាចដើរតាមដោយមិនអាចគេចរួចនូវសង្គមមួយដែលពួកអ្នកមានអំណាច មានលុយធ្វើអ្វីសម្រាប់តែប្រយោជន៍ផ្ទាល់ខ្លួន ហើយជាអ្នកកំណត់ថា តើមនុស្សណាគួរតែរស់ និងមនុស្សណាដែលគួរតែស្លាប់នោះ។

បណ្ឌិត លីអន កាស(Leon Kass) ជាជីវវិទូនៃសាកលវិទ្យាល័យ ស៊ីកាហ្គោ (University of Chicago) បាននិយាយទាក់ទងនឹងទិសដៅនៃវិទ្យាសាស្ត្រសម័យទំនើប និងថ្នាំពេទ្យថា «យើងបានធ្វើសាក្សីរួចហើយអំពីយោបល់របស់យើង គឺថាមនុស្សគឺជាអ្វីមួយដែលអស្ចារ្យ ឬមានលក្ខណៈដូចជាព្រះ គឺជាអ្វីដែលត្រូវបានបង្កើតមកដោយមានទាំងសិទ្ធិសេរីភាព និង សេចក្តីថ្លៃថ្នូរ។ ហើយជាការច្បាស់ណាស់ថា បើសិនជា

យើងមើលមកខ្លួនយើងថាជាសាច់មួយដុំ នោះយើងពិតជាសាច់មួយដុំមែន»[១៦]។

នេះគឺជាពិភពលោកមួយដែល កំពុងតែឈមមុខនឹង គំនិតនៃចលនាជំរុញឱ្យមានសិទ្ធិរំលូតកូន។

តើនេះជាពិភពលោកមួយ ដែលលោកអ្នកចង់ឱ្យកូនៗ និងចៅៗរបស់លោកអ្នករស់នៅឬ?

# ផ្នែកទី ៣

# ស្ត្រី

# ជំពូកទី ៨
# តើការរំលូតកូនជាបញ្ហាសិទ្ធិស្ត្រីឬ?

កែត មីសែលមិន (Kate Michelman) ជាអតីតប្រធាន ណារ៉ាល់ (NARAL) និយាយថា «យើងគួរតែរំលឹកមនុស្សថា ការរំលូតកូន គឺជាអ្នកធានាសិទ្ធិរបស់ស្ត្រី ដើម្បីឱ្យចូលរួមពេញលេញនៅក្នុងសង្គម និងជីវិតនយោបាយរបស់សង្គម»[១]។ ប៉ុន្តែ ស្ត្រីមានផ្ទៃពោះ*អាច* ចូលរួម*ពេញលេញ* នៅក្នុងសង្គម។ ហើយបើសិននាងមិនអាចចូលរួមបានទេ ការផ្លាស់ប្តូរសង្គមមិនមែនជាដំណោះស្រាយ ជាជាងការសម្លាប់ក្មេងឬ?

«តើធ្វើយ៉ាងណាទើបស្ត្រីអាចសម្រេចបាននូវគុណភាព ដោយមិនមានការគ្រប់គ្រង ការបន្តពូជ (ឱ្យកំណើតកូន)របស់ខ្លួន? ក្រុមដែលគាំទ្រសិទ្ធិស្ត្រីដើម្បីជីវិតឆ្លើយតបថា៖

> ការសន្មតនៃសំនួរ គឺជាការសន្មតរបស់បុរស ដែលគ្រប់គ្រងលើស្ត្រីអស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ គឺថា វាគឺជារឿងធម្មតាទៅហើយ ដែលបុរសអស្ចារ្យ ហើយស្ត្រីទន់ខ្សោយ(ទាបថោក)នោះ។ បច្ចេកវិទ្យាខាងជីវសាស្ត្រ គឺបានផ្តល់មកនូវដំណោះស្រាយដើម្បីសម្រេចបាននូវគុណភាពជីវិត ប៉ុន្តែការសន្មតនោះគឺមិនត្រឹមត្រូវទេ...វាគឺជាការមើលងាយស្ត្រី ដោយនិយាយថា ស្ត្រីត្រូវតែផ្លាស់ប្តូរជីវសាស្ត្ររបស់ខ្លួន ដើម្បីឱ្យត្រូវនឹងសង្គម»[២]។

នៅក្នុងសេចក្តីថ្លែងដំបូងរបស់នាង «ក្រុមស្ត្រីនិយមៈ ត្រូវបានទាក់ទាញដោយការរំលូតកូន» រ៉ូសម៉ារី បូតឈើរ (Rosemary Bottcher) អ្នកជំនាញខាងបរិស្ថានបាននិយាយថា ចលនាក្រុមស្ត្រីនិយម (ក្រុមការពារសិទ្ធិស្ត្រី) បានបន្ទាបបន្ថោកស្ត្រីដោយការគិតថា ពួកគេមិនអាចដោះស្រាយបញ្ហាតប់ប្រមល់ និងសម្ពាធនៃការមានផ្ទៃពោះ ដោយមិនយកការសម្លាប់កូនរបស់ពួកគេជាដំណោះស្រាយទេ[៣]។

ក្រុមអ្នកគាំទ្រការជ្រើសរើសតែងតែខិតខំប្រឹងប្រែង ដើម្បីឱ្យការរំលូតកូនត្រូវតែគិតថាដូចជា ការវះកាត់ទូទៅ នៅពេលដែលដឹងថា អ្នកជំងឺ និងគ្រោះថ្នាក់របស់

វា។ពួកគេហាក់ដូចជាមិនជឿថា ស្ត្រីអាចធ្វើការជ្រើសរើសដ៏ត្រឹមត្រូវបន្ទាប់ពីត្រូវបាន គេប្រាប់ពីការពិតដែលកំពុងតែកើតមានចំពោះនាងទេ។

ស៊េរីន ហ្វូសធើរ (Serrin Foster) ប្រធានស្ត្រីដើម្បីជីវិត បានថ្លែងសុន្ទរកថាដ៏មានសារៈសំខាន់មួយនៅក្នុង «ករណីរបស់ក្រុមស្ត្រីនិយមប្រឆាំងនឹងការរំលូតកូន»។ នាងបាននិយាយថា បើតាមប្រវត្តិសាស្ត្រ អ្នកដែលប្រឆាំងដ៏សកម្មបំផុតចំពោះការរំលូតកូនគឺជាស្ត្រី។ ជារឿងដែលគួរឱ្យសោកស្តាយណាស់ «ច្បាប់ប្រឆាំងនឹងការរំលូតកូន ដែលក្រុមស្ត្រីនិយមបានខិតខំធ្វើការយ៉ាងពិបាក ដើម្បីអនុម័តឱ្យមានការការពារដល់ស្ត្រី និងកុមារ ត្រូវបានបំផ្លាញក្នុងពេល ១០០ឆ្នាំក្រោយមកដោយសារសេចក្តីសម្រេច រ៉ូ វី វេត[៤] (Roe v. Wade)។

## ប្រវត្តិក្រុមស្ត្រីនិយម

ស៊ូសាន បី អ៊ែនថូនី (Susan B. Anthony) បានក្រោកឈរឡើងដើម្បីទាមទារសិទ្ធិស្ត្រី នៅពេលមួយដែលគេបិទសិទ្ធិស្ត្រីយ៉ាងខ្លាំង គឺសូម្បីតែបោះឆ្នោតមិនឱ្យស្ត្រីចូលរួមផង។ នាងបាននិយាយទាក់ទងនឹងការរំលូតកូនជាការ «សម្លាប់ក្មេង» ហើយជាការជញ្ជក់យកផលប្រយោជន៍ពីស្ត្រី និងក្មេងៗ។ អ៊ែនថូនី បានសរសេរថា «ខ្ញុំមានការសោកស្តាយចំពោះឃាតកម្មដ៏អាក្រក់ចំពោះក្មេងៗ...មិនថាជាអ្នកធ្វើនោះមានគំនិតយ៉ាងណានោះទេ ទាំងការស្រឡាញ់ ភាពសប្បាយ ឬបំណងដើម្បីសង្គ្រោះទារកដែលគ្មានកំហុសមិនទាន់កើតពីទុក្ខវេទនា ស្ត្រីៗមានអារម្មណ៍ថាខ្លួនមានកំហុស ខ្លាំងណាស់ ដោយបានប្រព្រឹត្តឃាតកម្មនោះ[៥]។

សារព័ត៌មានរបស់ អ៊ែនថូនី ឈ្មោះថា *បដិវត្តិ* បានប្រកាសយ៉ាងនេះ «នៅពេលដែលស្ត្រី សម្លាប់ជីវិតទារកដែលមិនទាន់កើតតាមរយៈការអប់រំ ឬបរិយាកាសជុំវិញបង្ហាញឱ្យឃើញថា នាងមានកំហុសខ្លាំង[៦]។

នៅប៉ុន្មានទសវត្សក្រោយមក មានក្រុមស្ត្រីនិយមថ្មីមួយទៀតបានកើតមកក្រោយក្រុមរបស់អានតូនី និងអ្នកប្រឆាំងនឹងការរំលូតកូនផ្សេងទៀត។ អ្នកដែលល្បីឈ្មោះជាងគេគឺ ម៉ាហ្គារែត ស៊ែងហ្គើរ (Magaret Sanger) ដែលគាំទ្រការរំលូតកូនថាជាមធ្យោបាយនៃការបង្កាត់ពូជមនុស្ស សេដ្ឋកិច្ច និងជាសេរីភាពខាងផ្លូវភេទ។ បន្ទាប់ពីការបង្កាត់ពូជមនុស្សបានធ្លាក់ប្រជាប្រិយភាពក្រោយពីរបបប្រល័យពូជសាសន៍របស់ពួកណាស៊ី អង្គការរបស់នាងត្រូវបានលួចធ្វើដោយលួចលាក់ហើយក្រោយមកបង្ហាញខ្លួនម្តងទៀតក្នុងឈ្មោះ សហព័ន្ធគម្រោងធ្វើជាមាតាបិតា (Planned Parenthood

Federation)[៧]។ ទាំង សែងហ្គើរ និងអ្នកផ្សេងទៀតដែលដើរតាម អែនថូនី បានព្យាយាម លើកយករបៀបវារៈការរំលូតកូនឱ្យក្លាយទៅជាការស្របច្បាប់នៃសិទ្ធិរបស់ស្ត្រី។

បណ្ឌិត ប៊ើននើត នៃថានសិន (Bernard Nathanson) បាននិយាយថា នៅទសវត្សឆ្នាំ ១៩៦០ គាត់ និងអ្នកដែលរៀបចំយុទ្ធសាស្ត្រសិទ្ធិនៃការរំលូតកូន បានភ្ជាប់ការរំលូតកូនទៅនឹងបញ្ហារបស់ស្ត្រី ថា មិនមែនជាការរំលូតកូនប៉ុណ្ណោះ តែជាសិទ្ធិរបស់ស្ត្រី[៨]។ ការរំលូតកូន គឺជាសិទ្ធិសម្រេចចុងក្រោយរបស់ស្ត្រី។

អាលីស ផល (Alice Paul) បានរៀបចំពង្រាងច្បាប់ដើមរបស់ ច្បាប់សិទ្ធិស្មើគ្នា (Equal Rights Amendment-ERA) ដែលជាឯកសាររបស់ក្រុមស្ត្រីនិយម។ ប៉ុន្តែ អាលីស បាននិយាយថា ការរំលូតកូនគឺជា «ការកេងយកផលប្រយោជន៍របស់ស្ត្រីដ៏អាក្រក់បំផុត»[៩]។

មានសមាជិកក្រុមស្ត្រីនិយមម្នាក់បានឱ្យឈ្មោះ ការប៉ុនប៉ងក្នុងការភ្ជាប់ក្រុមស្ត្រីនិយមទៅនឹងការរំលូតកូនគឺជា «ក្រុមភេរវករខាងស្ត្រីនិយម»។ នៅក្នុងពាក្យសម្ដីរបស់នាង បានបង្ខំក្រុមស្ត្រីនិយមឱ្យ «ព្រមសម្លាប់សម្រាប់អ្វីដែលអ្នកជឿ»[១០]។ នៅក្នុងការបោះពុម្ពផ្សាយរបស់ *ក្រុមស្ត្រីនិយមអាមេរិក (The American Feminist)* ស្ត្រីដើម្បីជីវិត មានដាក់រូបភាពដ៏ស្រស់ស្អាតរបស់ក្មេងម្នាក់ ហើយសួរថា «តើនេះជាមុខរបស់សត្រូវឬ?»។ ពួកគេបាននិយាយ ពួកគេបានឈរប្រឆាំងអស់រយៈពេលជាង ២០០ឆ្នាំនៃប្រវត្តិសាស្ត្ររបស់ក្រុមការពារមិនឱ្យរំលូតកូន ប៉ុន្តែក្រោយមកនៅទសវត្សឆ្នាំ១៩៧០ ចលនាស្ត្រីបានទទួលយកគំនិតនៃការរំលូតកូន»[១១]។

ការបោះឆ្នោតស្ទង់មតិជាច្រើនបង្ហាញឱ្យឃើញថា មានស្ត្រីច្រើនជាងបុរសដែលការពារសិទ្ធិទារកដែលមិនទាន់កើត[១២]។ តាមពិត «ក្រុមមនុស្សដែល គាំទ្រឱ្យមានការរំលូតកូន នៅសហរដ្ឋអាមេរិក (ហើយនៅប្រទេសផ្សេងទៀតផងដែរ) ពរុសស្បែកស ដែលមានអាយុប្រមាណ ២០ឆ្នាំ-៤៥ឆ្នាំ[១៣]។ ជាពិសេស «ក្រុមដែលគាំទ្រឱ្យមានការរំលូតកូននោះគឺបុរសដែលនៅលីវ»[១៤]។ វាជាការគួរឱ្យសោកស្ដាយដែរ ដែលការរំលូតកូនបានត្រលប់ចូលក្នុងបញ្ហាសិទ្ធិរបស់ស្ត្រី នៅពេលដែលលើកទឹកចិត្តភាពមិនទទួលខុសត្រូវ និងភាពបរាជ័យរបស់បុរសក្នុងការមើលថែទាំស្ត្រី និងកូនរបស់ខ្លួន។ តើបុរសមិនគួរត្រូវបានឱ្យមានការទទួលខុសលើសពីការផ្ដត់ផ្ដង់លុយ និងសម្លាប់ទេឬ? តើមិនគួរលើកទឹកឱ្យពួកគេទទួលខុសត្រូវ ជាជាងការដែលនិយាយទៅស្ត្រីថា អ្នកជាអ្នកបណ្ដោយឱ្យមានផ្ទៃពោះ ដោយនិយាយវិញថា «បងនឹងនៅទី

នោះជាមួយអូន ដើម្បីកូនរបស់យើង បងនឹងធ្វើអ្វីៗទាំងអស់ដើមកូនយើង»។

## ការជ្រើសរើសភេទ

រឿងដែលគួរឱ្យសោកស្ដាយមួយរបស់ក្រុមស្ត្រីនិយមគឺថា តាមរយៈការតស៊ូមតិរបស់ពួកគេ អំពីរំលូតកូន គឺបានទទួលស្គាល់មធ្យោបាយដ៏ធំបំផុតតែមួយនៃការប្លន់សិទ្ធិជាមូលដ្ឋានរបស់ស្ត្រី គឺសិទ្ធិដើម្បីរស់។

ការរំលូតកូនបានក្លាយជាមធ្យោបាយដើម្បីកំចាត់កូនស្រីដែលគេមិនចង់បានចោលនៅទូទាំងពិភពលោក។ ការសិក្សាមួយនៅប្រទេសឥណ្ឌាបានបង្ហាញឱ្យឃើញនូវទិន្នន័យគួរឱ្យព្រឺខ្លាចមួយ គឺក្នុងចំណោមប្រជាជន១០,០០០នាក់មានស្ត្រីតែ៥០នាក់ប៉ុណ្ណោះ[១៥]។ ក្មេងស្រីរាប់ពាន់នាក់ផ្សេងទៀតត្រូវបានស្លាប់ដោយការរំលូតកូន។ នៅ ទីក្រុង មុំបៃ តាម ការ ចត ឆ្លុះ ឃើញ ថា មាន ទារក ស្រី ចំនួន ៨,០០០ នាក់ តែក្នុងចំណោមទារកស្រីទាំងនោះ មានទារកស្រីម្នាក់ត្រូវបានសម្លាប់ដោយការរំលូត[១៦]។

ពីព្រោះការជ្រើសរើសភេទ ទាមរយៈការរំលូតកូន នៅប្រទេសចិន ទារកដែលកើតមកនៅប្រទេសចិនមាន២ភាគ៣ជាកូនប្រុស។ បើនៅជនបទវិញ មានស្រីម្នាក់ប្រុសបួននាក់[១៧]។

ការពិសោធនេះក៏បានធ្វើនៅសហរដ្ឋអាមេរិចផងដែរដើម្បីដឹងអំពីភេទរបស់ទារក។ *សារពត៌មានវិទ្យាសាស្ត្រពិភពលោក (Medical World News )*បានរាយការណ៍ឱ្យដឹងថា មានការសិក្សាមួយ នៅក្នុងចំណោមម្ដាយចំនួន៩៩នាក់ ត្រូវបានគេប្រាប់ឱ្យដឹងភេទរបស់កូនខ្លួន។ ហើយនៅក្នុងចំណោម៩៩នាក់នេះ មានកូនប្រុសចំនួន៥៣នាក់ និង ៤៦នាក់ជាកូនស្រី។ មានតែម្ដាយម្នាក់គត់ដែលជ្រើសរើសរំលូតកូនប្រុសរបស់ខ្លួន តែមានម្ដាយចំនួន២៩នាក់ជ្រើសរើសរំលូតកូនស្រីរបស់ខ្លួន[១៨]។

ឥឡូវនេះមានទារកស្រី ត្រូវបានសម្លាប់ដោយការរំលូតចេញច្រើនជាងទារកប្រុស។ ការសម្លាប់ក្មេងស្រីដែលមិនទាន់កើត គឺដូចជាសម្លាប់ក្មេងស្រីដែលកើតហើយដូច្នោះដែរ។ នឹងគ្មានសិទ្ធិស្មើភាពសម្រាប់ស្ត្រីទាំងអស់ទេ បើសិនជាសិទ្ធិរបស់ក្មេងស្រីដែលមិនទាន់កើតមិនស្មើភាពផងនោះ។

# ជំពូកទី ៩
# តើយើងមានសិទ្ធិដើម្បីជ្រើសរើស នូវអ្វីដែលយើងត្រូវធ្វើចំពោះរូបកាយរបស់យើងឬ?

អ្នកគាំទ្រការជ្រើសរើសបាននិយាយថា «ស្ត្រីគ្រប់រូបមានសិទ្ធិ ដើម្បីជ្រើសរើសអ្វីដែលនាងធ្វើចំពោះរាងកាយរបស់ខ្លួន»។ គួរឱ្យសោកស្តាយ ជម្រើសនៃការរំលូតកូន បញ្ជាក់ថា ជារៀងរាល់ឆ្នាំយ៉ាងហោចណាស់ក៏មានស្ត្រីចំនួន ៦៥០,០០០នាក់នៅសហរដ្ឋអាមេរិក ដែលមិនមានសិទ្ធិដើម្បីដើម្បីជ្រើសរើសអ្វីដែលពួកគេធ្វើចំពោះរាងកាយរបស់ខ្លួនទេ (ចំនួននោះគឺគ្រាន់តែជាចំនួនពាក់កណ្តាលនៃកូនដែលត្រូវរំលូតចេញប៉ុណ្ណោះ ហើយពាក់កណ្តាលទៀតគឺជាបុរសដែលធ្វើបាបមកលើស្ត្រី)។ ទារកស្រីដែលត្រូវសម្លាប់ដោយការរំលូតនោះ គឺមិនមានជីវិត មិនមានការជ្រើសរើស ឬមិនមានរាងកាយដើម្បីប្រើសិទ្ធិគ្រប់គ្រងខ្លួន។

មនុស្ស ប្រុស មិនបាន អនុញ្ញាតិ ដើម្បី បង្ហាញ ខ្លួន ទេ ។ មាន ច្បាប់ប្រ ឆាំងនឹង ការនោមនៅទីសាធារណៈ ពេស្យាចារនិងការប្រើគ្រឿងញៀន។ ភាគច្រើនក្នុងចំណោមយើង យល់ស្របនឹងច្បាប់នេះ ទោះបីជាច្បាប់នោះ បិទសិទ្ធិសេរីភាពដើម្បីធ្វើការណាមួយជាមួយនឹងរូបកាយរបស់ពួកគេក៏ដោយ។ ដៃរបស់ខ្ញុំ គឺជាផ្នែកមួយនៃរាងកាយរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនអាចប្រើវាដើម្បីវាយអ្នក ឬលួចអ្វីពីអ្នក ឬវាយក្មេងម្នាក់ឱ្យឈឺចាប់ឡើយ។

## សិទ្ធិដើម្បីធ្វើការជ្រើសរើស

នៅពេលដែលកម្មវិធីគាំទ្រជីវិតត្រូវបានយកមក បង្ហាញនៅក្នុងកម្មវិធីសាលាពេលខ្លះខ្ញុំចាប់ផ្តើមដោយនិយាយថា «ខ្ញុំជាអ្នកគាំទ្រការជ្រើសរើស។ ហេតុនេះហើយបានជាខ្ញុំជឿថា បុរសគ្រប់គ្នាមានសិទ្ធិគ្រប់គ្រាន់ដើម្បីចាប់រំលោភស្ត្រី បើសិននោះជាជម្រើសរបស់គាត់។ ពីព្រោះជារូបកាយរបស់គាត់ ហើយយើងមិនមានសិទ្ធិប្រាប់ថា តើអ្វីដែលគាត់អាចធ្វើ និងអ្វីដែលគាត់មិនអាចធ្វើនោះទេ»។

បន្ទាប់ពីខ្ញុំបញ្ចប់ ការចាប់ផ្តើមនិយាយដ៏គួរឱ្យភ្ញាក់ផ្អើលនេះ ខ្ញុំសូមពួកគេ

ឱ្យប្រាប់ខ្ញុំ អ្វីដែលជាជំនឿដ៏ខុសឆ្គងដែលខ្ញុំបាននិយាយ។ ពួកគេលើកឡើងថាដើម្បីគាំទ្រសិទ្ធិបុរស ខ្ញុំបានមើលរំលងការឈឺចាប់ដែលបានធ្វើចំពោះស្ត្រីដែលគ្មានកំហុសដែលត្រូវបានគេរំលោភសិទ្ធិ។ ខ្ញុំក៏និយាយថា «ដូច្នេះ អ្នកកំពុងតែប្រាប់ខ្ញុំថា តើអ្នកកំពុងតែប្រឆាំងនឹងការជ្រើសរើសមែនទេ?» បន្ទាប់ពួកគេជជែកតវ៉ាច្រើនឡើង ខ្ញុំបានឆ្លើយថា «ដូច្នេះ អ្នកកំពុងតែនិយាយមកកាន់ខ្ញុំថា បើសិនជាខ្ញុំបង្ហាញដល់អ្នកថា ជម្រើសរបស់ស្ត្រីដើម្បីពន្លូតកូន វាជាការធ្វើឱ្យមនុស្សម្នាក់ផ្សេងទៀតឈឺចាប់ ឬវាជាការសម្លាប់មនុស្សផង ដូច្នេះ អ្នករាល់គ្នានឹងមិនមែនជាក្រុមមនុស្សដែលគាំទ្រការជ្រើសរើសឱ្យមានការរំលូតកូនមែនទេ?។

សេចក្តីសង្ឃឹមរបស់ខ្ញុំ គឺត្រលប់មកគិតនូវអ្វីដែលគេធ្លាប់តែគិតជាទូទៅដែលស្តាប់ទៅវាត្រឹមត្រូវ។ ប៉ុន្តែ ពួកគេត្រូវបានបរាជ័យក្នុងរឿងរំលូតកូន។

វាមិនទំនងសោះក្នុងការការពារជម្រើសជាក់លាក់ណាមួយដែលជាជម្រើសគ្រឹះ។ ការសម្តែងចេញថា «សិទ្ធិនៃការជ្រើសរើស» បានមើលរំលងការពិត *មិនមែនជម្រើសទាំងអស់ជាការស្របច្បាប់ទេ* ។ ជាការពិត ហើយមានមនុស្សជាច្រើនទាំងគ្រិស្តបរិស័ទ ទាំងមិនមែនជាគ្រិស្តបរិស័ទយល់ស្រប គឺមានជម្រើសខ្លះពិតជាអាក្រក់ខ្លាំងណាស់។ មានជម្រើសខ្លះល្អ មានខ្លះអាក្រក់។ យើងមិនអាចពាក់ឯកសណ្ឋានជា អ្នកគាំទ្រការរំលូតកូនផង ឬប្រឆាំងនឹងការរំលូតកូនផងបានទេ។ យើងគួរតែធ្វើល្អ ហើយប្រឆាំងនឹងការអាក្រក់។

## ជ្រើសរើសគាំទ្រឱ្យមានការរំលូតកូនដោយអន្លើ

យើងគ្រប់គ្នាពេញចិត្តសេរីភាពនឹងការជ្រើសរើស ទាក់ទងនឹងជីវិតរស់នៅរបស់មនុស្ស តើពួកគេជិះឡានប្រភេទណា? តើពួកគេហូបអាហារប្រភេទណា?។ យើងទាំងអស់គ្នាក៏មានសិទ្ធិគាំទ្រសាសនា នយោបាយ និងជីវិតរស់នៅ ទោះបីជានៅពេលដែលមនុស្សជ្រើសរើសជំនឿ និងឥរិយាបថដែលយើងមិនចូលចិត្តក៏ដោយ។

ប៉ុន្តែមានការជាច្រើនដែលលោកអ្នកមិនគាំទ្រក្នុងការជ្រើសរើស ដូចជានរណាម្នាក់មានសិទ្ធិជ្រើសរើសដើម្បីរំលោភបំពានអ្នក ប្លន់អ្នក គាស់ផ្ទះរបស់អ្នក លួចឡានរបស់អ្នក ឬបោកប្រាស់អ្នកអំពីរឿងជំនួញ។ នោះគឺជាការបង្ហាញផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ដើម្បីធ្វើការជ្រើសរើសទាំងនោះ ប៉ុន្តែ មិនមែនមានន័យថា ពួកគេមានសិទ្ធិដើម្បីធ្វើការសម្រេចចិត្តជ្រើសរើសដូចនោះឡើយ។

នៅពេលដែលយើងប្រឆាំង «សិទ្ធិក្នុងការជ្រើសរើស» ការចាប់រំលោភ ឬការរំលោភបំពានលើក្មេង យើងមិនមែនកំពុងតែប្រឆាំងនឹងសិទ្ធិទេ តែយើងកំពុងតែប្រឆាំងនឹងអ្វីដែលខុស។ ហើយយើងក៏មិនមែនធ្វើដឹងមិនធ្វើឮ ហើយប្រកាន់តាមបែបនោះដែរ។

ជាការពិត ចលនាគាំទ្រការជ្រើសរើសគឺជាចលនារំលូតកូននោះឯង បានចាប់យកពាក្យ*ជម្រើស* ដោយជោគជ័យ។ *ជម្រើស* គឺជាពាក្យប្រើជំនួសការរំលូតកូន ដូច្នេះការជជែកប្រឆាំងនឹងការរំលូតកូន គឺបង្ហាញឱ្យឃើញនូវការជជែកប្រឆាំងនឹងជម្រើស។ អ្នកគាំទ្រជីវិតមិនគួរជជែកប្រឆាំងជាមួយនឹងជម្រើសទេ វាគឺជាសង្គ្រាមមួយដែលមិនអាចយកឈ្នះបាន ហើយមិនគួរតែធ្វើចម្បាំងដែរ។ យើងមិនគួរទុកឱ្យការរំលូតកូននៅតែជាយុទ្ធនាទាក់ទងនឹងជម្រើសឡើយ។ ដោយនូវពេលដែលយើងឮពីការ «គាំទ្រការជ្រើសរើស» យើងត្រូវតែសួរ ហើយជំរុញអ្នកផ្សេងឱ្យសួរ *តើយើងកំពុងតែនិយាយពីជម្រើសអ្វី?* បើសិនជាការរំលូតកូន សំណួរនោះគឺថា *តើអ្នកគិតថា មនុស្សមានសិទ្ធិដើម្បីធ្វើការជ្រើសរើសសម្លាប់ទារកមែនទេ?* តាមរយៈការប្រឆាំងនឹងការរំលូតកូន យើងមិនមែនប្រឆាំងនឹងជម្រើសទូទៅទេ គឺយើងកំពុងតែប្រឆាំងនឹងជម្រើសជាក់លាក់មួយ គឺជាការសម្លាប់ក្មេង។

សូមពិចារណាសំណួរដ៏មានប្រជាប្រិយភាពមួយរបស់ អ្នកគាំទ្រការជ្រើសរើស«បើសិនជាអ្នកមិនទុកចិត្តខ្ញុំជាមួយនឹងជម្រើសមួយ តើធ្វើយ៉ាងណាទើបអ្នកអាចទុកចិត្តខ្ញុំជាមួយនឹងក្មេងម្នាក់?»។ សំណួរនេះគឺចង់បិទផ្លូវមិនឱ្យមានការចរចាគ្នាតែម្តង។ប៉ុន្តែសូមកត់ចំណាំអំពីការនេះ *ជម្រើស* ត្រូវបានយកមកជំនួស *ការរំលូតកូន*។នៅពេលដែលយើងបន្ថែមពាក្យដែលឆ្លុះបញ្ចាំងអំពីភាពជាក់ស្តែង សំណួរនោះក្លាយជា«បើសិនជាអ្នកមិនទុកចិត្តខ្ញុំក្នុងការសម្លាប់ក្មេងម្នាក់ តើធ្វើយ៉ាងណាឱ្យអ្នកទុកចិត្តខ្ញុំក្នុងការចិញ្ចឹមក្មេងម្នាក់បាន?» អូ...!

## ចុះចំណែកជម្រើសរបស់អ្នករងគ្រោះវិញ?

មានស្ត្រីម្នាក់និយាយថា «បន្ទាប់ពីស្ត្រីម្នាក់មានផ្ទៃពោះ នាងមិនអាចជ្រើសរើស ថាតើនាងចង់ក្លាយជាម្តាយម្នាក់ឬក៏អត់នោះទេ។ នាងបានក្លាយជាម្តាយម្នាក់រួចទៅហើយ អ្វីដែលនៅសល់នោះគឺនាងត្រូវធ្វើការសម្រេចចិត្តថា តើនាងនឹងសម្រាលកូនរបស់នាងដោយឱ្យកូននោះស្លាប់ ឬសម្រាលកូននោះឱ្យរស់[១]។

ចៅហ្វាយរបស់ទាសករគឺជា អ្នកគាំទ្រការជ្រើសរើស ។ ពួកគេកំណត់ភាព

ខុសប្លែកគ្នាខាងរាងកាយ ដើម្បីបញ្ជាក់ពីអំណាចរបស់ពួកគេលើទាសកររបស់ខ្លួន។ ពួកគេនិយាយថា «អ្នកមិនបាច់ត្រូវមានទាសករទេ ប៉ុន្តែ សូមកុំប្រាប់យើងថា យើងមិនអាចមានទាសករនោះ។ អ្នកណាដែលចង់ គ្រប់គ្រងទាសករ គឺជាការខុសច្បាប់ ត្រូវបានគេចោទប្រកាន់ថា ប្រឆាំងនឹងការជ្រើសរើស និងប្រឆាំងសេរីភាពរបស់អ្នកផ្សេងដោយបង្ខំអ្នកផ្សេងឱ្យធ្វើតាមខ្លួន[២]។

ចលនាទាំងឡាយនៃការសង្កត់សង្កិន និងការកេងយកផលចំណេញពីទាសករ ដូចជាបើកបនពេស្យាចារ ជួញថ្នាំញៀន ត្រូវបានតាំងខ្លួនឯង អ្នកគាំទ្រការជ្រើសរើស។ ពួកគេក៏កំពុងតែតាំងខ្លួនប្រឆាំងចលនាដែលផ្តល់ការអាណិតមេត្តារំដោះឱ្យមានសេរីភាព ថាជាអ្នកប្រឆាំងនឹងការជ្រើសរើសរបស់អ្នកផ្សេងហើយ។

គោលជំហររបស់អ្នកគាំទ្រការជ្រើសរើសតែងតែមើលរំលងសិទ្ធិនៃការជ្រើសរើសរបស់ជនរងគ្រោះ។ ជនជាតិស្បែកខ្មៅមិនបានជ្រើសរើសធ្វើជាទាសករទេ ជនជាតិយូដាមិនបានជ្រើសរើសឡំដុតទេ ស្ត្រីមិនជ្រើសរើសការរំលោភទេ ហើយទារកក៏មិនជ្រើសរើសការរំលូតដែរ។

# ជំពូកទី ១០
# តើការរំលូតកូនជាផ្នែកមួយនៃសិទ្ធិជាឯកជនឬ?

ការរំលូតកូនមិនមែនជាកិច្ចការរបស់អ្នកផ្សេងណាទៀតទេ។ មនុស្សគ្រប់គ្នាមានសិទ្ធិជាឯកជនរបស់ខ្លួន។ វាផ្ទុយទៅនឹងជំនឿដ៏មានប្រជាប្រិយភាពមួយរបស់សហរដ្ឋអាមេរិក។ រដ្ឋធម្មនុញ្ញរបស់អាមេរិកនិយាយថា គ្មានអ្វីជាសិទ្ធិនៃឯកជនទេ។ លើសពីនេះទៀត ភាពឯកជនមិនមែនជាសិទ្ធិផ្តាច់មុខទេ ប៉ុន្តែ វាតែងតែត្រូវបានគ្រប់គ្រងដោយសិទ្ធិមួយផ្សេងទៀត។

តើយើងគិតយ៉ាងណា អំពីមនុស្សម្នាក់ត្រូវបានគេហាមមិនឱ្យវាយប្រពន្ធ និងរំលោភបំពានកូនក្មេង បាននិយាយថា «អ្វីដែលខ្ញុំធ្វើ គឺជារឿងឯកជនរបស់ខ្ញុំ មិនមែនជារឿងរបស់អ្នកផ្សេងទេ»?

សេចក្តីអះអាងមួយទៀតដែលតែងតែកើតកើតមានផ្សេងទៀត «ការរំលូតកូនគឺជាសិទ្ធិសម្រេចចិត្តជាឯកជន (ផ្ទាល់ខ្លួន) រវាងស្ត្រី និងគ្រូពេទ្យរបស់ខ្លួន»។

គ្រូពេទ្យត្រូវបានទទួលការបណ្តុះបណ្តាលខាងពេទ្យ ប៉ុន្តែ គំនិតខាងសីលធម៌របស់ពួកគេមិនមែនមានអំណាចដូចជាការវិភាគខាងផ្នែកពេទ្យរបស់ពួកគេទេ (ដោយពេលខ្លះពួកគេក៏ផ្តាសាយដែរ)។ មានគ្រូពេទ្យជាច្រើនជាមនុស្សដែលមានសតិសម្បជញ្ញៈ ដែលចាត់ទុកថា សុខុមាលភាពរបស់មនុស្សហួសពីចំណេះដឹង និងលុយ។ គួរឱ្យសោកស្តាយមានគ្រូពេទ្យខ្លះសីលធម៌របស់ពួកគេមិនអាចទុកចិត្តបានទេ។

សមត្ថភាពរបស់គ្រូពេទ្យនោះ ដែលអាចវិនិច្ឆ័យថា ធ្វើការដ៏អាក្រក់នោះត្រូវបានបង្ហាញឱ្យឃើញតាមរយៈគ្រូពេទ្យជនជាតិអាល្លឺម៉ង់ក្នុងកំឡុងពេលសង្គ្រាមលោកលើកទីពីរ។ លោក រ៉បើត ជេ លីវថិន (Robert Jay Lifton) លោកបានសរសេរនៅក្នុងសៀវភៅដ៏ល្បីរបស់លោកចំណងជើង *គ្រូពេទ្យរបស់ពួកណាស៊ី* បានកត់ត្រាពីអ្វីដែលគ្រូពេទ្យដ៏ចំណានៗបានចូលរួមក្នុងទង្វើដ៏អាក្រក់ និងសម្លាប់ដោយការវះកាត់ ហើយបានយកក្មេងដែលជិតនឹងស្លាប់មកធ្វើការពិសោធន៍[១]។ ពួកគេសុទ្ធតែត្រូវបានទទួលការហ្វឹកហ្វឺនជាគ្រូពេទ្យយ៉ាងប្រសើរបំផុតនៅក្នុងទ្វីបអឺរ៉ុប ប៉ុន្តែ ពួកគេបាត់បង់ត្រីវិស័យ

ខាងសីលធម៌របស់ខ្លួន។

គ្រូពេទ្យដែលធ្វើការរំលូតកូន គឺមិនបានគិតអំពីទិសដៅនៃការរំលូតកូនជាង ក្រុមហ៊ុនថ្នាំជក់គិតអំពីទិសដៅនៃការជក់បារីទេ។ អាជីព និងលុយរបស់ពួកគេបាន ពឹងទៅលើការរំលូតកូន ក៏ដូចជាការដែលមិនមានអ្វីប៉ះពាល់ដល់មនសិការរបស់ពួក គេ វាបានធ្វើឱ្យពួកគេ មានភាពកំសោយខាងសីលធម៌។

## ចៀសវាងសេចក្តីអាម៉ាស់

ស្ត្រីក្មេងៗជាច្រើន និងឪពុកម្តាយរបស់ពួកគេមិនចង់ឱ្យខ្មាសគេទេ។ មិន ថាជា អ្នកណាគិតអំពីការរួមភេទដោយមិនបានរៀបការនោះជាយ៉ាងម៉េចទេ ការមាន ផ្ទៃពោះនោះមិនមែនជាការខុសទេ ទោះបីវាជាលទ្ធផលនៃការរួមភេទក៏ដោយ។ មិន គួរមាននរណាម្នាក់ គិតឬប្រព្រឹត្តចំពោះម្តាយដូចជា «ស្ត្រីដែលមិនល្អ» ឬ ដាក់សម្ពាធ លើនាងឱ្យ «ដោះស្រាយបញ្ហារបស់នាង» ដោយការរំលូតកូនរបស់នាងទេតែយើង គួរតែ ស្រឡាញ់ និងជួយនាង ក្នុងពេលដែលនាងមានផ្ទៃពោះ ជួយណែនាំនាង ឱ្យជ្រើសរើសថា តើនឹងចិញ្ចឹមកូននោះ ឬឱ្យទៅអ្នកណាម្នាក់ទទួលចិញ្ចឹម។ ទោះបី ជានាងជ្រើសរើសយកមួយណាក៏ដោយយើងគួរតែគាំទ្រនាង។

នៅពេលដែលណាខ្ញុំឃើញស្ត្រីក្មេងៗកំពុងតែបីកូនរបស់ខ្លួន សកម្មភាពជា ដំបូងរបស់ខ្ញុំនោះ គឺសម្តែងការពេញចិត្ត និងសាទរដល់នាង។ ខ្ញុំដឹងថា នាងអាច «ដោះស្រាយរឿងនេះយ៉ាងលឿនបំផុត» ដោយគ្មាននរណាដឹង ប៉ុន្តែ នាងជ្រើសរើស ទុកកូនរបស់នាងឱ្យរស់នៅ។

ការរួមភេទមុនរៀបការ មានផលវិបាកយ៉ាងធ្ងន់ធ្ងរ គឺរួមទាំងការមានផ្ទៃពោះ ដែលខ្លួនមិនចង់មានផង។ ដោយហេតុនេះ យើងគួរតែគិតអំពី ការផ្តល់ការអប់រំពួក គេឱ្យចៀសវាង ឬតមទធ្វើរបែបនេះ[២]។ ចៀសវាងគឺជាការនិយាយថា «ទេ» ចំពោះអ្វី ដែលនាំឱ្យឈឺចាប់ដល់ខ្លួនអ្នក ហើយដើម្បីធ្វើដូច្នោះបាន ជាការនិយាយថា «បាទ ឬ ចាំ» ចំពោះជីវិតមួយដែលប្រសើរបំផុតសម្រាប់លោកអ្នក។ ប៉ុន្តែ បន្ទាប់ពីការរួមភេទ មុនពេលរៀបការបានកើតឡើងហើយ វាអាចជាមេរៀនមួយសម្រាប់យើង ហើយមិន ត្រូវធ្វើវាម្តងទៀតទេ។ ការសម្លាប់មនុស្សដែលគ្មានកំហុសដោយការរំលូតនោះ គឺធ្ងន់ ធ្ងរខ្លាំងណាស់ ហើយវាស្ថិតនៅជាប់ជារៀងរហូត។ គឺវាធ្វើឱ្យមនុស្សម្នាក់នោះចំណាយ លុយដើម្បីធ្វើកំហុសមួយផ្សេងទៀត។ លើសពីនេះទៀត វាបង្ខំឱ្យស្ត្រីក្មេងៗរស់នៅ ជាមួយនឹងអារម្មណ៍ដែលមានកំហុស ហើយវាផ្តល់ឱ្យនាងធ្វើនូវកំហុសដ៏ខ្លាំងលើស

នោះទៀតដើម្បីបិទបាំងអ្វីដែលនាងបានធ្វើនោះ។ ការរំលូតកូនអាច លាក់បាំងបាន ក្នុងមួយរយៈពេលខ្លី ប៉ុន្តែវាមិនដែលត្រូវបានដោះស្រាយរួចទេ។

ការរំលូតកូនបង្ហាញឱ្យឃើញឥរិយាបថ «សេចក្ដីសុខស្រួល និងសុភមង្គលរបស់ខ្ញុំជាអាទិភាព ទោះបីជាខ្ញុំបានរំលោភសិទ្ធមនុស្សដែលគ្មានកំហុស ដើម្បីទទួលបាននូវសេចក្ដីសុខស្រួល និងសុភមង្គលនោះក៏ដោយ»។ ឥរិយាបថបែបនេះមាននៅក្នុងគ្រប់ផ្នែកទាំងអស់ ទាំងតូចទាំងធំ ដែលបន្ថែមពើលើសីលធម៌របស់សង្គមដែលកំពុងតែចុះខ្សោយ (ហើយវាមិនដែលផ្ដល់សុមង្គលដូចដែលគិតទុកនោះឡើយ)។

ផលវិបាកដ៏អយុត្តិធម៌ និងភាពអាម៉ាស់របស់មនុស្សម្នាក់ មិនមែនកំណត់ដោយការសម្លាប់ជីវិតរបស់អ្នកផ្សេងនោះទេ។

# ជំពូកទី ១១
# តើរំលូតកូនមានគ្រោះថ្នាក់ដល់សុខភាពរាងកាយ និងសុខភាពខួរក្បាលរបស់ស្ត្រីឬទេ?

គោលនយោបាយរបស់សង្គមដែលបង្កើតឡើងដើម្បីជួយដល់ស្ត្រីត្រូវបានបរាជ័យដោយការរំលូតកូន។ ស៊ើរីន ហ្វូសធើរ (Serrin Foster) ជាប្រធានចលនាស្ត្រីដើម្បីជីវិត បានសរសេរថា «វាគឺជាការឆ្លុះបញ្ចាំងឱ្យឃើញថា យើងបានធ្វើឱ្យស្ត្រីទទួលបរាជ័យ»[១]។

ចូន អាប់ភ្លីថិន (Joan Appleton) គឺជាអ្នកគាំទ្រឱ្យមានការរំលូតកូនម្នាក់ និងជាប្រធានគិលានុបដ្ឋាយិកា នៅមន្ទីររំលូតកូនក្នុងរដ្ឋវើជីនៀរ (Virginia) នាងបានសួរខ្លួនឯងថា ហេតុអ្វីបានជាការរំលូតកូនជា «របួសខាងផ្លូវចិត្តចំពោះស្ត្រី បើសិនជាការនោះជារឿងធម្មជាតិ ហើយបើសិននោះជាការត្រឹមត្រូវ ហេតុអ្វីបានមានការពិបាកម្ល៉េះ?»។

អាប់ភ្លីថិន បាននិយាយមកកាន់ខ្លួននាងថា «ខ្ញុំបានផ្តល់ប្រឹក្សាដល់ស្ត្រីទាំងនេះយ៉ាងច្បាស់ ហើយពួកគេមានភាពប្រាកដក្នុងការសម្រេចចិត្តរបស់ខ្លួនណាស់។ ប៉ុន្តែ ហេតុអ្វីបានជាច្រើនខែច្រើនឆ្នាំក្រោយមកពួកគេមកជួបខ្ញុំវិញជាមួយនឹងបញ្ហាខាងផ្លូវចិត្តដូច្នេះ?[២]។

មានស្ត្រីដ៏ច្រើនលើសលប់ ដែលរងផលវិបាកដោយការរំលូតកូនបាននិយាយថា «ខ្ញុំមិនដឹងថា ការនេះនឹងកើតឡើងទេ មិនមាននរណាម្នាក់ប្រាប់ខ្ញុំឱ្យដឹងមុនពីគ្រោះថ្នាក់នេះទេ»។

## ផលវិបាកដែលតែងតែកើតមាន

នៅក្នុងការធ្វើសក្ខីកម្មរបស់នាងចំពោះមុខសមាជិកព្រឹទ្ធិសភាក្នុងឆ្នាំ ២០០៤ បណ្ឌិត អេលីសាបេត សាឌីហ្គាន់ (Elizabeth Shadigan) បានធ្វើសក្ខីកម្មថា «ការរំលូតកូន បានបង្កើនអត្រាមហារីកសុដន់ បញ្ហាស្បូន កូនកើតមិនគ្រប់ខែ និងការធ្វើ

អត្តឃាតរបស់ម្តាយកាន់តែច្រើនឡើង។ តាមស្ថិតិក្នុងករណីស្លាប់ទាំងអស់ គឺមានអត្រាខ្ពស់ជាមួយនឹងស្ត្រីដែលធ្លាប់រំលូតកូន[៣]»។

យ៉ាងហោចណាស់ មានការសិក្សាចំនួន៤៩ បានបង្ហាញឱ្យឃើញនូវស្ថិតិកើនឡើង អំពីកូនកើតមុនថ្ងៃកំណត់ កូនមិនគ្រប់ទម្ងន់ ជាគ្រោះថ្នាក់បំផុតសម្រាប់ស្ត្រីដែលធ្លាប់រំលូតកូន។ «កូនកើតទម្ងន់មិនគ្រប់ ឬកើតថ្ងៃកំណត់ គឺជាកត្តាគ្រោះថ្នាក់ធំជាងគេលើទារក ឬត្រូវពិការនៅពេលក្រោយ ក៏ដូចជាខ្វះលទ្ធភាពក្នុងការប្រើគំនិត និងបញ្ហាអត្តចរិតយ៉ាងធ្ងន់ធ្ងរ»[៤]។

ភាពចម្លែកនៃកុមារដែលមានរូបរាងមិនធម្មតាបានកើនឡើងដោយសារការរំលូតកូន[៥]។ អត្រាស្លាប់របស់ក្មេងដែលទើបកើត សម្រាប់ទារកដែលបន្ទាប់ពីម្តាយរបស់ពួកគេបានធ្វើការរំលូតពីមុន គឺក្នុងចន្លោះពីរទៅបួនដងនៃអត្រាស្លាប់ធម្មតា[៦]។ ពីព្រោះការរំលូតកូន បង្កើតនូវគ្រោះថ្នាក់ដល់កូនដែលត្រូវកើតមកបន្ទាប់ទៀត វាបង្ហាញឱ្យឃើញពីការទទួលខុសត្រូវចំពោះក្មេងដែលមានភាពពិការផ្នែកខួរក្បាលរាប់ពាន់នៅអាមេរិកខាងជើង[៧]។ ការមានកូនខុសកន្លែង កើតឡើងនៅក្នុងរយៈពេលមានគភ៌នោះ កើតឡើងនៅក្រៅស្បូន ជាពិសេសត្រង់ដៃស្បូន ហើយការមានគភ៌ប្រភេទនោះ គឺមានប្រហែលជា ១២%នៃអត្រាស្លាប់របស់ម្តាយក្នុងពេលដែលមានផ្ទៃពោះ។ នាយកដ្ឋានសុខភាព និងសេវាបម្រើមនុស្សរបស់អាមេរិកបានធ្វើការសិក្សាក្នុងរយៈពេល២០ឆ្នាំអំពីអត្រា ការមានគភ៌ដែលមានកូនក្រៅស្បូន បានបង្ហាញឱ្យឃើញថា អត្រាដែលកូននៅក្រៅស្បូននោះ កើនឡើងចំនួន ៥០% ចាប់តាំងមានការរំលូតកូនស្របច្បាប់មក[៨]។

ការសិក្សាក៏បង្ហាញឱ្យឃើញផងដែរថា គ្រោះថ្នាក់នៃការមានកូនក្រៅស្បូននោះ មានអត្រាខ្ពស់ជាពីរដងសម្រាប់ស្ត្រីដែលធ្លាប់រំលូតកូនតែម្តង ប៉ុន្តែសម្រាប់ស្ត្រីដែលធ្លាប់រំលូតកូនចាប់ពីពីរដងឡើងទៅ អត្រាគ្រោះថ្នាក់មានឡើងទៅបួនដង[១០]។ ចំនួន ៤០% នៃស្ត្រីដែលមានកូនក្រៅស្បូននឹងលែងមានកូន ហើយបើសិនជាមានកូនទៀតនោះ គឺក្នុងចំណោមស្ត្រីបីនាក់ គឺមានតែម្នាក់ទេដែលអាចមានកូន។ ជាការដែលគួរឱ្យកត់សំគាល់ថា «មានតែ៣៣% នៃស្ត្រីដែលធ្លាប់មានកូនក្រៅស្បូនប៉ុណ្ណោះនឹងអាចមានកូននៅពេលក្រោយទៀត»[១១]។

មជ្ឈមណ្ឌលគ្រប់គ្រងជំងឺ (The Centrs for Disease Control–CDC)បានរាយការណ៍ដោយដឹងថា «ការមានគភ៌ដែលមានភាពស្មុគស្មាញ ដូចជាកូននៅក្រៅស្បូន

នៅតែកើតមានដល់ស្ត្រីចំនួន ២០០០ នាក់ក្នុងមួយថ្ងៃ»[១២]។

ជម្ងឺរលាកត្រគាក (Pelvis Inflammatory Disease-PID) គឺជាជំងឺមួយដែលនាំទៅរក ជំងឺគ្រុនក្តៅ និងជំងឺមិនមានកូន (រាំងរដូវ)។ តាមរយៈការសិក្សាស្រាវជ្រាវបង្ហាញឱ្យឃើញថា «ជំងឺរលាកត្រគាកគឺជាជំងឺដែលតែងតែកើតមាន និងជាបញ្ហាដ៏ធ្ងន់ធ្ងរ របស់ស្ត្រីដែលធ្លាប់រំលូតកូន គឺមានប្រហែលជា ៣០% កូនករណីជំងឺរលាកត្រគាកទាំងអស់[១៣]»។ ការសិក្សាមួយ ជាមួយនឹងស្ត្រីដែលក្រោយពីធ្វើការរំលូតកូនក្នុងត្រីមាសដំបូង ដែលមានជំងឺរលាកត្រគាក គឺមានអត្រាយ៉ាងខ្ពស់នៃការមិនអាចមានកូនទៀត មានការឈឺចាប់ក្នុងពេលរួមភេទ និងជំងឺត្រគាករ៉ាំរ៉ៃ»[១៤]។

ការដែលមានកូននៅក្រៅស្បូន គឺបណ្តាលមកពី «ការធ្វើឱ្យខូច ឬរបួសដៃស្បូនកន្លងមក»[១៥] រួមទាំងការរំលូតកូនផងដែរ។ គឺកើតឡើងចំនួន ៧-១៥ ដង លើសពីធម្មតាចំពោះស្ត្រីដែលធ្លាប់រំលូតកូន ជាងស្ត្រីដែលមិនធ្លាប់រំលូតកូន[១៦]។ របាយការណ៍ថ្មីនេះបានឱ្យដឹងថា ផលវិបាកកើតឡើងភ្លាមៗលើករណីរំលូតកូនមិនតិចជាង ១០%ទេ។ ការសិក្សាផ្សេងទៀតអំពីផលវិបាករយៈពេលវែង បង្ហាញឱ្យឃើញអត្រាមិនទាបជាង ១៧% និងផលវិបាកដែលកើតឡើងជាញយៗបង្ហាញឱ្យឃើញថា មានកម្រិតពី ២៥-៤០%[១៧]។

ស្ត្រីដែលធ្លាប់រំលូតកូនម្តង បង្កើនឱ្យមានបញ្ហាមហារីកឆ្អឹងកងទ្វេដង បើប្រៀបធៀបជាស្ត្រីដែលមិនធ្លាប់រំលូតកូនសោះ ហើយស្ត្រីដែលធ្លាប់រំលូតកូនច្រើនដងគឺប្រឈមនឹងគ្រោះថ្នាក់ច្រើនលើស៥ដង។ ដូចគ្នាការបង្កើនមហារីកស្បូននិងមហារីកថ្លើមដែរ[១៨]។

បន្ទាប់ពីការសិក្សាដ៏លំបាកមួយដោយលោក បណ្ឌិត យ៉ូអែរល ប្រ៊ីន (Joel Brind) ជាសាស្ត្រាចារ្យ ផ្នែក អ័រម៉ូនវិទ្យា នៅ សាកលវិទ្យាល័យ ក្រុង ញូវ យ៉ក (City University of New York)បានធ្វើការសន្និដ្ឋានថា «កត្តាប្រសើរបំផុតដែលអាចចៀសវាងពីមហារីកសុដន គឺជាការមិនរំលូតកូន»[១៩]។ ស្ត្រីម្នាក់ដែលធ្លាប់រំលូតកូនម្តង បង្កើតភាពគ្រោះថ្នាក់ដោយមហារីកសុដនដល់ខ្លួនប្រហែលជា ៥០%-៨០%[២០]។មានស្ត្រីខ្លះ ដែលបន្ទាប់ពីរំលូតកូន អាចមានគភ៌ដែរ។ ការរំលូតកូនបង្កើតគ្រោះថ្នាក់ដល់ ការរីកលូតលាស់ដល់ក្មេងនៅពេលក្រោយ[២១]។

ជាញឹកញាប់ការស្លាប់របស់ក្មេងដែលទើបកើត ដែលម្តាយរបស់ខ្លួនបានធ្វើការរំលូតកូនពីមុន គឺក្នុងចន្លោះរវាងពី២ទៅ៤ដងនៃអត្រាស្លាប់ធម្មតា[២២]។

## ផលវិបាកផ្លូវចិត្តដែលតែងតែកើតមាន

តាមរយៈការសិក្សាជាច្រើនបង្ហាញឱ្យឃើញថា ការរំលូតកូន បានបង្កើតនូវអសមត្ថភាពខាងផ្លូវភេទ និងការបាត់ចំណង់ខាងផ្លូវភេទ និងបាត់ភាពស្និទ្ធស្នាល អារម្មណ៍មានកំហុសកើតឡើងដោយមិនបានរំពឹងទុក កំផិត តប់ប្រមល់ លក្ខណៈខុសប្លែកពីធម្មតា ទុក្ខព្រួយ អារម្មណ៍ដែលត្រូវគេរំលោភបំពាន និងបដិសេធក្មេងៗហើយការប្រើជាតិស្រវឹង និងថ្នាំញៀនមានភាពកើនឡើង[២៣]។ការសិក្សាមួយទៀតបង្ហាញឱ្យឃើញថា ស្ត្រីដែលរំលូតកូន គឺហាក់ដូចជាចូលចិត្តប្រើថ្នាំញៀនលើសស្ត្រីដែលមិនធ្លាប់ប្រើដល់ទៅ៥ដង[២៤]។

ដាវិដ រៀឌិន (David Reardon) អ្នកជំនាញខាងសុខភាពស្ត្រីក្រោយពីរំលូតកូន បានសរសេរឱ្យដឹងថា «នៅក្នុងការសិក្សាមួយបង្ហាញឱ្យឃើញថា អ្នកជំងឺបន្ទាប់ពីចំនួន៨សប្ដាហ៍នៃការរំលូតនោះ ៤៤% បានរអ៊ូថាឈឺក្បាលវិលមុខ៣១%មានការសោកស្ដាយចំពោះការសម្រេចចិត្តរបស់ពួកគេ ៣៦%មានបញ្ហាគេងមិនលក់ និង ១១%ត្រូវទទួលថ្នាំព្យាបាលផ្លូវចិត្តដោយគ្រូពេទ្យប្រចាំគ្រួសាររបស់ពួកគេ[២៥]»។ នេះជាចំណុចសំខាន់ណាស់ដែលគួរដឹង ព្រោះស្ត្រីខ្លះមិនមានផលប៉ះពាល់អ្វីដល់សុខភាពទេ បន្ទាប់ពីពួកគេបានរំលូតកូនភ្លាមៗនោះ។

ចលនាស្ត្រី ត្រូវកេងយកចំណេញដោយការរំលូតកូន (Women Exploited by Abortion) មានសមាជិកចំនួន៣០០០០នាក់នៅទូទាំងប្រទេសអាមេរិក ហើយក៏មានសាខានៅប្រទេសកាណាដា ញូស៊ីឡែន និងប្រទេសនៅទ្វីបអាហ្វ្រិក[២៦]។ មានក្រុមជួយដល់អ្នករងគ្រោះបន្ទាប់ពីការរំលូតកូនផ្សេងទៀត រួមមាន សមាគមជនរងគ្រោះដោយការសម្រេចចិត្ត សមាគមការប្រឹក្សាយោបល់ និងអប់រំដល់អ្នកដែលបានរំលូតកូន សមាគមអប់រំអ្នកដែលមានបញ្ហាផ្លូវចិត្តបន្ទាប់ពីរំលូតកូន...។ល។ ការកើតឡើងនៃក្រុមទាំងនោះ បានបញ្ជាក់ឱ្យដឹងថា មានស្ត្រីដែលធ្លាប់រំលូតកូនដ៏ច្រើនលើសលប់មានបញ្ហាខួរក្បាល និងបញ្ហាផ្លូវចិត្ត។

ខ្ញុំបានអានសារព័ត៌មានមួយ អ្នកនិពន្ធបានសរសេរថា ការរំលូតកូនគឺគ្រាន់តែជាការវះកាត់ក្នុងរូបភាពមួយផ្សេងទៀតតែប៉ុណ្ណោះ គឺមិនខុសគ្នាពីការវះកាត់ពោះវៀនដុះខ្នែងទេ។ ប៉ុន្តែ ហេតុអ្វីបានជា មនុស្សមិននឹកចាំពីថ្ងៃខួបដែលពួកគេបានវះកាត់កាលពី២០ឆ្នាំមុន? ហេតុអ្វីបានជាពួកគេមិនយំសោកស្ដាយចំពោះខ្នែងពោះវៀនដែលបានកាត់ចេញនោះ?ហើយហេតុអ្វីមិនមានក្រុមគាំទ្រប្រឹក្សាយោបល់ដល់

ពួកអ្នកដែលវះកាត់ពោះវៀនដុះខ្នែង?

មានបុរសជាច្រើនក៏កើតមានបញ្ហាផ្លូវចិត្តដែរ ដោយព្រោះតែពួកគេមានការពាក់ព័ន្ធក្នុងការសម្រេចចិត្តពីការរំលូតកូន និងការបាត់បង់កូនៗរបស់ពួកគេ[២៧]។ (ក្រុមដែលចាំជួយផ្ដល់ប្រឹក្សាយោបល់នោះក៏ជួយពួកគេផងដែរ)[២៨]។

## ការស្លាប់ដែលបណ្ដាលមកពីការរំលូតកូនស្របច្បាប់

ការសិក្សារបស់សមាគមស្ត្រីដែលស្លាប់ពេលមានគភ៌ បានបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីអាមេរិកមួយ បានបង្ហាញឱ្យឃើញថា អត្រាសីលធម៌ទាក់ទងនឹងការរំលូតកូនមាន ២.៩៥ ដង ច្រើនជាងអ្នកមានផ្ទៃពោះដែលមិនរំលូតកូន[២៩]។

មជ្ឈមណ្ឌលគ្រប់គ្រងជំងឺបានរាយការណ៍ថា នៅសហរដ្ឋអាមេរិកមានអ្នកស្លាប់ដោយរំលូតកូន១០នាក់ក្នុងឆ្នាំ១៩៩៨[៣០] ប៉ុន្តែ យោងតាមរបាយការណ៍ដូចគ្នាស្ថិតិនោះគឺមិនបានប្រាប់គ្រប់ចំនួនទេ ពីព្រោះមានអ្នករំលូតកូនខ្លះក៏បានបិទបាំងព័ត៌មានដែរ។ តាមពិត មន្ទីររំលូតកូន មិនមានផលចំណេញអ្វីទេ ក្នុងការដែលគេរាយការណ៍ ឬក៏មិនរាយការណ៍ទាក់ទងទៅនឹងការរំលូតកូននោះ[៣១]។ អ្វីដែលធ្វើឱ្យការរំលូតកូនធ្វើឱ្យស្លាប់មនុស្សនោះ គឺដោយសារភាគច្រើន មិនស្លាប់ក្នុងពេលរំលូតទេ គឺស្លាប់ក្រោយពេលរំលូតកូនមួយរយៈមក។

> សូមពិចារណា ម្ដាយដែលមានបញ្ហាធ្លាក់ឈាម ត្រូវបានបញ្ចូលឈាមឱ្យវិញ មានជំងឺថ្លើម ហើយប៉ុន្មានខែក្រោយមកបានស្លាប់។ តើមូលហេតុអ្វីបណ្ដាលឱ្យស្លាប់? រោគថ្លើម? តើអ្វីជាមូលហេតុជាក់ស្ដែង? គឺការរំលូតកូន។ ការចោះស្បូននាំឱ្យមានកើតមហារីកត្រគាក មានជាតិពុលក្នុងឈាម និងអាចស្លាប់។ មានរបាយការណ៍ជាផ្លូវការមួយបានឱ្យដឹងថា មូលហេតុនៃការស្លាប់គឺមកពីបញ្ហាអាប់សែត្រគាក និងជំងឺសសៃឈាម។ គេមិនសរសេរពីបញ្ហារំលូតកូនទេ។ការរំលូតកូនបណ្ដាលឱ្យមាន បញ្ហាសសៃឈាម។ នាងមានគភ៌ក្រៅស្បូន ប៉ុន្មានឆ្នាំក្រោយមកនាងក៏ស្លាប់ទៅ។ នោះគេប្រហែលជារាយការណ៍ថា គឺបញ្ហាកូនក្រៅស្បូន គេមិននិយាយពីមូលហេតុដែលនាងធ្លាប់រំលូតកូនទេ[៣២]។

ការសិក្សាមួយ ដែលត្រូវបានចុះផ្សាយនៅក្នុងទិន្នានុប្បវត្តិវេជ្ជសាស្ត្រភាគខាងត្បូង (Southern Medical Journal) បានចង្អុលបង្ហាញថា «ស្ត្រីដែលរំលូតកូន គឺជួបគ្រោះដែលអាចបណ្ដាលឱ្យស្លាប់ច្រើនជាងស្ត្រីដែលទុកឱ្យកូនកើត»[៣៣]។ នេះរួមទាំង១៥៤%នៃការស្លាប់ ដែលខ្ពស់ជាងការធ្វើអត្តឃាត ហើយក៏ខ្ពស់ជាងស្ត្រីដែលស្លាប់ដោយសារគ្រោះថ្នាក់ចរាចរ និងដែលត្រូវគេធ្វើឃាតដែរ។

ការសិក្សាមួយក្នុងរបៀបជាសព្វវចនាធិប្បាយឈ្មោះថា *សុខភាពស្ត្រីបន្ទាប់ពីរំលូតកូន (Women's Health Aftern Abortion)* ដែលត្រូវបានដកស្រង់ នៅក្នុងអត្ថបទខាងវេជ្ជសាស្ត្រប្រហែលជាង៥០០បង្ហាញឱ្យឃើញពីផលវិបាកដែលកើតឡើងចំពោះស្ត្រីដែលបានរំលូតកូន[៣៤]។ បើអ្នកណានៅតែមានការសង្ស័យ អំពីគ្រោះថ្នាក់ដែលកើតមានចំពោះស្ត្រីរំលូតកូននោះសូមពិនិត្យមើលភស្តុតាងខាងក្រោមនេះ៖

## អ្វីដែលស្ត្រីៗនិយាយ

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើស្ត្រីដែលជួបផលវិបាកដោយការរំលូតកូនបញ្ជាក់ឱ្យឃើញថា៖

១. ជាង ៩០% និយាយថា ពួកគេមិនបានទទួលព័ត៌មានគ្រប់គ្រាន់មុននឹងធ្វើការរំលូតកូនទេ។

២. ជាង ៨០% និយាយថា ពួកគេប្រហែលជាមិនពន្លូតកូនទេ បើមិនមានការលើកទឹកចិត្តពីអ្នកផ្សេងឱ្យធ្វើការរំលូតកូននោះ រួមទាំងប្រឹក្សាយោបល់ខាងរំលូតកូនផងដែរ។

៣. ៨៣% ប្រហែលជាមិនពន្លូតកូនទេ បើសិនជាពួកគេបានទទួលការគាំទ្រពីមិត្តប្រុស ឬពីមនុស្សសំខាន់នៅក្នុងជីវិតរបស់ពួកគេ។

ស្ត្រីគ្រប់រូបសក្តិសមនឹងទទួលអ្វីៗលើសពីការរំលូតកូន។

# ជំពូកទី ១២

# តើរំលូតកូន ជាការត្រឹមត្រូវឬ នៅពេលដែលការមានគភ៌ គឺជាគ្រោះមួយចំពោះជីវិតម្តាយនោះ?

តើការរំលូតកូន គឺជាការត្រឹមត្រូវឬ នៅពេលដែលជីវិត ឬសុខភាពរបស់ស្ត្រីម្នាក់ ត្រូវបានគំរាមគំហែងដោយការមានគភ៌ ឬមានកូននោះ? វាគឺជាករណីកម្រមានណាស់ ដែលការរំលូតកូនជាការសង្គ្រោះជីវិតរបស់ម្តាយ។ បណ្ឌិត ស៊ី អេវើរិតឃូប (C. Everett Koop) បាននិយាយបញ្ជាក់ថា អស់រយៈពេលប្រហែលជាង៦០ឆ្នាំដែលលោកធ្វើជាគ្រូពេទ្យកុមារផ្នែកខាងវះកាត់មកលោកមិនដែលឃើញ សូម្បីតែមួយករណីដែលការសម្លាប់ក្មេងមុនកើត (រំលូតកូន) ជាការជួយដល់ជីវិតម្តាយនោះ។ លោកមានប្រសាសន៍ថា អ្វីដែលលោកនិយាយគឺដើម្បីបញ្ជាក់ថា ការរំលូតកូនគឺជា «កញ្ចក់ស្រអាប់មួយ»។ បណ្ឌិត លែនឌ្រឹម សែតថល (Landrum Shettles) បានប្រកាសថា ការរំលូតកូនបានជួយសង្គ្រោះជីវិតរបស់ម្តាយនោះមានតិចជាង១%[១]។

## សង្គ្រោះជីវិតដែលអាចសង្គ្រោះបាន

ស្ត្រីម្នាក់ដែលមានគ្រោះថ្នាក់បណ្តាលមកពីជាតិពុលនៅក្នុងឈាម នឹងមានបញ្ហាសុខភាពយ៉ាងធ្ងន់ធ្ងរ ហើយមានអារម្មណ៍មិនស្រណុកស្រួលទេ និងត្រូវដេកសម្រាកឱ្យបានច្រើននៅពេលដែលនាងមានគភ៌នោះ។ នេះជាការពិបាកណាស់ ប៉ុន្តែវាមិនមែនជាការគម្រាមគំហែងជីវិតទេ។ ក្នុងករណីដូចនេះ ការរំលូតកូនដើម្បី«សុខភាព» មិនអាចជាការសង្គ្រោះជីវិតទេ តែជាការយកជីវិតវិញ។

ទោះបីជាយ៉ាងណាក៏ដោយ បើម្តាយមានជំងឺមហារីកស្បូនរីកសាយលឿន ការវះកាត់ដើម្បីយកជាតិមហារីកនោះចេញ ប្រហែលជាត្រូវធ្វើឱ្យកូននោះស្លាប់ហើយ។ ការមានគភ៌ខុសកន្លែងនោះ គឺជាការមានកូននៅក្រៅស្បូន។ កូននោះគ្មានសង្ឃឹមថាអាចរស់បានទេ ដូច្នេះ ត្រូវតែយកចេញដើម្បីជួយសង្គ្រោះជីវិតរបស់ម្តាយ។ នេះគឺជាស្ថានភាពដ៏អាក្រក់មួយប៉ុន្តែ ទោះបីជាត្រូវបាត់បង់ជីវិតមួយក៏ដោយ គឺត្រូវសង្គ្រោះជីវិតដែលអាចសង្គ្រោះបាន ហើយភាគច្រើនគេតែងសង្គ្រោះជីវិតរបស់

ម្ដាយ។ កម្រមានករណីវះកាត់ស្ត្រីដែលមានគភ៌ជិតនឹងកើត ដែលជួយសង្គ្រោះជីវិតរបស់កូនបាន តែមិនអាចជួយសង្គ្រោះជីវិតរបស់ម្ដាយបានណាស់។ ជាថ្មីម្ដងទៀត ការដែលជួយសង្គ្រោះជីវិតរបស់មនុស្សម្នាក់បាន ប្រសើរជាងការបាត់ជីវិតទាំងពីរ។

បងប្អូនអើយ យើងពិតជាបានជួបនឹងស្ថានភាពដែលជីវិតរបស់ម្ដាយត្រូវបានគម្រាមគំហែង ហើយការរីកសាយយ៉ាងលឿននៃជំងឺមហារីកនោះអាចធ្វើឱ្យកូននៅក្នុងផ្ទៃម្ដាយស្លាប់។ ការមានគភ៌នោះវាលឿងពេក គឺមិនមានពេលគ្រប់គ្រាន់ដើម្បីឱ្យកូនអភិវឌ្ឍខ្លួនគ្រប់គ្រាន់ ដើម្បីរស់នៅខាងក្រៅពោះមុនពេលទាំងម្ដាយ និងកូនអាចស្លាប់។ ការវះកាត់នោះបានធ្វើរួចហើយ ប៉ុន្តែនេះមិនមានអ្វីទាក់ទងនឹងការរំលូតកូនទេ។ គោលបំណងនៃការវះកាត់នោះ គឺមិនមែនដើម្បីសម្លាប់កូនទេ គឺដើម្បីសង្គ្រោះជីវិតរបស់ម្ដាយ។ ការស្លាប់របស់កូន គឺជាចំណែកប៉ះពាល់ដ៏អាក្រក់មួយនៃការខិតខំប្រឹងប្រែងជួយសង្គ្រោះជីវិតមនុស្ស។ នេះគឺជាសកម្មភាពនៃការការពារជីវិត ក្នុងនាមជាអ្នកការពារជីវិតមនុស្សនោះ មិនមែនមានន័យថា ជាការគ្រាន់តែការពារជីវិតរបស់ទារកទេ គឺវាមានន័យផងដែរក្នុងការការពារជីវិតរបស់ម្ដាយ។

# ជំពូកទី ១៣

# តើរំលូតកូនជាការត្រឹមត្រូវឬ នៅពេលដែលការមានគភ៌ គឺជាលទ្ធផលដែលកើតមកពីការរំលោភ ឬការរួមភេទជាមួយសាច់ញាតិជិតស្និទ្ធ?

ការសិក្សាជាច្រើនដែលធ្វើដោយអ្នកគាំទ្រការជ្រើសរើស របស់វិទ្យាស្ថានហ្គាតមាឈើរ (Guttmacher Institute) បង្ហាញឱ្យឃើញថា មនុស្សដែលចេះគិតហើយយល់ព្រមគ្នាដើម្បីរួមភេទនោះ ការដែលអាចមានគភ៌នោះមានតែ៣%ទេ។ ពួកគេក៏ចង្អុលបង្ហាញឱ្យឃើញថា មានកត្តាផ្សេងៗដែលចូលរួមក្នុងការរំលោភ ក៏កាត់បន្ថយនូវអត្រានៃការមានកូនរបស់អ្នកដែលត្រូវគេរំលោភដែរ[១]។ វិទ្យាស្ថាននោះបាននិយាយថា នៅក្នុងមួយឆ្នាំមាន ការរំលូតកូនដែលជាលទ្ធផលនៃការរំចាប់រំលោភនិងរួមភេទជាមួយសាច់ញាតិជិតស្និទ្ធដែលច្បាប់ហាមចំនួន ១៤000 នាក់[២] ដែលចំនួននេះមានត្រឹមតែ ១% នៃករណីរំលូតកូនទាំងអស់[៣]។ ការសិក្សាផ្សេងៗជាច្រើនទៀតបង្ហាញឱ្យឃើញថា ការមានគភ៌ដោយការចាប់រំលោភនោះមានតែមួយទេក្នុងមួយពាន់[៤]។ លើសពីនេះទៀត ដោយសារតែការមានគភ៌មិនកើតឡើងភ្លាមៗបន្ទាប់ពីការរួមដំណេកនោះការមានគភ៌ដោយការចាប់រំលោភនោះ ប្រហែលជាត្រូវបានការពារដោយការលាងសំអាតមិនឱ្យទឹកកាមរបស់បុរសចូលគ្នាជាមួយទឹកកាមរបស់ស្ត្រីដែលអាចនឹងបង្កកំណើតបាន (នេះគឺខុសប្លែកគ្នាយ៉ាងខ្លាំង ពីការប្រើថ្នាំ ដែលអាចសម្លាប់ទារកដែលចាប់ផ្តើមមាននៅក្នុងគភ៌ហើយ)។

## តើអ្វីនៅជាបញ្ហាពិតប្រាកដ?

តើគំនិតដែលយល់ខុសថា ការមានគភ៌ភាគច្រើន ជាលទ្ធផលនៃការចាប់រំលោភ? ស្ត្រីដែលមានការភ័យខ្លាចជាច្រើនគិតថា ការមានផ្ទៃពោះរបស់ពួកគេ គឺដោយសារតែការចាប់រំលោភ គេនិយាយយ៉ាងនេះ គឺដើម្បីចៀសវាងការថ្កោលទោស

ពីអ្នកផ្សេង។ នរម៉ា ម៉ាកឃវី (Norma McCorvey) ជាស្ត្រីវ័យក្មេងដែលគេហៅថា «រ៉ូ» (Roe) នៅក្នុងបទបណ្ដឹងក្នុងតុលាការឈ្មោះថា *រ៉ូវី. វេឌ (Roe v. Wade)* ស្ត្រីម្នាក់នេះត្រូវបាននិយាយទៅកាន់តុលាការ និងប្រព័ន្ធផ្សព្វផ្សាយថា នាងត្រូវគេចាប់រំលោភ ប៉ុន្តែប៉ុន្មានឆ្នាំក្រោយមក នាងបានសារភាពថា នាងកុហកហើយគ្មានអ្នកណាចាប់រំលោភនាងទេ[៥]។ (ក្រោយមកម៉ាកឃវីក្លាយជាស្ត្រីម្នាក់ដែលលេចធ្លោ ក្នុងក្រុមអ្នកគាំទ្រជីវិត ហើយនាងបានស្នើឱ្យតុលាការកំពូល ឱ្យពិនិត្យ និងសើរើសាលក្រម *រ៉ូវី. វេឌ* នោះឡើងវិញ[៦]។

ក្រុមអ្នកគាំទ្រការជ្រើសរើស បានតស៊ូមតិបង្វែរការចាប់អារម្មណ៍ពីសំណាក់អ្នកដែលចាប់អារម្មណ៍រឿងការរំលូតកូន ឱ្យមកគិតរឿងការចាប់រំលោភ ពីព្រោះវាគឺជាករណីដែលគួរឱ្យអាណិត។ គោលបំណងរបស់ពួកគេនោះគឺ ឱ្យគិតថា ការមានផ្ទៃពោះដែលកើតមកពីការចាប់រំលោភនោះ គឺច្រើនណាស់។

យើងមានមិត្តសម្លាញ់ម្នាក់ ដែលត្រូវគេចាប់រំលោភ ហើយក៏មានគភ៌ ហើយដោយសារតែស្ថានភាពជីវិតរបស់នាង នាងមិនអាចចិញ្ចឹមកូនបានទេ។ នាងបានឱ្យកូនទៅគ្រួសារគ្រិស្តបរិស័ទមួយចិញ្ចឹម។ នាងបានទំនាក់ទំនងជាមួយគ្រួសារនិងកូនរបស់នាងជាញឹកញាប់។ នោះមិនមែនជាការងាយស្រួលទេ ហើយនាងមានការឈឺចាប់ខ្លាំងណាស់ ប៉ុន្តែនាងនៅតែមានការលើកទឹកចិត្តយ៉ាងខ្លាំង ដោយដឹងថាកូនរបស់នាងមានជីវិតរស់នៅ ហើយបានទទួលសេចក្តីស្រឡាញ់ពីគ្រួសារនោះ។

នៅក្នុងកម្មវិធីទូរទស្សន៍មួយអំពីការរំលូតកូន ខ្ញុំបានឮបុរសម្នាក់និយាយថា ស្ត្រីមានគភ៌ដោយការចាប់រំលោភ «អ្វីទាំងឡាយដែលកើតឡើងតាមរយៈការនេះគ្មានសិទ្ធិទេ ដោយសារតែវាជាលទ្ធផលនៃការរំលោភ»។ ប៉ុន្តែ តើធម្មជាតិរបស់ទារកដែលម្តាយត្រូវគេចាប់រំលោភនេះ ខុសពីក្មេងៗដទៃយ៉ាងដូចម្តេចទៅ? តើក្មេងខ្លះសក្តិសមនឹងរស់នៅដោយសារតែឪពុករបស់គេជាមនុស្សអស្ចារ្យឬ? ហើយហេតុអ្វីបានជាអ្នកគាំទ្រការជ្រើសរើស តែងតែនិយាយថា ទារកដែលមិនទាន់កើត គឺជាសិទ្ធិម្តាយមិនមែនរបស់ឪពុកទេ ប៉ុន្តែនៅពេលនាងត្រូវចាប់រំលោភពួកគេបែរជានិយាយថា ទារកនោះគឺជាសិទ្ធិរបស់ឪពុក មិនមែនជារបស់ម្តាយទេដូច្នេះ? ចំណុចនោះគឺថាមិនមែនជា *របៀប* ដែលទារកនោះចាប់កំណើតទេ ប៉ុន្តែទារកនោះបានចាប់កំណើតហើយ។ ទារកនោះមិនត្រូវបានគេមើលងាយថាជា «លទ្ធផលនៃការរំលោភទេ» ទារកនោះជា មានលក្ខណៈពិសេសនិងជាស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។

ការមានកូន និងចិញ្ចឹមកូនដែលគ្មានកំហុស ហើយធ្វើល្អច្រើនសម្រាប់ស្ត្រីរងគ្រោះ ប្រសើរជាងការសម្លាប់ក្មេងដែលគ្មានកំហុសដោយសារទង្វើដ៏អាក្រក់ ដើម្បីកាត់បន្ថយភាពតានតឹង (ការឈឺចាប់)។

## មានគភ៌ដោយការរួមភេទជាមួយសាច់ញាតិជិតស្និទ្ធ

ការរួមភេទជាមួយសាច់ញាតិជិតស្និទ្ធ គឺជាបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរ។ ដែលប្រព្រឹត្តិបែបនោះ គួរតែត្រូវបានដាក់ទោសហើយអ្នកដែលមានសិទ្ធិសម្រេចនោះ គួរតែយកស្ត្រីចេញពីទំនាក់ទំនងដែលនាងកំពុងតែមានជាមួយសាច់ញាតិជិតស្និទ្ធដែលបានរំលោភបំពានខាងផ្លូវភេទរបស់នាង។ អ្នករំលោភបំពាននោះ *មិនមែន* ស្ត្រី ឬក្មេងនោះទេ វាគឺជាបញ្ហា។ ការធ្វើអន្តរាគមគឺជាការការពារ ហើយការជួយដល់ស្ត្រីនោះគឺមិនមែនការសម្លាប់ក្មេងដែលគ្មានកំហុសទេ ប៉ុន្តែជាដំណោះស្រាយ។ ដោយមិនគិតពីជំនឿដែលថា កូនដែលម្តាយឪពុកត្រូវជាសាច់ញាតិជិតស្និទ្ធនឹងគ្នានោះ ពេលកើតមកនឹងមានលក្ខណៈមិនប្រក្រតី។បើទោះជាកូននោះកើតមកពិការ គេក៏នៅតែសក្តិសមនឹងរស់នៅ។

ហេតុអ្វីបានជាមនុស្ស «ក» គួរត្រូវបានសម្លាប់ ពីព្រោះតែមនុស្ស «ខ» រំលោភ និងបំពានខាងផ្លូវភេទម្តាយរបស់មនុស្ស«ក»ដូច្នេះ? បើសិនជាឪពុករបស់លោកអ្នកប្រព្រឹត្តិបទឧក្រិដ្ឋ តើអ្នកគួរចូលគុកជំនួសគាត់ឬ? បើសិនជានៅថ្ងៃនេះលោកអ្នកដឹងថា ឪពុករបស់អ្នកបានរំលោភម្តាយរបស់អ្នក ហើយកើតអ្នកមកតើអ្នកនឹងគិតថា ខ្លួនអ្នកគ្មានតម្លៃដើម្បីរស់នៅទៀតទេមែនឬ? មានស្ត្រីម្នាក់ដែលឮខ្ញុំនិយាយអំពីរឿងនេះ បានឡើងមកខាងមុខដោយយំខ្សឹកខ្សួល។ នាងបាននិយាយថា «ម្តាយរបស់ខ្ញុំត្រូវគេចាប់រំលោភនៅពេលដែលគាត់មានអាយុ១៣ឆ្នាំ។ គាត់បានឱ្យកំណើតខ្ញុំមក ហើយគាត់បានឱ្យខ្ញុំទៅកន្លែងចិញ្ចឹមក្មេង។ ជារៀងរាល់ពេលដែលខ្ញុំឮគេនិយាយថា ការរំលូតកូនដែលមានដោយការចាប់រំលោភនោះមិនជាបញ្ហាទេ ខ្ញុំបានគិតថា បើដូច្នោះ ខ្ញុំគ្មានសិទ្ធិដើម្បីរស់ទេ»។

ចូរដាក់ទោសអ្នកចាប់រំលោភ និងអ្នកបំពានផ្លូវភេទអ្នកផ្សេងវិញ។ ស្ត្រីមិនមែនជាទំនិញដែលគ្មានគុណភាពនោះទេ(ម្ហូបស្អុយ)«មិនមែនជាទំនិញទេ» ប៉ុន្តែជាមនុស្សដ៏មានតម្លៃបំផុតជាមួយនឹងគុណតម្លៃ និង កិត្តិយសដែលមិនអាចប្រព្រឹត្តអាក្រក់លើ ឬមើលងាយនាងទេ។ ដូចគ្នាដែរ ទារកមិនមែនជាជំងឺមហារីកដែលត្រូវតែកាត់ចេញទេ ប៉ុន្តែ គេជាមនុស្សដែលមានជីវិតម្នាក់។

## ការរំលូតបង្កើតឱ្យការប៉ះទង្គិចផ្លូវអារម្មណ៍

ក្រុមស្ត្រីដើម្បីជីវិតរបស់នៅ (ក្រុមការពារសិទ្ធិស្ត្រី) និយាយថា «មានស្ត្រីខ្លះបានរាយការណ៍ឱ្យដឹងថា បានជួបនឹងការរងទុក្ខពីបញ្ហាផ្លូវចិត្តដោយការរំលូតកូនយូរក្រោយពីបញ្ហាផ្លូវចិត្តដោយការរំលោភបានរសាយផុតទៅ»[៧]។ វាគឺជាការពិបាកណាស់ក្នុងការព្យាបាលស្ត្រីម្នាក់ដែលត្រូវគេចាប់រំលោភ បន្ទាប់មករស់នៅដោយភាពមានកំហុស និងភាពតប់ប្រមល់ដោយកូនរបស់នាងត្រូវបានសម្លាប់។ នៅថ្ងៃមួយនាងគង់នឹងយល់ ហើយអស់អ្នកដែលផ្ដល់ប្រឹក្សាឱ្យនាងរំលូតកូននោះនឹងមិននៅទីនោះ ដើម្បីជួយសម្រាលការឈឺចាប់ និងអារម្មណ៍នៃភាពមានកំហុសរបស់នាងទេ។

នៅក្នុងសៀវភៅរបស់ពួកគេមួយមានចំណងជើងថា *ជនរងគ្រោះ និងអ្នកមានជ័យជំនះ (Victims and Victors)* លោក ដេវិឌ រៀឌិន និងសហការីរបស់លោក បានដកស្រង់ទីបន្ទាល់របស់ស្ត្រី ១៩២ រូប ដែលមានបទពិសោធន៍មានគភ៌ដោយការចាប់រំលោភ និងរួមភេទជាមួយសាច់ញាតិជិតស្និទ្ធ និងក្មេង ៥៥ នាក់ ដែលម្ដាយមានគភ៌តាមរយៈការរំលោភបំពានខាងផ្លូវភេទ។ វាបង្ហាញឱ្យឃើញថា ជនរងគ្រោះដោយអំពើឃោរឃៅនិយាយដើម្បីខ្លួនគេ ហើយគំនិតរបស់ពួកគេអំពីការចាប់រំលោភ គឺស្ទើរតែដូចគ្នាទាំងស្រុង ហើយពិតជាផ្ទុយគ្នានឹងអ្វីដែលមនុស្សភាគច្រើននឹងព្យាករណ៍:

> ស្ត្រីទាំងអស់ដែលត្រូវបានសម្ភាសន៍នៅក្នុងការសិក្សាស្ទង់មតិដ៏ខ្លីនេះ បាននិយាយថា ពួកគេសោកស្ដាយចំពោះការការរំលូតកូនដែលមានគភ៌ដោយការចាប់រំលោភ និងការរួមដំណេកជាមួយសាច់ញាតិជិតស្និទ្ធ។ ក្នុងចំណោមអ្នកដែលផ្ដល់នូវគំនិតចូលរួមទាំងនោះ ប្រហែលជា៩០% បាននិយាយថា ពួកគេនឹងមិនលើកទឹកចិត្ត ឱ្យអ្នករងគ្រោះផ្សេងទៀតដោយការរំលោភបំពានខាងផ្លូវភេទឱ្យរំលូតកូនទេ។ ផ្ទុយទៅវិញ ក្នុងចំណោមស្ត្រីដែលកត់ត្រានៅក្នុងសៀវភៅ អ្នកដែលមានគភ៌ដោយការចាប់រំលោភ និងរួមដំណេកជាមួយសាច់ញាតិជិតស្និទ្ធ ហើយនៅទុកកូននោះឱ្យកើត គឺមិនមាននរណាម្នាក់សោកស្ដាយចំពោះការជ្រើសរើសរបស់ពួកគេទេ[៨]។

ការរំលូតកូន និងការចាប់រំលោភយ៉ាងឃោរឃៅនោះគឺដូចតែគ្នា ព្រោះទាំងពីរនេះ ធ្វើឡើងដោយអ្នកដែលមានអំណាចខ្លាំងជាងទៅលើមនុស្សដែលមានខ្សោយជាង។

ការរំលូតកូន មិនបាននាំការព្យាបាលមកដល់ជនរងគ្រោះដែលត្រូវគេរំលោភនោះទេ។ ការជំរុញឱ្យមានការដាក់ទោសប្រហារជីវិតទៅលើក្មេងដែលគ្មានកំហុសដោយការរំលោភខាងផ្លូវភេទនោះ មិនបានធ្វើអ្វីអាក្រក់ចំពោះអ្នកដែលរំលោភគេទេ ហើយក៏មិនមានអ្វីល្អដល់ស្ត្រីដែរ។

ការបង្កើតឱ្យមានអ្នករងគ្រោះទីពីរនោះ មិនបានលុបបំបាត់នូវការខូចកាលពីលើកមុនទេ។

ផ្នែកទី ៤

# បញ្ហាសំខាន់ផ្សេងទៀត

## ជំពូកទី ១៤
## ចុះចំណែកឯមនុស្សពិការ និងកូនដែលគេមិនចង់បាន?

មានអ្នកខ្លះនិយាយថា «វាគឺជាការអាក្រក់ខ្លាំងណាស់ ដែលទុកឱ្យទារកពិការកើតមកដែលរស់នៅជាជីវិតទុគ៌តនិងគ្មានតម្លៃ»។ ប៉ុន្តែ តើមនុស្សពិការគិតយ៉ាងណាដែរចំពោះជីវិតរបស់ពួកគេ? អ្នកជំងឺឆ្អឹងខ្នងត្រូវបានគេបានសួរថា តើភាពពិការរបស់ពួកគេ ធ្វើឱ្យជីវិតគ្មានតម្លៃឬ តើពួកគេគួរតែស្លាប់បន្ទាប់ពីកើតភ្លាមដែរឬទេ? ចម្លើយជាឯកច្ឆន្ទរបស់ពួកគេនោះ គឺមានអំណាចយ៉ាងខ្លាំង គឺថា ជាការពិតណាស់ពួកគេចង់រស់ ហើយពួកគេបានគិតថា សំណួរនោះ ពិតជាល្ងេល្ងើខ្លាំងណាស់»[១]។

ខ្ញុំបានឮអ្នកគាំទ្រការជ្រើសរើសម្នាក់និយាយអំពីក្មេងដែលមានភាពពិការធ្ងន់ធ្ងរថា តើត្រូវបង្ខំស្ត្រីម្នាក់ឱ្យនាំសត្វចម្លែកមួយចូលមកក្នុងពិភពលោកនេះឬ»? មានតែការប្រើពាក្យបែបនោះទេ បានបញ្ឆោតខ្លួនយើងផ្ទាល់ឱ្យជឿវាបាន។ ពាក្យថា *បន្លែ* គឺជាពាក្យដ៏មានប្រជាប្រិយភាពមួយទៀត សម្រាប់មនុស្សដែលគ្មានឱកាស (វប្បធម៌របស់អាមេរិច ប្រើពាក្យថា បន្លែដើម្បីជាការបង្អាប់បន្ថោកមនុស្សដែលអន់ជាងខ្លួន)។ កម្រងពាក្យនោះ បានបន្ទាបបន្ថោកមនុស្សនៅក្នុងកែវភ្នែករបស់យើង ប៉ុន្តែវាមិនបានផ្លាស់ប្តូរមនុស្សនោះឱ្យទៅជាអ្វីមួយផ្សេងបានទេ។

ស្វាយដែលជាំបម្រុងនឹងស្អុយ គឺនៅតែជាស្វាយ។ ឆ្កែដែលខ្វាក់ភ្នែក គឺនៅតែជាឆ្កែ។ ស្ត្រីចាស់ដែលវង្វេងវង្វាន់ នៅតែជាស្ត្រី។ ធម្មជាតិរបស់មនុស្សមិនអាចផ្លាស់ប្តូរដោយភាពពិការបានទេ។

មានវេជ្ជបណ្ឌិតខ្លះបានណែនាំឱ្យ «រំលូតកូនចេញ» បើសិនជាប្រវត្តិពូជពង្សរបស់ឪពុកម្តាយ អាចនាំមកនូវកំណើតរបស់កូនខុសពីធម្មតា។ ការពិសោធន៍តាមបទដ្ឋានត្រឹមត្រូវមួយពីលទ្ធភាពដែលនាំមកនូវភាពមិនប្រក្រតីរបស់ទារក បានធ្វើឡើងដោយការពិសោធន៍សុខភាព (រួមទាំងសុខភាពបន្តពូជ)។ នៅក្នុងឆ្នាំ ២០០០

ស្ថិតិជាតិបានរាយការណ៍ឱ្យដឹងថាក្នុងចំណោមស្ត្រី ១,០០០នាក់ មានស្ត្រីប្រហែលជា ២៨.៩% ទទួលការរងទុក្ខលំបាកយ៉ាងខ្លាំងពីការពិសោធន៍នេះ គឺមានកត្តាគ្រោះថ្នាក់ ៣ នាក់ក្នុងចំណោមស្ត្រី ១០០នាក់[២]។ មជ្ឈមណ្ឌលគ្រប់គ្រងជំងឺ បានធ្វើការប៉ាន់ប្រមាណនៅក្នុងការពិសោធន៍ដំបូងថា អត្រាស្លាប់របស់ទារកដែលមិនទាន់កើតដោយការរលូតគឺ «នៅចន្លោះ ១ ក្នុង ៤០០នាក់ និង ១ ក្នុង២០០នីតិវិធី»។ការសិក្សាក៏បានរកឃើញថា ភាពមិនប្រក្រតីជាជើងកែក គឺកើតឡើងលើស១០ដងបន្ទាប់ពីការពិសោធន៍សុខភាពដំបូង[៣]។

ការពិសោធន៍សុខភាព ត្រូវបានធ្វើឡើងជាប្រចាំ ដើម្បីកំណត់ពីភាពមិនប្រក្រតីរបស់ក្មេង ដើម្បីឱ្យឪពុកម្ដាយមានជម្រើសក្នុងការរំលូត។ គ្រោះថ្នាក់នៃការរំលូតដែលជាលទ្ធផលនៃការពិសោធន៍ខាងសុខភាព គឺស្មើរតែដូចគ្នាទាំងស្រុងនឹងគ្រោះថ្នាក់ សម្រាប់ក្មេងដែលមានភាពមិនប្រក្រតី[៤]។

## ជំនឿរបស់សង្គម

ការស្ទង់មតិមួយរបស់ គ្រូពេទ្យកុមារ និងគ្រូពេទ្យវះកាត់ផ្នែកកុមារ បានបង្ហាញឱ្យដឹងថា មានគ្រូពេទ្យ ២នាក់ក្នុងចំណោម៣នាក់ ដែលចង់បដិសេធវះកាត់ដើម្បីសង្គ្រោះជីវិតទារកដែលមានភាពមិនប្រក្រតី។ ប៉ុន្តែ យើងផ្តល់កន្លែងពិសេសសម្រាប់ចតរថយន្ត និងជណ្តើរយន្តសម្រាប់មនុស្សពិការ។ យើងបានស្នើសុំការផ្គត់ផ្គង់សម្រាប់ក្មេងៗដែលមានបញ្ហាជំងឺឆ្អឹងខ្នង និងក្មេងដែលមានភាពមិនប្រក្រតី។ យើងបានផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មវិធីកីឡាអូឡាំពិក និងគាំទ្រក្នុងពេលប្រកួត ពួកគេបានទទួលយើងដោយអំណរ។ ប៉ុន្តែ នៅពេលយើងឮស្ត្រីម្នាក់កំពុងតែពរពោះក្មេងប្រភេទនេះ យើងបែរជានិយាយថា «ចូរសម្លាប់វាទៅ»។

អ្វីដែលសំខាន់គឺ «មិនមានអង្គការសុខភាពផ្លូវចិត្តរបស់ឪពុកម្តាយណាសូម្បីតែមួយរារាំងមិនឱ្យមានការរំលូតកូនទេ[៥]។

ឧបមាថា បើសិនជាកូនរបស់លោកអ្នកដែលមានអាយុ ៦ឆ្នាំ ទៅជាខ្វាក់ភ្នែក ឬខ្វិនជើងទាំងពីរ។ ឥឡូវនេះ គាត់ក្លាយជាបន្ទុកមួយរបស់លោកអ្នក លោកអ្នកត្រូវចំណាយលុយជាច្រើនដើម្បីចិញ្ចឹមគាត់ រស់នៅដោយគ្មានភាពសុខស្រួល ហើយវាប៉ះពាល់ដល់សុខភាពផ្លូវចិត្តរបស់លោកអ្នក តើអ្នកគួរតែសម្លាប់គាត់ឬ? បើសិនជាច្បាប់ត្រូវបានអនុញ្ញាតិឱ្យសម្លាប់ក្មេងនោះបាន តើអ្នកនឹងធ្វើទេ? បើមិនធ្វើទេ ហេតុអ្វី?

លោកអ្នកមិនសម្លាប់កូនដែលពិការរបស់ខ្លួនទេ *ពីព្រោះតែលោកអ្នកស្គាល់កូននោះ*។ ប៉ុន្តែ លោកអ្នកហ៊ានសម្លាប់កូនរបស់ខ្លួនដែលមិនទាន់កើត ពីព្រោះតែលោកអ្នកមិនទាន់បានបីពរគេនៅនឹងដៃរបស់អ្នក ហើយមិនដែលឮសម្លេងរបស់កូននោះយំ គឺមិនបានផ្លាស់ប្តូរតម្លៃរបស់កូននោះ ឬកាត់បន្ថយការបាត់បង់របស់គេទេ។ ចូរផ្តល់ឱកាសដល់ខ្លួនអ្នកដើម្បីឱ្យស្គាល់កូន។ នោះលោកអ្នក*នឹង* ស្រឡាញ់គាត់។

ចុះចំណែកកូនដែលមិនមានការអភិវឌ្ឍន៍ផ្នែកខួរក្បាលពេញលេញវិញ? ដោយសារគាត់នៅតែស្លាប់ដដែលនោះលោកវេជ្ជបណ្ឌិតតែងតែណែនាំម្តាយឱ្យរំលូតកូននោះ។ ប៉ុន្តែ មានការមួយគួរដឹងថា កូននោះនឹងស្លាប់ ហើយជ្រើសរើសទុកឱ្យកូននោះរស់នៅ។ មានគ្រួសារជាច្រើនមានបទពិសោធដ៏អស្ចារ្យនេះ គឺបានដាក់ឈ្មោះបានបីពកូននោះ ជាប់ចិត្តស្រឡាញ់កូនដែលមានបញ្ហាខួរក្បាលបន្ទាប់ពីកើតមកនេះ។ នៅពេលដែលកូននោះស្លាប់ ពួកគេបានទទួលបទពិសោធន៍សោយសោកដ៏ពេញលេញ ចំពោះការស្លាប់តាមបែបធម្មជាតិនៃសមាជិករបស់គ្រួសារគេ។ នេះគឺផ្ទុយគ្នាទាំងស្រុងនឹងការសោកសោយ និងភាពមានកំហុសដែលមិនប្រក្រតីដែលកើតមកពីការបដិសេធន៍មិនឱ្យទារកចូលមកក្នុងគ្រួសារ ដោយការសម្លាប់ជីវិតរបស់កូននោះ។

គុណភាពរបស់សង្គមមួយ ត្រូវបានកំណត់ដោយរបៀបដែលសង្គមនោះប្រព្រឹត្តចំពោះសមាជិកដែលខ្សោយជាងខ្លួន។ ការសម្លាប់ក្មេងដែលគ្មានកំហុសមិនដែលនាំមកនូវភាពត្រឹមត្រូវ ពីព្រោះតែនោះជាការបន្ទូរបន្ទុករបស់អ្នកផ្សេងទៀតតែប៉ុណ្ណោះ។វាមិនមែនជាដំណោះស្រាយទេ ក្នុងការទម្លាក់ការឈឺចាប់ទៅលើមនុស្សម្នាក់ ដើម្បីឱ្យមនុស្សម្នាក់ទៀតរួចផុតពីការឈឺចាប់នោះ។ ប្រសិនជាយើងរំលូតកូនដោយព្រោះតែកូននោះពិការ វាធ្វើឱ្យគ្រោះថ្នាក់ដល់មនុស្សពិការទាំងអស់។

## បន្ទុកនៃការមិនចង់បាន

គំរោងធ្វើជាមាតាបិតាបាននិយាយថា កូនដែលឪពុកម្តាយមិនចង់បានគឺ«បានទទួលចំណាត់ថ្នាក់ទាប ជាពិសេសក្នុងជំនាញភាសា»។ វានិយាយថា ក្មេងជំទង់ដែលឪពុកម្តាយមិនចង់បាន «នៅសាលារៀនមិនសូវពូកែទេ» ហើយ «ទោះបីជាសាលាដាក់សម្ពាធយ៉ាងក៏ដោយក៏រៀនមិនសូវពូកែដែរ» ហើយ «ពួកគេបានទទួលការអប់រំខ្ពស់តិចជាងពាក់កណ្តាលនៃកូនដែលឪពុកម្តាយចង់បានមក»[៦]។

ខ្ញុំមិនបានសួរនាំឱ្យច្បាស់ពីចំណុចដែលគេសិក្សាឃើញឱ្យឱ្យបានស៊ីជម្រៅទេ។ ពួកគេប្រាប់យើងនូវអ្វីដែលយើងគួរតែដឹងពីសារៈសំខាន់នៃការដែលយើងចង់

បានកូនរបស់យើង ព្រមទាំងដោយមិនខ្វល់ថា អ្នកគាំទ្រការជ្រើសរើស ខិតខំតស៊ូមតិជាមួយយើងតាមរយៈការសិក្សាស្រាវជ្រាវប្រភេទនោះ ដើម្បីឱ្យគេគិតថា «ការរំលូតកូន» ដែលឪពុកម្ដាយមិនចង់បានជាការត្រឹមត្រូវនោះ។

មានស្ត្រីមានគភ៌ដែលខ្លួនមិនចង់មាន ប៉ុន្តែ *មិនមានកូនដែលគេមិនចង់បានបែបនោះទេ*។ ប្រហែលជាមានមនុស្សខ្លះមិនចង់បានទេ ហើយក៏ពិតជាមានមនុស្សខ្លះចង់បានកូននោះយ៉ាងខ្លាំងដែរ។

មានគ្រួសារជនជាតិអាមេរិកកាំងប្រហែលជា ១.៣ លានគ្រួសារចង់បានកូនមកចិញ្ចឹម ហើយមានគ្រួសារខ្លះមានការភ័យខ្លាចយ៉ាងខ្លាំងថា ការយកកូនគេមកចិញ្ចឹម គឺជាប្រភពនៃភាពមហន្តរាយ។ មានការចង់បានកូនប្រភេទនោះ ដែលទីផ្សារងងឹតបានបង្កើតឡើងដើម្បីលក់កូនម្នាក់ក្នុងតម្លៃ $៥០,០០០។ គឺមិនមែនគ្រាន់តែ «ទារកធម្មតាទេ» ដែលឪពុកម្ដាយចង់បាននោះ មានមនុស្សជាច្រើនមានការស្នើសុំកូនយ៉ាងពិសេសរួមទាំងក្មេងដែលមានភាពមិនប្រក្រតីផងដែរ[៧]។

មានកូនជាច្រើនដែលដំបូងឡើយម្ដាយរបស់ពួកគេមិនចង់បាន ក្រោយមកបន្ទាប់ពីជិតគ្រប់ខែកើត ម្ដាយរបស់គេចង់បានយ៉ាងខ្លាំងទៅវិញ ប្រហែលជាស្រឡាញ់កាន់តែខ្លាំងទៀតបន្ទាប់ពីកើត។ គួរឱ្យសោកស្ដាយដែលនឹកចង់បានកូនរបស់ខ្លួននៅក្នុងខែទីប្រាំមួយ ត្រូវបានរំលូតកូនរបស់ខ្លួននៅខែទីបី។

លើសពីនេះទៀត កូនជាច្រើនដែលម្ដាយរបស់គេចង់បាននៅពេលកើត តែបែរជាមិនចង់បាននៅពេលដែលកូននោះស្រែកយំនៅម៉ោងពីររំលងអធ្រាតបន្ទាប់ពីកើតបាន ៦សប្ដាហ៍។ មិនថា ជាម្ដាយនោះចង់បានកូននោះឬក៏អត់នោះទេ តើកូននោះសក្តិសមនឹងរស់នៅទេ? បើការសម្លាប់កូនជាការស្របច្បាប់ ហេតុអ្វីមិនធ្វើបន្ទាប់ពីកើត?

បញ្ហារបស់កូនដែលឪពុកម្ដាយមិនចង់បាន គឺជាការជជែកវែកញែកដ៏ល្អមួយសម្រាប់ការដែលចង់បានកូន។ ប៉ុន្តែ វាគឺជាការជជែកដ៏លេលាដើម្បីសម្លាប់ពួកគេនោះ។

គំនិតដ៏អាក្រក់មួយក្នុងចំណោមគំនិតដ៏អាក្រក់ជាច្រើនរបស់អ្នកគាំទ្រការជ្រើសរើស គឺខំបង្ហាញថា ការរំលូតកូន គឺជាប្រយោជន៍ដ៏ប្រសើរបំផុតសម្រាប់ទារក។ នេះគឺជារឿងដ៏ភ្លីភ្លើ ហើយគួរឱ្យអស់សំណើចណាស់។ ទារកតូចមួយនៅក្នុងផ្ទៃត្រូវបានហែកដៃហែកជើង តើនេះជាប្រយោជន៍របស់ *ទារក* នោះឬ? វាស្រដៀងគ្នានឹង

ថៅហ្វាយរបស់ទាសករនិយយថា ភាពជាទាសករ គឺជាប្រយោជន៍ដ៏ធំបំផុតរបស់ពួកស្បែកខ្មៅ។ (តើយើងកំពុងតែលែងសើចជាមួយអ្នកណា?)

មានមនុស្សខ្លះនិយាយថា «ខ្ញុំមិនអាចមានកូននេះបានទេ ពីព្រោះតែខ្ញុំមិនអាចចិញ្ចឹមគេឱ្យរស់នៅក្នុងភាពប្រសើរបានទេ»។ តើអ្វីជាដំណោះស្រាយរបស់ពួកគេក្នុងដែលដែលមិនអាចចិញ្ចឹមគេឱ្យបានល្អ? តើត្រូវយកជីវិតតែមួយដែលកូនមានចេញពីកូននោះឬ?

## កូនទាំងអស់ គឺជាកូនដែលគេចង់បាន

*មិនចង់បាន* មិនមែននិយាយអំពីកូនទេ ប៉ុន្តែគឺជាឥរិយាបថរបស់មនុស្សចាស់ខ្លះចំពោះក្មេងម្នាក់។ បញ្ហាពិតប្រាកដនោះ គឺមិនមែនជាក្មេងដែលមិនចង់បានទេ គឺជាចាស់ដែលមិនចង់បាន។

«ការចង់បាន» គឺជាគំនិតរបស់មនុស្សម្នាក់ ហើយអារម្មណ៍ដែលអាចផ្លាស់ប្តូរបានចំពោះអ្នកផ្សេង។ ក្មេងដែល «ឪពុកម្តាយមិនចង់បាន» គឺជាមនុស្សពិតៗម្នាក់ មិនថាជាអ្នកណាគិតចំពោះក្មេងនោះយ៉ាងម៉េចទេ។ តម្លៃរបស់ស្ត្រីនោះ ពេលមួយត្រូវបានកំណត់ដោយបុរសម្នាក់ចង់បានគេឬក៏អត់។ ហើយពេលនេះ តម្លៃរបស់ក្មេងម្នាក់ត្រូវបានកំណត់ដោយម្តាយចង់បានក្មេងនោះឬក៏អត់។ រឿងទាំងពីរនេះ គឺអយុត្តិធម៌ខ្លាំងណាស់។ ពាក្យស្លោករបស់ គម្រោងធ្វើជាមាតាបិតានិយាយថា «កូនទាំងអស់ គឺជាកូនដែលគេចង់បាន» គឺជាអ្វីដែលយើងទាំងអស់គ្នាគួរតែយល់ស្រប។ កន្លែងដែលយើងមិនឯកភាពគ្នា គឺស្ថិតនៅក្នុងភាពត្រឹមត្រូវដើម្បីបញ្ចប់ប្រយោគ។ តើលោកអ្នកគិតថា ប្រយោគគួរតែបញ្ចប់យ៉ាងណា?

- កូនទាំងអស់ គឺជាកូនដែលគេចង់បាន ដូច្នេះ...ចូរយើងដាក់កូននោះនៅក្នុងផ្ទះដែលមានអ្នកចង់បានគេ ហើយចូររៀនស្រឡាញ់ក្មេងឱ្យកាន់តែច្រើនឡើង។
- កូនទាំងអស់ គឺជាកូនដែលគេចង់បាន ដូច្នេះ...ចូរយើងកំណត់ឱ្យដឹងថាកូនណាដែលយើងមិនចង់បាន មុនពេលដែលកូននោះកើតមក ហើយសម្លាប់កូននោះដោយការរំលូតទៅ។

មនុស្សគ្រប់គ្នាយល់ស្របថា កូនទាំងអស់គួរតែត្រូវបាន គេចង់បាន។ សំណួរតែមួយគត់នោះគឺថា៖ តើយើងគួរយក *ការដែលមិនចង់បាន* ចេញ ឬយក *កូន* ចេញ?

នៅពេលដែលយើងនិយាយពីទារកដែលមិនទាន់កើត សិទ្ធិជ្រើសរើសរំលូតកូន គឺឆ្លុះបញ្ជាំងយ៉ាងច្បាស់ នៅក្នុងពាក្យស្លោកខុសៗគ្នា ដោយពាក្យស្លោកមួយមើលទៅមិនសូវជាល្អគឺថា «កូនដែលគេមិនចង់បាន គឺជាកូនម្នាក់ដែលស្លាប់»

# ជំពូកទី ១៥
# តើការរំលូតកូនទប់ស្កាត់ការរំលោភបំពានលើកុមារដែរឬទេ?

ក្មេងស្រីជំទង់ម្នាក់កើតបានកូនម្នាក់នៅក្នុងផ្ទះសំណាក់មួយ។ នាង និងមិត្តប្រុសរបស់នាងបានដាក់ទារកនោះទាំងរស់ទៅក្នុងថង់ផ្លាស្ទិក ហើយបោះចោលទៅក្នុងធុងសំរាម។ ម្តាយអាយុដប់ប្រាំពីរឆ្នាំម្នាក់ ដែលនៅរៀនបានជ្រមុជកូនរបស់នាងនៅក្នុងទឹកទន្លេ ក្រោយពីនាងមិនអាចរកបានអ្នកមើលកូនឱ្យ។ មានរឿងដែលស្រដៀងគ្នាបែបនេះច្រើនណាស់។

ការរំលូតកូនត្រូវបានដាក់ឱ្យស្របច្បាប់ជាលើកដំបូងនៅក្នុងឆ្នាំ១៩៧៣ ពេលនោះករណីអំពីការរំលោភបំពានលើកុមារនៅសហរដ្ឋអាមេរិក មានប្រហែលជា ១៦៧,០០០ ករណី[១]។ យោងទៅតាមព័ត៌មានមកពីមន្ទីរសុខាភិបាល និងសេវាសាធារណៈរបស់សហរដ្ឋអាមេរិក មានកុមារប្រហែលជា ៩០៣,០០០ នាក់ បានក្លាយជាជនរងគ្រោះដែលបណ្តាលមកពីការរំលោភបំពាននៅក្នុងអំឡុងឆ្នាំ ២០០១ ជាចំនួនមួយដែលច្រើនជាងមុនប្រាំដង[២]។

ការកើនឡើងនៅក្នុងការរំលោភបំពានលើកុមារកាន់តែអាក្រក់ទៅទៀត ដោយព្រោះមានកុមារជនជាតិអាមេរិក ៤៦ លាននាក់ ដែលត្រូវបានសម្លាប់តាមរយៈការវះកាត់យកកូនចេញ (និង ការរំលូតកូនដោយប្រើថ្នាំ ដែលគ្មានកំណត់ត្រាអំពីចំនួនកុមារដែលបានស្លាប់ទេ) មិនត្រូវបានចាត់ទុកថាជាជនរងគ្រោះដែលបណ្តាលមកពីការរំលោភបំពានលើកុមារទេ។ ប៉ុន្តែ ការរំលូតកូនគឺជាការរំលោភបំពានលើកុមារតាំងពីដំណាក់កាលដំបូងបំផុត ដែលនាំឱ្យមានការបាត់បង់ជីវិតច្រើនជាងគេ។ មតិដែលថា ការរំលូតកូនទប់ស្កាត់ការរំលោភបំពានលើកុមារ មានលក្ខណៈដូចគ្នានឹងគំនិតដែលថា ការសម្លាប់ប្រពន្ធទប់ស្កាត់ការរំលោភបំពានលើប្រពន្ធ។ មនុស្សដែលស្លាប់លែងត្រូវគេរំលោភបំពានទៀតហើយ...ប៉ុន្តែការទប់ស្កាត់ការរំលោភបំពានដោយការសម្លាប់ពួកគេ គឺជាភាពត្រឹមត្រូវក្លែងក្លាយ។

ហេតុអ្វីបានជាកុមារត្រូវគេបំពានកាន់តែច្រើន ចាប់ពីការរំលូតកូនត្រូវបានដាក់ឱ្យស្របច្បាប់មក? ពីព្រោះ *ការរំលូតកូនបានផ្លាស់ប្តូររបៀបគិតរបស់យើងអំពីកុមារ*។

## របកគំហើញនៅក្នុងការសិក្សា

អ្នកគាំទ្រច្បាប់រំលូតកូននិយាយថា «ការមានកូនដែលគេមិនចង់បានកាន់តែច្រើន នាំឱ្យមានការរំលោភបំពានលើកុមារកាន់តែច្រើន» ប៉ុន្តែការសិក្សាទាំងឡាយមិនយល់ស្របជាមួយគំនិតនេះទេ។

លោក អេតវត ឡេណូស្គី (Edward Lenoski) ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យរដ្ឋកាលីហ្វ័រញ៉ាភាគខាងត្បូង (University of Southern California) បានធ្វើការសិក្សាដ៏សំខាន់ទៅលើកុមារ ៦៧៤ នាក់ ដែលត្រូវគេរំលោភបំពាន។ គាត់បានរកឃើញថា ឪពុកម្តាយ ៩១ភាគរយ សារភាពថា ពួកគេចង់បានកូនដែលពួកគេបានរំលោភបំពាននោះ[៣]។ គំនិតរបស់អ្នកគាំទ្រការជ្រើសរើសគឺថា កូនដែលគេមិនចង់បាននឹងទទួលការរំលោភបំពាន ស្តាប់មើលទៅហាក់បីដូចជាត្រឹមត្រូវ ប៉ុន្តែការសិក្សាដែលបានធ្វើឡើងរហូតមកដល់ពេលបច្ចុប្បន្ននេះបង្ហាញថា គំនិតនេះខុសឆ្គងទេ។

«ការសិក្សាបង្ហាញថា ការរំលោភបំពានលើកុមារកើតមានជាញឹកញាប់នៅក្នុងចំណោមម្តាយដែលធ្លាប់មានការរំលូតកូនពីមុនមក»[៤]។ ការសិក្សារបស់បណ្ឌិត ភីលីព ណេ (Philip Ney) បង្ហាញឱ្យឃើញថា ហេតុការណ៍បែបនេះមួយផ្នែកគឺដោយសារតែអារម្មណ៍ខុសឆ្គង និងតានតឹង ដែលបណ្តាលមកពីការរំលូតកូនហើយរាំងសមត្ថភាពរបស់ម្តាយនៅក្នុងការផ្សាភ្ជាប់ចំណងទំនាក់ទំនងជាមួយកូនក្រោយៗទៀត[៥]។លោកចងក្រងជាឯកសារថា ការរំលូតកូនបន្ថយសមត្ថភាពរបស់ម្តាយក្នុងការទប់ទល់នឹងអារម្មណ៍ខឹងចំពោះកូនតូច[៦]។

ទាំងឪពុក ទាំងម្តាយឈ្នះអារម្មណ៍ ពីកំណើតរបស់ពួកគេឱ្យមើលថែកូនដែលត្រូវការជំនួយ ពេលដែលពួកគេជ្រើសរើសយកការរំលូតកូន។ ក្រោយពីពួកគេបានគាបសង្កត់សភាវគតិការពារនោះរួចហើយ ពួកគេលែងសូវមានសមត្ថភាពទប់ទល់នឹងអារម្មណ៍ខឹងចំពោះភាពត្រូវការជំនួយរបស់កូនសម្លេងយំរបស់កូនដែលចេះដើរ ឬកំហុសរបស់កូនដែលមិនទាន់គ្រប់អាយុចូលរៀន[៧]។

ឥរិយាបថដែលនាំឱ្យមានការរំលូតកូន គឺជាឥរិយាបថតែមួយដែលនាំឱ្យមានការរំលោភបំពានលើកុមារ។ លើសពីនេះទៅទៀត ប្រសិនបើនាងមិនរំលូតកូនទេ ម្តាយអាចសម្លឹងមើលកូនអាយុបីឆ្នាំរបស់នាង ហើយគិតថា «ខ្ញុំមានសិទ្ធិនឹងរំលូតកូននេះ»។ កូនជំពាក់នាងអ្វីៗទាំងអស់ តែនាងគ្មានជំពាក់អ្វីកូនទេ។ គំនិតនេះប៉ះទង្គិចដល់ការទាមទារឱ្យមានការលះបង់ពីឪពុកម្តាយ។ ទោះបីជាអនុសម្បជញ្ញៈក៏ដោយ

នោះមានគំនិតថា បើសម្លាប់កូនមុនពេលកើតគ្មានបញ្ហា ទះកំផ្លៀងកូននៅពេលនេះក៏គ្មានបញ្ហាដូចគ្នាដែរ។

នៅក្នុងចំណោមកុមារជនជាតិអាមេរិកប្រាំពាន់នាក់ដែលត្រូវបានសម្លាប់ជារៀងរាល់ឆ្នាំ (តួលេខនេះមិនរាប់បញ្ចូលការរំលូតកូនទេ) ៩៥% ត្រូវបានឪពុកម្ដាយរបស់ពួកគេតែម្នាក់ ឬទាំងពីរនាក់សម្លាប់[៤]។ មានផ្នត់គំនិតរាលដាលថា កូនគឺជាកម្មសិទ្ធិរបស់ឪពុកម្ដាយ។ មនុស្សពេញវ័យគិតថា ពួកគេមានសិទ្ធិបោះកូនចោល ជាសិទ្ធិតែមួយដែលសង្គមឱ្យពួកគេមុនពេលដែលកូនកើតមក។ នៅពេលដែលការរំលោភបំពានកុមាររក្លោបក្ដាប់សង្គមមួយ វាមិនត្រឹមតែកំណត់ទៅរកមនុស្សមួយក្រុមប៉ុណ្ណោះទេ។ ប្រសិនបើកុមារដែលមិនទាន់កើតមកមិនមានសុវត្ថិភាពទេ គ្មានកុមារណាម្នាក់មានសុវត្ថិភាពឡើយ។

លោក ភីធើរ ស៊ីងងើរ និយាយថាៈ

> «បើនិយាយខាងសីលធម៌ គ្មានព្រំដែនច្បាស់លាស់រវាងទារកទើបកើតដែលមិនមែនជាមនុស្សជាមួយនឹងកុមារទេ។ នៅក្នុងសៀវភៅរបស់យើង ដែលមានចំណងជើងថា «*តើទារកគួរតែមានជីវិតរស់នៅដែរឬទេ? (Should the Baby Live?)*» សហការីរបស់ខ្ញុំ ហែលហ្គា យូស (Helga Kuhse) និងខ្ញុំ បានផ្ដល់យោបល់ថា រយៈពេលម្ភៃប្រាំបីថ្ងៃក្រោយពេលកើត ទើបគេទទួលស្គាល់ថា ទារកមានសិទ្ធិរស់នៅដូចជាមនុស្សដទៃទៀត[៥]»។

តើកុមារមានសិទ្ធិរស់នៅ ទាល់តែម្ភៃប្រាំបីថ្ងៃក្រោយកើតឬ? ហេតុអ្វីមិនរង់ចាំរហូតដល់ប្រាំមួយខែ? ឬប្រាំមួយឆ្នាំ? ការសម្លាប់ក្មេងអាយុប្រាំឆ្នាំ ដប់ឆ្នាំ ឬដប់ប្រាំឆ្នាំ គឺជាការរំលូតកូនក្រោយពេលកើត។ ដូចដែលលោក ស៊ីងងើរ បានបង្ហាញរួចមកហើយ នៅពេលដែលលោកអ្នកគិតថា សម្លាប់មនុស្សគ្មានបញ្ហាទេ នោះមានភាពទូលាយនៅក្នុងការសម្លាប់មនុស្សវ័យណាក៏បាន ដោយព្រោះហេតុផលផ្សេងៗ។

ដំណោះស្រាយសម្រាប់កុមារដែលត្រូវគេរំលោភបំពានក្រោយដែលកើតមកហើយ មិនមែនជាទារកដែលនៅក្នុងផ្ទៃទេ។ ដំណោះស្រាយសម្រាប់ការរំលោភបំពានលើកុមារ មិនមែនជាការប្រព្រឹត្តិការរំលោភបំពាន*ពីដំបូង*ទេ។ ការធ្វើបែបនេះមិនជួយដោះស្រាយអ្វីទាល់តែសោះ។

# ជំពូកទី ១៦
# ខ្លួនផ្ទាល់ប្រឆាំងនឹងការរំលូតកូន ប៉ុន្តែគាំទ្រការជ្រើសរើសឬ?

មនុស្សជាច្រើននិយាយថា «ខ្ញុំមិនគាំទ្រការរំលូតកូនទេ ប៉ុន្តែខ្ញុំគាំទ្រឱ្យមានការជ្រើសរើស»។ តើលោកអ្នកឆ្លើយតបយ៉ាងដូចម្តេចទៅកាន់អ្នកដែលនិយាយថា «ខ្ញុំមិនគាំទ្រការរំលោភទេ ខ្ញុំគ្រាន់តែមិនប្រឆាំង»។ គោលជំហររបស់គាត់ប្រាប់ថា ការរំលោភមិនធ្វើឱ្យអ្នកណាម្នាក់ឈឺចាប់ទេ ហើយពេលខ្លះមិនខុសទេ។ លោកអ្នកនឹងឆ្លើយតបវិញថា «មិនប្រឆាំងនឹងការរំលោភ គឺគាំទ្រការរំលោភហើយ»។ ចម្លើយដូចគ្នាដែរ បើគាំទ្រការជ្រើសរើសរំលូតកូន គឺគាំទ្រការរំលូតកូនហើយ។

សម្លឹងមើលមួយភ្លែត មានពាក្យបិទប្រកាសយ៉ាងត្រឹមត្រូវថា «ប្រឆាំងការរំលូតកូនឬ? មិនត្រូវមានឡើយ»។ ពាក្យនេះមាននៅលើយន្តហោះ កន្លែងទាត់បាល់ ឬភោជនីយដ្ឋាន ប៉ុន្តែមិនសំដៅទៅរកការចាប់រំលោភ ការធ្វើទារុណកម្ម ការចាប់ជម្រិត ឬឃាតកម្មទេ។

## គោលជំហរនៅកណ្តាលឬ?

មនុស្សមួយចំនួនគិតថា ការដែលបុគ្គលផ្ទាល់ខ្លួនប្រឆាំងនឹងការរំលូតកូនតែជឿថាអ្នកដទៃមានសិទ្ធិជ្រើសរើស គឺជាការសម្របសម្រួលរវាងគោលជំហរគាំទ្រការរំលូតកូន និងគោលជំហរគាំទ្រជីវិត។ វាមិនមែនដូច្នោះទេ។ អ្នកគាំទ្រការជ្រើសរើសដូចគ្នានឹងអ្នកគាំទ្រការរំលូតកូនដែរ។ សម្រាប់ទារកដែលស្លាប់ អ្នកគាំទ្រការរំលូតកូន និងអ្នកគាំទ្រការជ្រើសរើស មិនខុសប្លែកគ្នាទេ សុទ្ធតែជាអ្នកដែលមិនព្រមការពារពួកគេ។

ហេតុផលតែមួយគត់ក្នុងការប្រឆាំងជាមួយនឹងការរំលូតកូន គឺជាហេតុផលដែលជម្រុញយើងឱ្យប្រឆាំងនឹងមនុស្សដទៃទៀតដែលរំលូតកូន គឺជាការសម្លាប់ក្មេង។ បុគ្គលផ្ទាល់ខ្លួនប្រឆាំងនឹងការរំលូតកូន តែគាំទ្រសិទ្ធិអ្នកដទៃទៀតនៅក្នុងការរំលូត

កូនគឺជាការប្រឆាំងនឹងខ្លួនឯង។ ការធ្វើបែបនោះប្រៀបបីដូចជាការនិយាយថា «ខ្ញុំខ្លួនឯងប្រឆាំងនឹងការរំលោភបំពានលើកុមារ តែខ្ញុំការពារសិទ្ធិអ្នកជិតខាងរបស់ខ្ញុំឱ្យរំលោភបំពានលើកូនរបស់គាត់ ប្រសិនបើគាត់ជ្រើសរើសធ្វើបែបនោះ» ឬ «ខ្ញុំខ្លួនឯងប្រឆាំងនឹងការមានទាសករ ប៉ុន្តែប្រសិនបើអ្នកដទៃទៀតចង់មានទាសករ នោះមិនពាក់ព័ន្ធជាមួយខ្ញុំទេ» ឬ «ខ្ញុំខ្លួនឯងមិនគាំទ្រការវាយប្រពន្ធទេ ខ្ញុំមិនចង់ដាក់គំនិតនេះលើមនុស្សដទៃទៀតទេ ដូច្នេះខ្ញុំគាំទ្រឱ្យមានសិទ្ធិវាយប្រពន្ធ»។

អ្នករៀបចំកម្មវិធីតាមវិទ្យុម្នាក់បានប្រាប់ខ្ញុំថា នាងអាក់អន់ចិត្ត ពីព្រោះមនុស្សមួយចំនួនហៅនាងថា«អ្នកគាំទ្រការរំលូតកូន» មិនព្រមហៅនាងថា «អ្នកគាំទ្រការជ្រើសរើស»។ ខ្ញុំបានសួរនាងតាមទូរស័ព្ទវិញថា «ហេតុអ្វីបានជាអ្នកមិនចង់ឱ្យគេហៅថាជាអ្នកគាំទ្រការរំលូតកូន? តើការរំលូតកូនមានអ្វីខុសឬ?»។ នាងបានឆ្លើយតបមកវិញថា «ការរំលូតកូនពិបាកណាស់ គ្មានមនុស្សណាចង់ទេ»។ ខ្ញុំបាននិយាយថា «ខ្ញុំមិនយល់ទេ។ តើអ្វីធ្វើឱ្យការរំលូតកូនពិបាក? ហេតុអ្វីបានជាគេមិនចង់រំលូតកូន?»។ នាងបានឆ្លើយភ្លាមទាំងមានអារម្មណ៍អាណិតអាសូរថា«ការរំលូតពិបាកពីព្រោះនោះជាការសម្លាប់កូនខ្លួនឯង»។

ពេលដែលនាងនិយាយរួចហើយ ទើបនាងដឹងខ្លួន ប៉ុន្តែវាយឺតពេលទៅហើយ នៅពេលដែលមិនប្រយ័ត្ន នាងបានបង្ហាញចេញអ្វីដែលនាងបានដឹង អ្វីដែលមនុស្សគ្រប់គ្នាដឹង គ្រាន់តែពួកគេសារភាពការពិតប៉ុណ្ណោះ: *ការរំលូតកូនពិបាក ដោយព្រោះវាខុស ដោយព្រោះនោះគឺជាការសម្លាប់កូន*។ គ្មានហេតុផលណាល្អណាគ្រប់គ្រាន់នឹងសម្លាប់កូនទេ។

## ជំពូកទី ១៧

# ចុះចំណែកការឱ្យកូនទៅគេយកទៅចិញ្ចឹមវិញ?

ហេតុផលដ៏សំខាន់មួយរបស់ក្រុមអ្នកគាំទ្រការជ្រើសរើស គឺថាស្ត្រី គ្មានជម្រើសអ្វីផ្សេងទៀតក្រៅតែពីការរំលូតកូនទេ។ ក្រុមអ្នកគាំទ្រការជ្រើសរើស អាចហៅថាជាក្រុមអ្នកគាំទ្រការរំលូតកូន និងគ្មានជម្រើស។ ស្ត្រីជាច្រើនធ្វើបន្ទាល់ថា សម្រាប់ពួកគេ «គាំទ្រការជ្រើសរើស» មានន័យថា «គ្មានការជ្រើសរើស»។

ឪពុក ម្ដាយ មិត្តប្រុស ប្ដី គ្រូបង្រៀន អ្នកប្រឹក្សាយោបល់នៅសាលារៀន បណ្ឌិត គិលានុបដ្ឋាក ប្រព័ន្ធផ្សព្វផ្សាយ និងមនុស្សនៅក្នុងជំនាន់នេះ ជាញឹកញាប់បង្ខំស្ត្រីដែលមានផ្ទៃពោះឱ្យធ្វើការជ្រើសរើសមួយ ដែលមនសិការរបស់នាងប្រាប់នាងថាខុស ហើយការជ្រើសរើសនោះគឺជាការជ្រើសរើសរបស់មនុស្សដទៃទៀត មិនមែនជាការជ្រើសរើសរបស់នាងទេ (ប៉ុន្តែ តើ *ពួកគេ* នៅឯណា ពេលដែលនាងយល់ច្បាស់ពីអ្វីដែលនាងបានធ្វើនោះ?)។

តើស្ត្រីពិតជា ចង់ធ្វើការរំលូតកូនមែនឬ? ហ្វ្រេត ឌឺរីកា ម៉ាធូវេស-ហ្គ្រីន (Frederica Mathewes-Green) ជាអតីតប្រធានសមាគមន៍ស្ត្រីដើម្បីជីវិត និយាយថា «គ្មានស្ត្រីណាចង់ធ្វើការរំលូតកូន ដូចជានាងចង់បរិភោគអាហារនោះទេ។ នាងចង់ធ្វើការរំលូតកូន ព្រោះនាងដូចជាសត្វដែលជាប់អន្ទាក់ ចង់ខំផ្ដាច់ជើងខ្លួនឯង។ ការរំលូតកូន គឺជាការជ្រើសរើសដ៏តក់ស្លុតមួយដើម្បីគេចចេញពីស្ថានភាពដ៏អាក្រក់ដែលបណ្ដាលមកពីអំពើហិង្សា ឬការបាត់បង់ខ្លួនឯង[១]»។

ការរំលូតកូនមិនមែនជាការជ្រើសរើសដោយស្ម័គ្រចិត្តទេ។ ស្ត្រីភាគច្រើននឹងជ្រើសរើសមិនរំលូតកូន ប្រសិនបើពួកគេដឹងថា ពួកគេនឹងទទួលបានការគាំទ្រខាងស្មារតី និងខាងហិរញ្ញវត្ថុតាមដែលពួកគេត្រូវការនោះ។

ស្ទើរតែពីរភាគបីនៃស្ត្រីដែលបានរំលូតកូន ពណ៌នាថាខ្លួន«ត្រូវបានបង្ខំឱ្យរំលូតកូនដោយព្រោះតែកាលៈទេសៈរបស់ពួកគេ...ជាង ៨៤ ភាគរយនិយាយថា ពួកគេនឹងទុកកូនរបស់ពួកគេ បើកាលៈទេសៈមិនអាក្រក់ទេនោះ»[២]។

## ជម្រើសដែលកម្រនឹងលើកឡើង

ក្រុមប្រឹក្សាជាតិទទួលបន្ទុកការឱ្យកូនទៅគេយកទៅចិញ្ចឹម ប្រមើលមើលថា មានប្ដីប្រពន្ធ ១.៣ លាននាក់ កំពុងរង់ចាំដើម្បីសុំកូនយកទៅចិញ្ចឹម[៣]។ ប៉ុន្តែជារៀងរាល់ឆ្នាំ នៅពេលដែលទារក ១.៣ លាននាក់ កំពុងត្រូវបានសម្លាប់ដោយសារការរំលូតកូន មានទារកតិចជាង ៥០,០០០ នាក់ សម្រាប់សុំយកទៅចិញ្ចឹមជាកូន។ នេះមានន័យថាទារកសម្រាប់សុំចិញ្ចឹមជាកូនកើតមកម្នាក់ ទារកសាមសិបនាក់ដទៃទៀតត្រូវបានសម្លាប់។ គ្រួសារមួយសុំបានកូនទៅចិញ្ចឹម សែសិបគ្រួសារទៀតតម្រង់ជួររង់ចាំ[៤]។

នៅក្នុងសង្គមមួយដែលឱ្យតម្លៃលើការជ្រើសរើស ហេតុអ្វីបានជាវេជ្ជបណ្ឌិត សាលារៀន មន្ទីរផ្នែករៀបចំផែនការគ្រួសារ និងមន្ទីររំលូតកូន មិនត្រូវបានតម្រូវឱ្យបង្ហាញដល់ស្ត្រីអំពីការជ្រើសរើស *ទាំងអស់* ដែលមាន រួមទាំងការសុំយកកូនទៅចិញ្ចឹម? មិត្តភក្តិម្នាក់បានប្រាប់យើងថា «ពេលដែលខ្ញុំនៅធ្វើជាអ្នកប្រឹក្សាយោបល់នៅក្នុងមន្ទីររំលូតកូនមួយកន្លែង ខ្ញុំមិនបានទទួលព័ត៌មានអំពីជម្រើសផ្សេងទៀតទេ។ ខ្ញុំមិនដែលបានឱ្យយោបល់ឱ្យទុកកូន ព្រោះមានការសុំយកកូនទៅចិញ្ចឹមទេ។ ខ្ញុំមិនដឹងទាល់តែសោះទាក់ទងនឹងពេទ្យ រួមទាំងការវិវឌ្ឍន៍របស់ទារកផង។ ខ្ញុំមិនបានទទួលការបណ្ដុះបណ្ដាលអំពីបញ្ហាទាំងនេះទេ។ ការងាររបស់ខ្ញុំ គឺឱ្យយោបល់ស្ត្រីធ្វើការរំលូតកូន»។

ដោយមានការប្រឹក្សាយោបល់បែបនេះ តើស្ត្រីប៉ុន្មាននាក់នឹងជ្រើសរើសយកការរំលូតកូន? អតីតម្ចាស់និងសមាជិកមន្ទីររំលូតកូនជាច្រើនកន្លែងបាននិយាយថា ការងាររបស់ពួកគេគឺ«លក់ការរំលូតកូន»ឱ្យស្ត្រីមានផ្ទៃពោះ។ មន្ទីរមួយចំនួនជួលអ្នកឯកទេសខាងផ្សព្វផ្សាយផលិតផលមកបណ្ដុះបណ្ដាលបុគ្គលិករបស់ពួកគេអំពីការលក់ការរំលូតកូន[៥]។

ការឱ្យកូនទៅគេយកទៅចិញ្ចឹម គឺជាជម្រើសវិជ្ជមានមួយ ដែលបញ្ចៀសបន្ទុកក្នុងការចិញ្ចឹមកូន ហើយក៏បានជួយសង្គ្រោះជីវិត ព្រមទាំងធ្វើឱ្យគ្រួសាររីករាយ។ វាជាការអាក្រក់ណាស់ដែលគេមិនសូវជ្រើសរើសយកការឱ្យកូនទៅគេយកទៅចិញ្ចឹម ឬផ្ដល់ជម្រើសផ្សេងទៀតក្រៅពីការរំលូតកូន។

ការស្រាវជ្រាវនៅឯមជ្ឈមណ្ឌលថែរក្សាគភ៌ បង្ហាញឱ្យឃើញថា ការប្រឆាំងនៅក្នុងផ្លូវអារម្មណ៍ចំពោះការឱ្យកូនទៅគេយកទៅចិញ្ចឹម គឺជាឧបសគ្គទូទៅមួយ

ដែលកើតមាននៅក្នុងចំណោមស្ត្រីដែលរំលូតកូន[៦]។ ហេតុផលដែលការឱ្យកូនទៅគេយកទៅចិញ្ចឹមនាំឱ្យឈឺចាប់ដូចគ្នានឹងការរំលូតកូន គឺជាការពាក់ព័ន្ធជាមួយនឹងជីវិតមនុស្ស។

ការឱ្យកូនទៅគេយកទៅចិញ្ចឹម ត្រូវបានអ្នកគាំទ្រការជ្រើសរើសយកមកពណ៌នាបែបអវិជ្ជមាន។ អ្នកតស៊ូមតិខាងការគាំទ្រការជ្រើសរើស ឃែរ៉ូល អ៊ិនឌើសិន (Carole Anderson) និងលីខេម ប៊ែល (Lee Campbell) និយាយ អំពីការឱ្យកូនទៅគេយកទៅចិញ្ចឹមថា «ការបំបែកកូនចេញពីម្ដាយជាការដាក់ទោសដ៏ព្រៃផ្សៃដែលមានរយៈពេលអស់មួយជីវិត»។

នៅពេលដែលពួកគេចាត់ទុកថាការឱ្យកូនទៅគេយកទៅចិញ្ចឹមជាអំពើព្រៃផ្សៃ ពួកគេមិនបានលើកឡើងពីអារម្មណ៍ខុសឆ្គងដែលស្ត្រីមានពេញមួយជីវិតពេលដែលនាងយល់ច្បាស់ថា នាងបានសម្លាប់កូនរបស់ខ្លួន។ ការឱ្យកូនទៅគេយកទៅចិញ្ចឹម វាមិនមែនជាការដាក់ទោសសម្រាប់ស្ត្រីដែលគ្មានលទ្ធភាពនឹងចិញ្ចឹមកូនរបស់ខ្លួនទេ។ ទោះបីជាពិបាកមែន ប៉ុន្តែនោះជាជម្រើសដែលបានចាត់មកពីស្ថានសួគ៌។

មានអត្ថបទល្អៗជាច្រើនតាមប្រព័ន្ធអ៊ីនធើណេតដែលនិយាយអំពីការឱ្យកូនទៅគេយកទៅចិញ្ចឹម[៨] ព្រមទាំងមានសៀវភៅមួយដែលសព្វវចនាធិប្បាយអំពីការឱ្យកូនទៅគេយកទៅចិញ្ចឹមដែលមានជាងបួនរយអត្ថបទ[៩]។ យើងជំពាក់ស្ត្រី និងកុមារដែលត្រូវដឹងអំពីការឱ្យកូនទៅគេយកទៅចិញ្ចឹមនេះ។

## ការរំលូតកូនប្លន់គ្រួសារដែលរង់ចាំដើម្បីសុំយកកូនទៅចិញ្ចឹម

ដោយការមានផ្ទៃពោះរហូតដល់គ្រប់ខែ ស្ត្រីវ័យក្មេងទទួលយកការទទួលខុសត្រូវសម្រាប់ការជ្រើសរើសរបស់នាង។ កូននោះធំឡើង ហើយពេញវ័យ។ ម្ដាយអាចមើលត្រលប់ទៅអតីតកាលវិញ ដោយមានអំនួត និងការពេញចិត្តថា នាងបានធ្វើត្រូវ ដោយអនុញ្ញាតឱ្យកូនរបស់នាងមានទាំងជីវិត និងគ្រួសារល្អ។ ប្រាកដណាស់ការឱ្យកូនទៅគេយកទៅចិញ្ចឹមគឺជាជម្រើសតែមួយគត់។ ស្ត្រីវ័យក្មេងនោះអាចជ្រើសរើសទុកកូន ហើយចិញ្ចឹមដោយខ្លួនឯង។ ការជ្រើសរើសណាមួយសុទ្ធតែត្រូវ។

អ្នកខ្លះសួរថា «តើខ្ញុំជាម្ដាយបែបណា ដែលបោះបង់កូនឱ្យគេយកទៅចិញ្ចឹម?» លទ្ធផលគឺថា ម្ដាយដែលមិនឱ្យកូនរបស់នាងទៅគេ ដោយព្រោះស្រឡាញ់កូន នឹងសម្លាប់កូននោះវិញ។ សំណួរដែលគាត់គួរតែសួរមិនមែនថា «តើខ្ញុំឱ្យកូនទៅគេយក

ទៅចិញ្ចឹមបានយ៉ាងដូចម្ដេច?» តែគួរតែសួរថា «តើខ្ញុំអាចសម្លាប់កូនរបស់ខ្ញុំដោយការរំលូតកូនបានយ៉ាងដូចម្ដេច?»។ ទោះបីជានាងមិនអាចមើលថៃកូនរបស់នាងដោយខ្លួនឯងបានក៏ដោយ តើនាងមិនអាចមើលឃើញថា នាងគួរតែអនុញ្ញាតឱ្យអ្នកដទៃស្រឡាញ់ និងមើលថៃកូននោះបានទេឬអី? គួរឱ្យស្ដាយ វាមិនមែនសាមញ្ញដូច្នេះទេ។

ស្ត្រីចង់ឱ្យវិបត្តិរបស់នាងបញ្ចប់ទៅ ប៉ុន្តែការឱ្យកូនទៅគេយកទៅចិញ្ចឹមហាក់បីដូចជាបន្សល់ទុកឱ្យស្ថានភាពមិនបានដោះស្រាយ។ «ជាមួយនឹងភាពមិនប្រាកដ និងអារម្មណ៍ថាខុសតាមដែលនាងអាចមើលឃើញទាំងសម្រាប់ខ្លួនឯង និងកូនរបស់នាង»[១០] នាងប្រហែលជាមានអារម្មណ៍ថា នាងមិនត្រឹមតែជាម្ដាយប៉ុណ្ណោះទេ ថែមទាំងជាម្ដាយដែលអាក្រក់ទៀតផង ព្រោះបានបោះបង់កូនរបស់ខ្លួនឱ្យទៅអ្នកដទៃ។ នាងប្រហែលជាមានអារម្មណ៍ព្រួយ ដែលនាងបានបោះបង់ចោល ឬខ្លាចគេរំលោភបំពានលើកូន។ ហេតុផលនៅត្រង់នេះ គឺនាងគិតថា ប្រសិនបើនាងរំលូតកូន កូននោះនឹងមិនមែនជាកូនទេ ហើយនាងក៏នឹងមិនក្លាយជាម្ដាយដែរ។ តាមពិតទៅនាងមិនអាចជ្រើសរើសបដិសេធការពិតទាំងពីរនេះបានទេ។ កូនរបស់នាងគឺពិត ដូច្នេះហើយនាងគឺជាម្ដាយ។ សំណួរតែមួយគត់គឺថា ក្នុងនាមជាម្ដាយ តើនាងនឹងធ្វើយ៉ាងដូចម្ដេចជាមួយកូននោះ?

ពីព្រោះនាងមិនទាន់មានចំណងផ្សាភ្ជាប់ជាមួយកូនរបស់នាងនៅឡើយការរំលូតកូនហាក់បីដូចជាដំណោះស្រាយមួយដ៏ងាយស្រួល បើប្រៀបធៀបទៅនឹងការបែកពីកូនរបស់នាងក្រោយពេលកើតមកនោះ។ ប៉ុន្តែកូននោះមានជីវិតពិតប្រាកដមុនពេលមានចំណងផ្សាភ្ជាប់ ដូចជាក្រោយពេលមានចំណងផ្សាភ្ជាប់ដែរ។ ស្ត្រីមានការជ្រើសរើសបីយ៉ាង: មានកូន ហើយចិញ្ចឹមកូននោះ ឬមានកូន ហើយឱ្យគ្រួសារផ្សេងទៀតចិញ្ចឹមកូននោះ ឬសម្លាប់កូននោះ។ ទោះបីជាការរំលូតកូនហាក់បីដូចជាពេញនិយមជាងគេបំផុតក៏ដោយ តាមពិតទៅវាជាជម្រើសដែលនាំមកនូវការបំផ្លាញយ៉ាងខ្លាំងបំផុត។

យើងត្រូវជួយស្ត្រីវ័យក្មេងឱ្យយល់ច្បាស់ពីការចិញ្ចឹមកូន ការឱ្យកូនទៅគេយកទៅចិញ្ចឹម និងការរំលូតកូន។ យើងគួរតែចាត់ទុកថាការឱ្យកូនទៅគេយកទៅចិញ្ចឹមគឺជាជម្រើសដ៏ក្លាហានមួយ ជាជម្រើសដែលឱ្យជីវិតដល់កូន និងគ្រួសារមួយ។

យុវ័យមានផ្ទៃពោះម្នាក់ដែលយើងបាននាំមកផ្ទះរបស់យើង មានការរំលូត

កូនពីរដងរួចមកហើយ ប៉ុន្តែនៅពេលដែលនៅជាមួយយើង នាងបានបង្កើតកូន ហើយឱ្យកូនទៅគេយកទៅចិញ្ចឹម។ ការធ្វើបែបនេះមិនងាយស្រួលទេ ប៉ុន្តែស្ត្រីដ៏អស្ចារ្យម្នាក់នេះបានប្រាប់ខ្ញុំជាច្រើនឆ្នាំក្រោយមកថា «ខ្ញុំបានក្រឡេកមើលទៅកូនទាំងបីនាក់ដែលមិននៅជាមួយដោយអារម្មណ៍ផ្សេងគ្នា។ កូនពីរនាក់ដែលខ្ញុំបានរំលូតនោះ បានធ្វើឱ្យខ្ញុំក្រៀមក្រំ និងសោកស្តាយយ៉ាងខ្លាំង។ ប៉ុន្តែនៅពេលដែលខ្ញុំគិតដល់កូនដែលខ្ញុំបានឱ្យគេយកទៅចិញ្ចឹម ខ្ញុំមានអំណរ ពីព្រោះខ្ញុំដឹងថាមានគ្រួសារដែលចង់បានវា ចិញ្ចឹមវាហើយ»។

សហគមន៍គ្រិស្តបរិស័ទគួរតែខំប្រឹងប្រែងយកឈ្នះអារម្មណ៍អវិជ្ជមានអំពីការសុំយកកូនទៅចិញ្ចឹម។ យើងគួរតែនិយាយអំពីការឱ្យកូនទៅគេយកទៅចិញ្ចឹមតាមបែបវិជ្ជមាន ហើយបង្ហាញចេញនូវការគោរពយ៉ាងខ្លាំងចំពោះស្ត្រីដែលឱ្យកូនរបស់នាងទៅគេយកទៅចិញ្ចឹម។ យើងគួរតែគោរពឪពុកម្តាយដែលសុំកូនគេមកចិញ្ចឹមនិងឱ្យពរកូនចិញ្ចឹមនោះ។ យើងគួរតែផ្តល់ធនធានដែលនិយាយអំពីការសុំកូនយកទៅចិញ្ចឹម ហើយអបអរចំពោះការសុំកូនចិញ្ចឹមនៅក្នុងក្រុមជំនុំរបស់យើង។ មានតែធ្វើតាមរយៈដូច្នេះប៉ុណ្ណោះ យើងជួយស្ត្រីវ័យក្មេងឱ្យយល់ច្បាស់ថា ការឱ្យកូនទៅគេយកទៅចិញ្ចឹម គឺជាជម្រើសដ៏ក្លាហានមួយ ហើយជាជំរើសមួយដែលទាំងម្តាយ ទាំងកូននឹងអរគុណយ៉ាងខ្លាំង។

ការគាំទ្រការជ្រើសរើសត្រលប់ជាគ្មានការជ្រើសរើស ឬការជ្រើសរើសមិនបានល្អ។ ប៉ុន្តែការឱ្យកូនទៅគេយកទៅចិញ្ចឹមគឺជាជម្រើសដ៏ឈ្លាសវៃ ពេញដោយចិត្តអាណិតអាសូរ និងមនុស្សគ្រប់គ្នាចាប់អារម្មណ៍យ៉ាងខ្លាំង។

ផ្នែកទី ៥

# ទស្សនៈវិស័យខាងវិញ្ញាណ និងឱកាស

# ជំពូកទី ១៨

# តើព្រះជាម្ចាស់លើកលែងទោសឱ្យការរំលូតកូនដែរឬទេ?

បុរសស្ត្រីរាប់លាននាក់ ទាំងនៅក្នុងសង្គម និងនៅក្នុងក្រុមជំនុំ កំពុងតែមានអារម្មណ៍ថាខុសឆ្គងដោយសារការរំលូតកូន។ ដូចដែលយើងបានឃើញរួចមកហើយនៅក្នុងជំពូក ១ ពីរភាគបីនៃអ្នកដែលបានធ្វើការរំលូតកូន បញ្ជាក់អត្តសញ្ញាណថាពួកគេគឺជាអ្នកខាងប្រូតេស្តង់ ឬខាងកាតូលិក។ ស្ទើរតែមួយភាគបីនៃស្ត្រីដែលរំលូតកូន បញ្ជាក់អត្តសញ្ញាណថានាងគឺជាគ្រិស្តបរិស័ទ[១]។ ឪពុកភាគច្រើននៃកូនទាំងនេះក៏ជាអ្នកនៅក្នុងក្រុមជំនុំរបស់យើងផងដែរ។

ប្រសិនបើអ្នកជាស្ត្រីដែលធ្លាប់រំលូតកូន ឬឱ្យជំបូន្មានអ្នកដទៃទៀតរំលូតកូន មេរៀននៅក្នុងជំពូកនេះគឺសម្រាប់អ្នកហើយ។ ប្រសិនបើលោកអ្នកគឺជាបុរសដែលចូលរួមនៅក្នុងការសម្រេចចិត្តអំពីការរំលូតកូនទោះជាពាក់ព័ន្ធនឹងមិត្តស្រី ប្រពន្ធ កូនស្រី ឬអ្នកណាក៏ដោយ មេរៀននៅក្នុងជំពូកនេះក៏សម្រាប់លោកអ្នកផងដែរ។

ការព្យាយាមលុបបំបាត់អារម្មណ៍ថាខុស ដោយមិនបានដោះស្រាយពីបុព្វហេតុនោះ មិនបានផលឡើយ។ មនុស្សដទៃទៀតប្រហែលជានិយាយថា «អ្នកគ្មានអ្វីដែលត្រូវគិតថាខ្លួនឯងខុសនោះទេ» ប៉ុន្តែលោកអ្នកដឹងច្បាស់ជាងគេបង្អស់។ ការបដិសេធការពិតមិនអាចជួយលោកអ្នកឱ្យគេចផុតចេញពីអារម្មណ៍ខុសឆ្គងបានទេ។ការបដិសេធធ្វើឱ្យអ្នកជួបការស្រយុតចិត្ត ពេលណាមានអ្វីមួយធ្វើឱ្យអ្នកនឹកឃើញកូនដែលអ្នកបានពរពោះម្តងនោះ។ អ្នកត្រូវការដំណោះស្រាយដែលនៅរហូតសម្រាប់បញ្ហាកំហុសរបស់លោកអ្នក ជាដំណោះស្រាយដែលផ្អែកទៅលើការពិត មិនមែនជាការធ្វើពុតទេ។

ដោយព្រោះគម្ពីរផ្តល់ដំណោះស្រាយនោះ ខ្ញុំនឹងដកស្រង់ចេញពីគម្ពីរ។ ចូរសុំឱ្យអ្នកដឹកនាំក្រុមជំនុំ អ្នកដឹកនាំក្រុមស្ត្រី ឬមិត្តភក្តិគ្រិស្តបរិស័ទ ឬសមាជិកគ្រួសាររបស់លោកអ្នកជួយលោកអ្នកឱ្យយល់។

## កិច្ចការរបស់ព្រះគ្រិស្ដ

ដំណឹងល្អគឺថា ព្រះជាម្ចាស់ស្រឡាញ់លោកអ្នក និងចង់លើកលែងទោសឱ្យលោកអ្នកសម្រាប់ការរំលូតកូនរបស់លោកអ្នក ទោះជាលោកអ្នកដឹង ឬមិនដឹងអ្វីដែលលោកអ្នកកំពុងធ្វើក៏ដោយ។ ប៉ុន្តែមុនពេលដែលអាចយល់បានអំពីដំណឹងល្អ យើងត្រូវតែដឹងដំណឹងអាក្រក់ជាមុនសិន។ ដំណឹងអាក្រក់គឺថា ពិតជាមានកំហុសខាងសីលធម៌មែន ហើយយើងទាំងអស់គ្នាខុសនឹងសីលធម៌ជាច្រើនទាស់នឹងព្រះជាម្ចាស់ ដែលក្នុងនោះការរំលូតកូនគឺជាការប្រព្រឹត្តិខុសខាងសីលធម៌មួយ «គ្រប់ៗគ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយគ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ» (រ៉ូម ៣:២៣)។

អំពើបាបគឺជាការខ្វះមិនដល់ភាពបរិសុទ្ធរបស់ព្រះជាម្ចាស់។ អំពើបាបញែកយើងចេញពីទំនាក់ទំនងជាមួយព្រះជាម្ចាស់ (អេសាយ ៥៩:២)។ អំពើបាបបោកបញ្ឆោតយើង ធ្វើឱ្យយើងគិតខុសទៅជាត្រូវ ត្រូវទៅជាខុស (សុភាសិត ១៤:១២)។ «ដ្បិតលទ្ធផលនៃបាបគឺសេចក្ដីស្លាប់ រីឯព្រះអំណោយទានរបស់ព្រះជាម្ចាស់វិញ គឺជីវិតអស់កល្បជានិច្ចរួមជាមួយព្រះគ្រិស្ដយេស៊ូ ជាព្រះអម្ចាស់នៃយើង»(រ៉ូម ៦:២៣)។

ព្រះយេស៊ូគ្រិស្ដ ដែលជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ ស្រឡាញ់យើងយ៉ាងខ្លាំង រហូតដល់ព្រះអង្គត្រលប់ជាមនុស្សដើម្បីជួយសង្គ្រោះយើងចេញពីបាបរបស់យើង (យ៉ូហាន ៣:១៦)។ ព្រះអង្គបានយកភាពកម្សោយដូចជាយើង ប៉ុន្តែមិនមានបាបដូចជាយើងទេ (ហេព្រើរ ២:១៧, ១៨, ៤:១៥-១៦)។ ព្រះយេស៊ូបានសោយទិវង្គតនៅលើឈើឆ្កាងក្នុងនាមជាអ្នកតែមួយគត់ដែលស័ក្តិសមនឹងបង់ថ្លៃការដាក់ទោសសម្រាប់អំពើបាបរបស់យើង ទៅតាមការទាមទារមកពីភាពបរិសុទ្ធរបស់ព្រះជាម្ចាស់ (២ កូរិនថូស ៥:២១)។ ព្រះអង្គបានរស់ពីការសោយទិវង្គតឡើងវិញ យកឈ្នះអំពើបាប និងសេចក្ដីស្លាប់ (១ កូរិនថូស ១៥:៣-៤, ៥៤-៥៧)។

នៅពេលដែលព្រះគ្រិស្ដបានសោយទិងវង្គតនៅលើឈើឆ្កាងសម្រាប់យើង ព្រះអង្គមានបន្ទូលថា «ខ្ញុំបានសម្រេចសព្វគ្រប់អស់ហើយ» (យ៉ូហាន ១៩:៣០)។ ភាសាក្រេកដែលបកប្រែថា «ខ្ញុំបានសម្រេចសព្វគ្រប់អស់ហើយ»ត្រូវបានគេសរសេរទទឹងនៅលើលិខិតបំណុល ពេលដែលលុបចោលបំណុលនោះ។ ពាក្យនោះមានន័យថា «បង់សព្វគ្រប់អស់ហើយ»។ ព្រះគ្រិស្ដបានសោយទិវង្គត ដើម្បីបង់បំណុលរបស់យើងសព្វគ្រប់អស់ហើយ។

## ការអត់ទោសទាំងស្រុង

ដោយព្រោះតែកិច្ចការរបស់ព្រះគ្រិស្តនៅលើឈើឆ្កាងសម្រាប់យើង ព្រះជាម្ចាស់ប្រទានឱ្យយើងមានការលើកលែងទោសដោយឥតគិតថ្លៃ។ ទាំងនេះគឺជាការប្រទានឱ្យមួយចំនួនតូចៈ

«ព្រះអង្គមិនដាក់ទោសយើងឱ្យសមនឹងអំពើបាបដែលយើងប្រព្រឹត្តនោះឡើយ ហើយព្រះអង្គក៏មិនឱ្យយើងទទួលទោសសមនឹងកំហុសរបស់យើងនោះដែរ។ ទិសខាងកើតនៅឆ្ងាយពីទិសខាងលិចយ៉ាងណា ព្រះអង្គក៏ដកកំហុសរបស់យើងចេញឆ្ងាយពីយើងយ៉ាងនោះដែរ។ ឪពុកអាណិតអាសូរកូនរបស់ខ្លួនយ៉ាងណា ព្រះអម្ចាស់ក៏អាណិតអាសូរអស់អ្នកដែលគោរពកោតខ្លាចព្រះអង្គយ៉ាងនោះដែរ» (ទំនុកតម្កើង ១០៣:១០, ១២-១៣)។

«ប៉ុន្តែ បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់មានព្រះហឫទ័យស្មោះស្ម័គ្រ និង សុចរិត ទ្រង់នឹងអត់ទោសយើងឱ្យរួចពីបាប ព្រមទាំងជម្រះយើងឱ្យបានបរិសុទ្ធ រួចពីគ្រប់អំពើទុច្ចរិតទាំងអស់ផង» (១ យ៉ូហាន ១:៩)។

«ឥឡូវនេះ អស់អ្នកដែលចូលរួមជាមួយព្រះគ្រិស្តយេស៊ូ ឥតមានទោសពៃរ៍ទៀតឡើយ» (រ៉ូម ៨:១)

## អំណោយដែលមិនអាចរកបាន

សេចក្តីសង្គ្រោះគឺជាអំណោយទាន «ព្រះអង្គសង្គ្រោះបងប្អូន មកពីព្រះអង្គមានព្រះហឫទ័យប្រណីសន្តោស ដោយសារបងប្អូនមានជំនឿ។ ការសង្គ្រោះមិនមែនមកពីបងប្អូនទេ គឺជាព្រះអំណោយទានរបស់ព្រះជាម្ចាស់វិញ ហើយក៏មិនមែនមកពីមនុស្សប្រព្រឹត្តអំពើល្អដែរ ដើម្បីកុំឱ្យអ្នកណាម្នាក់អួតខ្លួនបាន» (អេភេសូរ ២:៨-៩)។ យើងមិនអាចធ្វើការដើម្បីឱ្យបានអំណោយនេះទេ។ សេចក្តីសង្គ្រោះមិនអាស្រ័យលើកុសល ឬការខិតខំប្រឹងប្រែងរបស់យើងទេ ប៉ុន្តែពឹងផ្អែកតែទៅលើយញ្ញបូជារបស់ព្រះគ្រិស្តសម្រាប់យើងប៉ុណ្ណោះ។

ព្រះជាម្ចាស់ប្រទានឱ្យយើងមានអំណោយដែលជាការលើកលែងទោស និងជីវិតអស់កល្បជានិច្ច ប៉ុន្តែអំណោយទាំងនេះមិនមែនក្លាយជារបស់យើងដោយស្វ័យប្រវត្តិទេ។ ដើម្បីទទួលបានអំណោយនេះ យើងត្រូវជ្រើសរើសទទួលយកអំណោយនេះ។

លោកអ្នកប្រហែលជាគិតថា «ប៉ុន្តែអ្វីៗទាំងអស់ដែលខ្ញុំបានធ្វើ ខ្ញុំមិនសមនឹងទទួលបានការលើកលែងទោសទេ»។ គំនិតនោះត្រឹមត្រូវណាស់។ ក្នុងចំណោមយើងគ្មាននរណាម្នាក់សមនឹងទទួលបានការអត់ទោសទេ។ ប្រសិនបើយើងសមនឹងទទួលបានការលើកលែងទោស យើងមិនត្រូវការការលើកលែងទោសទេ។ នេះគឺជាព្រះគុណ។ ព្រះគ្រិស្តបានទទួលយកអ្វីដែលយើងសមនឹងទទួលនៅលើឈើឆ្កាងរួចទៅហើយ ដើម្បីឱ្យយើងអាចទទួលបានអ្វីដែលយើងមិនសមនឹងទទួល គឺជាភាពស្អាត និងការចាប់ផ្តើមជាថ្មី។

នៅពេលដែលទទួលបានការអត់ទោសរួចហើយ យើងអាចរង់ចាំដើម្បីនៅជាមួយព្រះគ្រិស្ត និងគ្រួសារខាងវិញ្ញាណរបស់យើងអស់កល្បជានិច្ច (យ៉ូហាន ១៤:១-៣, វិវរណៈ ២០:១១-២២)។ លោកអ្នកអាចរង់ចាំដើម្បីជួបជុំជាមួយអ្នកជាទីស្រឡាញ់របស់លោកអ្នកនៅឯស្ថានសួគ៌ គឺជាអ្នកដែលត្រូវបានគ្របបាំងដោយព្រះលោហិតរបស់ព្រះគ្រិស្ត (១ ថែស្សាឡូនីច ៤:១៣-១៨)។

## មិនត្រូវរស់នៅក្នុងអំពើបាបដូចកាលពីមុន

ស្ត្រីផិតក្បត់ម្នាក់បានយំនៅទាបព្រះបាទារបស់ព្រះគ្រិស្ត ថើប ហើយយកសក់នាងមកជូត។ ព្រះយេស៊ូមានបន្ទូលទៅកាន់អ្នកឈរក្បែរនោះម្នាក់ដែលកំពុងតែមានគំនិតជំនុំជម្រះថា «ហេតុនេះហើយ ខ្ញុំសុំប្រាប់ឱ្យលោកដឹងថា នាងសំដែងសេចក្តីស្រឡាញ់ជាខ្លាំងយ៉ាងនេះ ព្រោះព្រះជាម្ចាស់បានប្រោសឱ្យនាងរួចពីបាបជាច្រើន» (លូកា ៧:៤៧)។ ព្រះយេស៊ូប្រទានការលើកលែងទោសតែមួយនោះដល់យើងទាំងអស់គ្នា។

ព្រះជាម្ចាស់មិនចង់ឱ្យលោកអ្នករស់នៅក្នុងជីវិតដែលដាក់ទោសខ្លួនសម្រាប់ការរំលូតកូន ឬកំហុសដទៃទៀតដែលលោកអ្នកបានធ្វើនោះទេ។ កិច្ចការរបស់លោកអ្នក គឺទទួលយកតង្វាយធួននឹងបាបរបស់ព្រះគ្រិស្ត មិនមែនធ្វើបាបម្តងហើយម្តងទៀតទេ។ ព្រះយេស៊ូមានបន្ទូលទៅកាន់ស្ត្រីប្រាសចាកសីលធម៌ម្នាក់ថា «ខ្ញុំអត់ទោសឱ្យនាងបានរួចពីបាបហើយ...ជំនឿរបស់នាងបានសង្គ្រោះនាងហើយ សូមអញ្ជើញទៅវិញដោយសុខសាន្តចុះ» (លូកា ៧:៤៨-៥០)។ ស្ត្រីដែលសង្គមបដិសេធន៍បានមកឯព្រះយេស៊ូ ហើយព្រះអង្គបានស្វាគមន៍ពួកគេដោយព្រះហឫទ័យអាណិតអាសូរ និងការអត់ទោស។

ទោះជាលោកអ្នកបានធ្វើអ្វីក៏ដោយ គ្មានអំពើបាបណាមួយដែលព្រះគុណ

របស់ព្រះជាម្ចាស់មិនអាចអត់ទោសឱ្យបាននោះទេ។ ព្រះអង្គបានមើលឃើញតាំងពីពេលដែលយើងនៅអាក្រក់ ប៉ុន្តែនៅតែស្រឡាញ់យើង។ គ្មានដែនកំណត់សម្រាប់ព្រះគុណរបស់ព្រះជាម្ចាស់ក្នុងការអត់ទោសឱ្យទេ។ គ្មានសេរីភាពណាដូចជាសេរីភាពក្រោយពីបានអត់ទោសឱ្យហើយនោះទេ។

លោកអ្នកប្រហែលជាមានអារម្មណ៍បានស្អាតភ្លាម នៅពេលដែលលោកអ្នកសារភាពអំពើបាបរបស់លោកអ្នក ឬលោកអ្នកប្រហែលជាត្រូវជួយធ្វើការ។ ទោះជាតាមវិធីណាក៏ដោយ លោកអ្នកត្រូវបានអត់ទោសឱ្យរួចហើយ។ លោកអ្នកគួរតែព្យាយាមបំភ្លេចអ្វីពីអតីតកាល ហើយបន្តឆ្ពោះទៅរកអនាគតដ៏ល្អដែលយើងអាចទទួលបានដោយសារព្រះគ្រិស្ត (ភីលីព ៣:១៣-១៤)។ នៅពេលណាក៏ដោយដែលយើងចាប់ផ្តើមមានអារម្មណ៍ថាត្រូវបានអត់ទោសឱ្យ នោះជាពេលដែលត្រូវមកឯព្រះគម្ពីរហើយរំលឹកខ្លួនយើង និងរំលឹកគ្នាទៅវិញទៅមកអំពីការអត់ទោសរបស់ព្រះជាម្ចាស់។

ការចូលរួមនៅក្នុងក្រុមដែលមានតួនាទីព្យាបាលក្រោយពេលរំលូតកូន អាចជួយលោកអ្នកបានយ៉ាងច្រើន។ មានថ្នាក់សិក្សាព្រះគម្ពីរជាច្រើនដែលត្រូវបានរៀបចំឡើងសម្រាប់ស្ត្រី និងសម្រាប់បុរសដែលធ្លាប់មានបញ្ហារំលូតកូន។ ឯកសារតាមប្រព័ន្ធអ៊ីនធឺណេតជាច្រើនអាចជួយលោកអ្នករកឃើញក្រុមគាំពារដែលលោកអ្នកត្រូវការ[២]។

## ការជ្រើសរើសត្រឹមត្រូវមកតាមក្រោយការអត់ទោស

ស្ត្រីជាច្រើនដែលបានរំលូតកូន មានភាពល្វីងជូរចត់ចំពោះបុរសដែលបានប្រើ និងរំលោភបំពានលើពួកគេ ចំពោះឪពុកម្តាយដែលបានបង្ខំពួកគេ និងអ្នកដែលនាំពួកគេឱ្យជ្រើសរើសសម្លាប់កូនរបស់ពួកគេ។ ព្រះជាម្ចាស់សង្ឃឹមថាយើងនឹងទទួលយកការអត់ទោសដែលព្រះអង្គបានប្រទានឱ្យយើង និងអត់ទោសឱ្យមនុស្សដទៃទៀតផងដែរ (ម៉ាថាយ ៦:១៤-១៥)។

លោកអ្នកត្រូវធ្វើជាមួយផ្នែករបស់សហគមន៍ប្រោសឱ្យជា គឺជាគ្រួសារគ្រិស្តបរិស័ទហៅថាក្រុមជំនុំ។ (ប្រសិនបើលោកអ្នកជាសមាជិកក្រុមជំនុំរួចហើយ ចូរចែកចាយបទពិសោធន៍រំលូតកូនដល់អ្នកផ្សេង ដើម្បីទទួលបានជំនួយដែលលោកអ្នកត្រូវការ។ លោកអ្នកប្រហែលជាមានអារម្មណ៍មិនស្រួលនៅក្បែរគ្រិស្តបរិស័ទ ដោយព្រោះតែអតីតកាលរបស់លោកអ្នក។ លោកអ្នកមិនគួរមានអារម្មណ៍បែបនេះទេ។ ក្រុមជំនុំដែលផ្តង់ចិត្តទៅរកព្រះគ្រិស្តមិនមែនជាកន្លែងដាក់តាំងពួកបរិសុទ្ធទេ តែជា

មន្ទីរពេទ្យសម្រាប់មនុស្សបាប។ លោកអ្នកនឹងមិនត្រូវបានជំនុំជម្រះ និងដាក់ទោសសម្រាប់អំពើបាបដែលព្រះគ្រិស្តបានលើកលែងទោសឱ្យហើយនោះទេ។ មនុស្សដែលលោកអ្នកចូលរួមជាមួយគ្រាន់តែជាមនុស្ស ហើយមិនគ្រប់លក្ខណ៍ដូចជាលោកអ្នកដែរ។ សមាជិកក្រុមជំនុំភាគច្រើនមិនមែនសុចរិតដោយខ្លួនឯងទេ។ អ្នកដែលសុចរិតដោយខ្លួនឯង ជាមនុស្សដែលគួរឱ្យអាណិតទៅវិញទេ ពីព្រោះពួកគេមិនយល់អំពីព្រះគុណរបស់ព្រះជាម្ចាស់។

ក្រុមជំនុំល្អនឹងបង្រៀនសេចក្ដីពិតរបស់ព្រះគម្ពីរ ហើយនឹងផ្ដល់សេចក្ដីស្រឡាញ់ ការទទួលយក និងការគាំទ្រដល់លោកអ្នក។ ប្រសិនបើលោកអ្នកមិនអាចរកឃើញក្រុមជំនុំយ៉ាងដូច្នេះនៅក្នុងតំបន់របស់លោកអ្នកទេ សូមទំនាក់ទំនងអង្គការរបស់យើងដែលមានអាសយដ្ឋាននៅក្របខាងក្រោយរបស់សៀវភៅនេះ ហើយយើងរីករាយនឹងជួយលោកអ្នក។

កិច្ចការដ៏ប្រសើរមួយទៀតដែលលោកអ្នកអាចធ្វើបាន គឺឈោងចាប់ស្ត្រីដែលមិនចង់មានផ្ទៃពោះ តែមានផ្ទៃពោះ។ ព្រះជាម្ចាស់អាចប្រើបទពិសោធន៍របស់លោកអ្នកដើម្បីរៀបចំលោកអ្នកឱ្យជួយអ្នកដទៃទៀត និងចែកចាយសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ដល់ពួកគេ។ ភរិយារបស់ខ្ញុំ និងខ្ញុំមានមិត្តល្អៗជាច្រើនដែលធ្លាប់មានការរំលូតកូន។ តាមរយៈការខិតខំប្រឹងប្រែងរបស់ពួកគេនៅក្នុងការគាំទ្រជីវិត ពួកគេបានផ្ដល់ជំនួយដល់ស្ត្រីដទៃទៀត ជាជំនួយដែលពួកគេចង់បានពីអ្នកណាម្នាក់កាលពីមុននោះ។ ការនិយាយរឿងរបស់ពួកគេមិនត្រឹមតែជួយសង្គ្រោះជីវិតកូន និងជួយសង្គ្រោះម្ដាយចេញពីការឈឺចាប់ដោយសារការរំលូតកូនប៉ុណ្ណោះទេ ថែមទាំងបានជួយក្នុងការនាំមកនូវការប្រោសឱ្យជាដល់ពួកគេថែមទៀតផង។ លោកអ្នកក៏អាចទទួលបានបទពិសោធន៍ទាំងអស់នេះដែរ។

# ជំពូកទី ១៩

# បញ្ហាគាំទ្រជីវិតៈ

# កិច្ចការនាំឱ្យបែកចេញពីមហាបេសកកម្ម ឬ ជាមួយផ្នែករបស់មហាបេសកកម្ម?

គ្រិស្តបរិស័ទជាច្រើនដែលមានបំណងល្អជឿថា ក្រុមជំនុំមិនគួរលើកឡើងអំពីការរំលូតកូនទេ។ អ្នកខ្លះនិយាយថា តាមរយៈការនិយាយអំពីការរំលូតកូន យើងធ្វើឱ្យមនុស្សមានអារម្មណ៍ខុសឆ្គង។ ប៉ុន្តែ ហេតុផលនៅក្នុងការនិយាយអំពីការរំលូតកូនគឺ *ទប់ស្កាត់* មិនឱ្យមានការរំលូតកូន និងអារម្មណ៍ខុសឆ្គងដែលការរំលូតកូននាំមកនោះ ព្រមទាំងផ្តល់ជំនួយ និងសេចក្តីសង្ឃឹមដល់អ្នកដែលត្រូវអារម្មណ៍ខុសឆ្គងគាបសង្កត់ និងត្រូវការមានសេរីភាព។ ហេតុផលដែលយើងនៅស្ងៀមអំពីរឿងនេះធ្វើឱ្យក្រុមជំនុំពោរពេញទៅដោយមនុស្សដែលពាក់ព័ន្ធនឹងការរំលូតកូន។ តាមពិតទៅនេះគឺជាគំនិតដ៏ល្អបំផុតក្នុងការដោះស្រាយបញ្ហានៅចំពោះមុខ ហើយផ្តល់គំនិតជំនួយ និងការគាំទ្រតាមដែលយើងអាចធ្វើបាន។

និស្សិតសាលាព្រះគម្ពីរម្នាក់នៅឯក្រុមជំនុំរបស់ខ្ញុំ បានប្រាប់ខ្ញុំរឿងដែលខ្ញុំបានឮជាញឹកញាប់ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ៈ «បញ្ហាដូចជាការរំលូតកូននេះគ្រាន់តែជាកិច្ចការដែលនាំឱ្យបែកចេញពីកិច្ចការដ៏សំខាន់តែប៉ុណ្ណោះ»។

ខ្ញុំបានសួរថា «តើកិច្ចការដ៏សំខាន់នោះគឺជាអ្វី?»

គាត់បានឆ្លើយថា «មហាបេសកកម្ម ដែលជាការនាំមនុស្សថ្វាយព្រះគ្រិស្ត។ នោះគឺជាអ្វីដែលយើងត្រូវធ្វើរីឯកិច្ចការផ្សេងទៀតគ្រាន់តែជាកិច្ចការដែលនាំឱ្យរំខានប៉ុណ្ណោះ»។

គាត់កំពុងយោងទៅរកព្រះបន្ទូលរបស់ព្រះគ្រិស្តនៅក្នុងម៉ាថាយ ២៨ៈ១៩-២០ «ដូច្នេះហើយ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឱ្យធ្វើជាសាវក ហើយធ្វើពិធីជ្រមុជទឹកឱ្យគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ ត្រូវ

បង្រៀនគេឱ្យប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា»។

តើគាត់និយាយត្រូវដែរឬទេ? តើកិច្ចការគាំទ្រជីវិត គឺជាកិច្ចការដែលនាំឱ្យបែកចេញពីមហាបេសកកម្ម ឬជាមួយផ្នែករបស់មហាបេសកកម្ម?

## បុរសម្នាក់ឈ្មោះវីលៀម (William)

កាលពីពីររយឆ្នាំមុន មានបុរសជនជាតិអង់គ្លេសម្នាក់ឈ្មោះ វីលៀម ជាអ្នកប្រឆាំងយ៉ាងខ្លាំងនឹងភាពជាទាសករ ដែលបានបដិសេធមិនទិញស្ករពីតំបន់អ៊ិនឌីភាគខាងលិចទេ ពីព្រោះនោះគឺជាផលិតផលរបស់ទាសករ។ លោក វីលៀម មានអារម្មណ៍ថា ព្រះជាម្ចាស់ចង់ឱ្យគាត់ទៅប្រទេសឥណ្ឌា ជាកន្លែងដែលគាត់រន្ធត់ចិត្តយ៉ាងខ្លាំងដោយឃើញថា ជនជាតិហិណ្ឌូជាច្រើនសម្លាប់កូនតូចរបស់ពួកគេ។ ពួកគេក៏បានបោះបង់ចោលមនុស្សដែលខ្សោយ មនុស្សដែលឈឺ និងមនុស្សឃ្លង់។ រដ្ឋាភិបាលអង់គ្លេសនៅក្នុងប្រទេសឥណ្ឌាមើលបញ្ហានេះតាមបែបផ្សេង ពីព្រោះពួកគេមិនចង់ជ្រៀតជ្រែកវប្បធម៌ ឬសាសនាទេ ប៉ុន្តែលោកវីលៀម មានអារម្មណ៍ថាត្រូវតែជ្រៀតជ្រែក ពីព្រោះមនុស្សកំពុងតែស្លាប់។

ថ្ងៃមួយ លោកវីលៀម បានឃើញទំនៀមទម្លាប់មួយហៅថា *សាទី (sati)* ដែលស្ត្រីមេម៉ាយត្រូវគេដុតទាំងរស់នៅលើគំនរអុសដុតសពប្ដីរបស់ពួកគេដែលបានស្លាប់ទៅនោះ។ ក្រោយពីបានឃើញការស្លាប់មួយយ៉ាងដូច្នេះ គាត់បានក្រោកឈរឡើងនៅក្នុងចំណោមមនុស្សដែលបានប្រមូលផ្ដុំគ្នាដើម្បីដុតស្ត្រីម្នាក់ទាំងរស់ ហើយប្រាប់ពួកគេថាទំនៀមទម្លាប់របស់ពួកគេខុស។ គាត់បានដឹកនាំបេសកជនមួយមួយក្រុមធ្វើបាតុកម្ម។ គាត់បានជជែកជាសាធារណៈអំពីរឿងនេះដើម្បីឱ្យគេឃើញទស្សនៈរបស់ព្រះជាម្ចាស់។

នៅព្រឹកថ្ងៃអាទិត្យ ដែលត្រូវនឹងថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៨២៩ ក្រោយពីការប្រឆាំងអស់រយៈពេលជាច្រើនឆ្នាំ លោកវីលៀម បានទទួលលិខិតផ្លូវការហាមប្រាមការដុតស្ត្រីមេម៉ាយ។ គាត់ត្រូវអធិប្បាយនៅក្នុងក្រុមជំនុំនៅព្រឹកនោះ ប៉ុន្តែគាត់មិនបានអធិប្បាយទេ។ គាត់បានលះបង់ពេលវេលាមួយថ្ងៃនោះបកប្រែលិខិតនោះទៅជាភាសាបេងហ្កាលី ពីព្រោះគាត់ដឹងថា ជីវិតមនុស្សបានស្ថិតនៅក្នុងសភាពមិនទៀងជាយូរមកហើយ។

មនុស្សមួយចំនួនបានរិះគន់លោកវីលៀម សម្រាប់សកម្មភាពខាងនយោបាយ

និងខាងសីលធម៌របស់គាត់។ ពួកគេបាននិយាយថា «លោកមកទីនេះមិនមែនដើម្បីធ្វើកិច្ចការនេះទេ។ នេះមិនមែនជាការត្រាស់ហៅរបស់លោកទេ។ ចូរផ្តោតអារម្មណ៍លើកិច្ចចំបងវិញ គឺប្រកាសដំណឹងល្អ និងអធិប្បាយ»[១]។

តើសកម្មជនសង្គមដែលយកចិត្តទុកដាក់អំពីសីលធម៌ ច្បាប់ និងការសង្គ្រោះជីវិតមនុស្សនេះគឺជានរណា? គាត់មានឈ្មោះថា វីលៀម ឃែរី (William Carey) ដែលមនុស្សគេស្គាល់នៅសព្វថ្ងៃនេះថាជា «បិតាបេសកកម្មសម័យទំនើប»។ នៅពេលដែលយើងគិតដល់មហាបេសកកម្ម ហើយក្រុមបេសកកម្មនៅសម័យបច្ចុប្បន្នគ្មានឈ្មោះណាលេចធ្លោជាងឈ្មោះរបស់គាត់ទេ។

លោក ឃែរី បានទៅប្រទេសឥណ្ឌាដើម្បីនាំមនុស្សថ្វាយព្រះគ្រិស្ត និងបង្កើតសិស្ស មិនមែនគ្រាន់តែប្រកាសដំណឹងល្អប៉ុណ្ណោះទេ ថែមទាំងរស់នៅតាមដំណឹងល្អទៀតផង ដែលរួមមានទាំងការអន្តរាគមន៍ដើម្បីជួយសង្គ្រោះជីវិត និងការខំប្រឹងប្រែងដើម្បីផ្លាស់ប្តូរមតិសាធារណៈ និងច្បាប់ដែលអាក្រក់។

## ជំហានត្រូវដើរតាម

លោក ចន វេស្លី (John Wesley) បានប្រឆាំងយ៉ាងខ្លាំងនឹងទាសភាព។ លោក ឆាលស៍ ហ្វីននី (Charles Finney) មានតួនាទីយ៉ាងសំខាន់នៅក្នុងផ្លូវរថភ្លើងក្រោមដីខុសច្បាប់ ដែលបានសង្គ្រោះជីវិតរបស់ទាសករជាច្រើន នៅពេលជាមួយគ្នានោះ គាត់ត្រូវគ្រិស្តបរិស័ទជាច្រើនរិះគន់ដោយព្រោះតែការមិនស្តាប់បង្គាប់របស់គាត់នៅក្នុងសង្គម។ ឌី អ៊ិល មូឌី (D. L. Moody) បានទទួលក្មេងស្រីទាំងឡាយដែលក្រីក្រ ឱ្យស្នាក់នៅផ្ទះរបស់គាត់ ដោយជួយសង្គ្រោះពួកគេចេញពីការកេងប្រវ័ញ្ច។ លោក ឆាលស៍ ស្ពើរជិន (Charles Spurgeon) បានកសាងកន្លែងស្នាក់នៅដើម្បីជួយមើលថែស្ត្រីចាស់ជរា និងជួយសង្គ្រោះកុមារកំព្រាដែលនៅតាមដងផ្លូវក្នុងទីក្រុង។ អេមី ខាមីឃែល (Amy Carmichael) បានអន្តរាគមន៍ជួយសង្គ្រោះស្ត្រីជនជាតិឥណ្ឌាដែលត្រូវបានគេកេងប្រវ័ញ្ចខាងផ្លូវភេទ ដោយជួយសង្គ្រោះពួកគេចេញពីពេស្យាចារនៅក្នុងវិហារសាសនា។ គាត់បានសង់ផ្ទះ សាលារៀន និងមន្ទីរពេទ្យឱ្យពួកគេ។

គ្រិស្តបរិស័ទទាំងអស់នេះត្រូវបានគេស្គាល់ថាជាបេសកជន និងអ្នកផ្សាយដំណឹងល្អ ជាមនុស្សដែលបានសម្រេចមហាបេសកកម្ម។ ប៉ុន្តែ យើងមិនសូវយកចិត្តទុកដាក់នឹងការប្តេជ្ញាចិត្តដ៏មោះមុតរបស់ពួកគេនៅក្នុងការអន្តរាគមន៍ជួយអ្នកទន់ខ្សោយ អ្នកខ្វះខាត និងអ្នកដែលត្រូវគេកេងប្រវ័ញ្ចទេ។

ការផ្សាយដំណឹងល្អរបស់ពួកគេមានប្រសិទ្ធភាព ប្រហែលពីព្រោះពួកគេរស់នៅតាមដំណឹងល្អដែលពួកគេបានប្រកាសនោះ។ គ្មានការប្រឆាំងគ្នារវាងដំណឹងល្អជាមួយនឹងការយកចិត្តទុកដាក់ខាងសង្គម និងការអន្តរាគមន៍ផ្ទាល់ខ្លួនជួយអ្នកដែលខ្វះខាតនោះទេ។ តាមពិតទៅ មានការផ្សារភ្ជាប់គ្នាដោយផ្ទាល់រវាងសេចក្តីទាំងពីរនេះ។

## មួយផ្នែករបស់កិច្ចការដ៏ចំបង

យើងគួរតែព្យាយាមជួយសង្គ្រោះជីវិត ដោយព្រោះមានហេតុផលដ៏សាមញ្ញថា ព្រះគម្ពីរដែលយើងយកមកអធិប្បាយជារៀងរាល់សប្តាហ៍ប្រាប់ថា យើងគួរតែធ្វើយ៉ាងដូច្នេះ។

«ចូរជួយសង្គ្រោះអស់អ្នកដែលគេកាត់ទោសប្រហារជីវិត» (សុភាសិត ២៤:១១)។

«ចូររកយុត្តិធម៌ឱ្យមនុស្សទន់ខ្សោយ និងក្មេងកំព្រា ចូរកាត់ក្តីឱ្យមនុស្សកម្សត់ទុគ៌ត និងមនុស្សតោកយ៉ាក» (ទំនុកតម្កើង ៨២:៣)។

«ចូរស្រឡាញ់បងប្អូនឯទៀតៗឱ្យបានដូចស្រឡាញ់ខ្លួនឯងដែរ» (ម៉ាថាយ ១៩:១៩)។

ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ត្រូវមើលថែជាពិសេសដល់ស្ត្រីដែលគ្មានប្តី និងកូនដែលគ្មានឪពុក (យ៉ាកុប១:២៧)។ តើអ្នកណាស័ក្តិសមនឹងទទួលការមើលថែនេះជាងស្ត្រីដែលមិនបានរៀបការ និងកូនរបស់នាងដែលមិនទាន់កើតមកនោះ?

នៅក្នុងលូកា ១០:២៥ យើងបានអានថា មានបណ្ឌិតខាងវិន័យម្នាក់បានសួរថា «តើខ្ញុំត្រូវធ្វើអ្វីខ្លះដើម្បីឱ្យបានទទួលជីវិតអស់កល្បជានិច្ច?»។ ព្រះយេស៊ូបានឆ្លើយថា «ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នក...ហើយត្រូវស្រឡាញ់បងប្អូនឯងទៀតៗឱ្យបានដូចស្រឡាញ់ខ្លួនឯងដែរ» (ខ ២៧)។ ព្រះយេស៊ូបានហៅការស្រឡាញ់ព្រះជាម្ចាស់ជាបញ្ញត្តិទីមួយ និងធំជាងគេបង្អស់ ហើយការស្រឡាញ់អ្នកជិតខាងរបស់លោកអ្នកជាបញ្ញត្តិ ទីពីរ ដែលធំជាងគេ (ម៉ាថាយ ២២:៣៧-៣៩)។ ដូច្នេះ មហាបេសកកម្មមិនមែនជាបញ្ញត្តិដែលធំជាងគេ...ផ្ទុយទៅវិញ គឺជាការស្រឡាញ់ព្រះជាម្ចាស់ និងស្រឡាញ់អ្នកជិតខាងរបស់លោកអ្នក។

គ្មានអ្វីបើកទ្វារសម្រាប់ការផ្សាយដំណឹងល្អដូចជាព័ន្ធកិច្ចដែលបំពេញសេចក្តីត្រូវការទេ។ សិស្សដែលនិយាយអំពីការរំលូតកូន អាចមានការសន្ទនាក្រោយៗមក

ទៀតដែលអាចនាំទៅរកការប្រកាសដំណឹងល្អ។ អ្នកដែលធ្វើការនៅមជ្ឈមណ្ឌលថែរក្សាគភ៌ មានឱកាសនឹងចែកចាយពីព្រះគ្រិស្ត ហើយអ្នកដែលហុចឯកសារណែនាំនៅគ្លីនិករំលូតកូនក៏អាចចែកចាយពីព្រះគ្រិស្ត និងទៅបរិវេណសាលាដើម្បីអប់រំអំពីការរំលូតកូន។ មនុស្សដែលទទួលស្ត្រីមានផ្ទៃពោះឱ្យស្នាក់នៅក្នុងផ្ទះរបស់ពួកគេបង្ហាញសេចក្ដីស្រឡាញ់ដែលនាំទៅរកការចែកចាយដំណឹងល្អ។ នៅពេលណាក៏ដោយដែលយើងបំពេញសេចក្ដីត្រូវការរបស់មនុស្ស ការផ្សាយដំណឹងល្អត្រលប់ជាធម្មជាតិនិងជោគជ័យ។

## ទស្សនៈបីយ៉ាងអំពីមហាបេសកកម្ម

យើងត្រូវពិចារណាទស្សនៈបីយ៉ាងដើម្បីយល់អំពីទំនាក់ទំនងរវាងការខិតខំប្រឹងប្រែងគាំទ្រជីវិត និងមហាបេសកកម្ម។

ទីមួយ មហាបេសកកម្មគឺជាសេចក្ដីបង្គាប់ដ៏សំខាន់មួយ ប៉ុន្តែព្រះយេស៊ូបានហៅសេចក្ដីបង្គាប់មួយផ្សេងទៀតថាជាបញ្ញត្តិដែលសំខាន់ជាងគេបំផុត។ មហាបេសកកម្មគ្រាន់តែជាមួយផ្នែករបស់សេចក្ដីបង្គាប់ឱ្យស្រឡាញ់ព្រះជាម្ចាស់ និងអ្នកជិតខាងរបស់យើងតែប៉ុណ្ណោះ។

ទីពីរ ទោះបីជាកិច្ចការទាំងអស់របស់មហាបេសកកម្មគឺជាការផ្សាយដំណឹងល្អក៏ដោយ ការក្រោកឈរឡើងការពារជីវិតដែលកំពុងតែមានគ្រោះថ្នាក់ មានតម្លៃពីព្រោះការធ្វើបែបនោះបើកទ្វារសម្រាប់ការផ្សាយដំណឹងល្អ។

ទីបី នៅក្នុងមហាបេសកកម្មរបស់ព្រះអង្គ ព្រះយេស៊ូមិនបានប្រាប់យើងឱ្យផ្សាយតែដំណឹងល្អនោះទេ។ ព្រះអង្គបានប្រាប់យើង«ឱ្យបង្រៀនគេឱ្យប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា» (ម៉ាថាយ២៨:២០)។ ព្រះអង្គមិនមែនគ្រាន់តែមានបន្ទូលថាឱ្យបង្រៀនពួកគេឱ្យ *ជឿ*ប៉ុណ្ណោះទេ។ ព្រះអង្គមានបន្ទូលថាបង្រៀនពួកគេឱ្យ*ប្រតិបត្តិតាម*។

ព្រះយេស៊ូបង្គាប់យើងឱ្យមានចិត្តអាណិតអាសូរ និងលះបង់សម្រាប់មនុស្សដែលទន់ខ្សោយ និងដែលខ្វះខាត។ ដូច្នេះ នោះគឺជាផ្នែកមួយនៃ«សេចក្ដីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា» ហើយប្រសិនបើយើងខកខានមិនបានប្រតិបត្តិតាមផ្នែកនោះ និងមិនបានបង្រៀនមនុស្សដទៃទៀតឱ្យប្រតិបត្តិតាមផ្នែកនោះ យើងមិនបានសម្រេចមហាបេសកកម្មទេ។

ប្រសិនបើក្រុមជំនុំមិនអន្តរាគមន៍ជួយកូនដែលមិនទាន់កើតមក ព្រមទាំងម្តាយទេ ហើយប្រសិនបើយើងមិនបង្រៀនមនុស្សឱ្យជួយពួកគេទេ នោះយើងមិនបានសម្រេចមហាបេសកកម្មទេ។

ក្រុមជំនុំត្រូវតែជាអ្នកដ៏សំខាន់នៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់សម្រាប់អ្នកដែលត្រូវការជំនួយ។ ប្រសិនបើក្រុមជំនុំរបស់លោកអ្នកមិនទាន់បានធ្វើគ្រប់គ្រាន់ល្មមសម្រាប់កូនដែលមិនទាន់កើតមក ព្រមទាំងម្តាយនៅឡើយទេ នោះព្រះជាម្ចាស់ប្រហែលជាត្រាស់ហៅលោកអ្នកឱ្យងើបឡើង ជួយក្រុមជំនុំរបស់លោកអ្នក និងអ្នកដឹកនាំឱ្យចាប់យកព័ន្ធកិច្ចដ៏សំខាន់នេះ។

# ជំពូកទី ២០
# តើខ្ញុំអាចជួយកូនមិនទាន់កើតមក និងម្ដាយរបស់គេបានយ៉ាងដូចម្ដេច?

មានអង្គការជាច្រើនដែលគាំទ្រជីវិតនៅពាសពេញប្រទេស និងពិភពលោក។ ពួកគេមានជំនាញឯកទេសផ្សេងៗគ្នា ដែលរួមមានទាំងការអប់រំអំពីការចេះទប់ចិត្ត ការអប់រំអំពីការវិវឌ្ឍន៍របស់ទារក ការប្រឹក្សាយោបល់ដល់ស្ត្រីមានផ្ទៃពោះ មានឥទ្ធិពលលើការធ្វើច្បាប់ ទទួលកូនយកមកចិញ្ចឹម ប្រឈមមុខនឹងវប្បធម៌ដែលសម្លាប់ទារកនៅក្នុងផ្ទៃ ចែកចាយអត្ថបទសិក្សាខាងវិទ្យាសាស្ត្រ និងខាងចិត្តសាស្ត្រ ការអធិស្ឋាន ការប្រឹក្សាយោបល់នៅតាមផ្លូវខាងក្រៅគ្លីនិករំលូតកូន និងជួយបុរសស្ត្រីដែលធ្លាប់មានការរំលូតកូន។ មានអ្នកប្រឹក្សាយោបល់ដែលបានទទួលការបណ្ដុះបណ្ដាលក្នុងការប្រឹក្សាយោបល់ និងឆ្លើយតាមទូរស័ព្ទ និងសារជាអេឡិចត្រូនិចម្ភៃបួនម៉ោងក្នុងមួយថ្ងៃ[១]។

## សំណូមពរឱ្យមានការរួបរួមគ្នានៅក្នុងការគាំទ្រជីវិត

ម្ភៃឆ្នាំមកនេះ ខ្ញុំមានអភ័យឯកសិទ្ធិធ្វើការ និងអង្កេតការនៅក្នុងព័ន្ធកិច្ចជាច្រើនដែលគាំទ្រជីវិត។ ខ្ញុំបានឃើញភាពខ្លាំងនៅក្នុងវិធីសាស្ត្រផ្សេងៗគ្នា ដែលឈោងចាប់មនុស្សផ្សេងៗគ្នា និងដែលទាក់ទាញអ្នកធ្វើការស្ម័គ្រចិត្ត និងអ្នកគាំទ្រ។

អ្នកគាំទ្រជីវិត ដែលឆេះឆួលអំពីបុព្វហេតុរបស់ពួកគេ ពេលខ្លះគិតថា របៀបដែលគេប្រើនៅក្នុងព័ន្ធកិច្ចគាំទ្រជីវិត គឺជារបៀបដែលសំខាន់ជាងគេ ដែលត្រូវ ឬជារបៀប*តែមួយគត់* ដែលជោគជ័យ។ នេះគឺជាការមើលមិនបានឆ្ងាយ ដូចជាទាហានដែលនិយាយថា កងនាវាមិនមានប្រយោជន៍ទេ។ ភារកិច្ចគាំទ្រជីវិត គឺជាភារៈកិច្ចមួយដែលធំ ហើយមានច្រើនផ្នែកណាស់ ដែលទាមទារឱ្យមានយុទ្ធសាស្ត្រច្រើន។ យើងទាំងអស់គ្នាមិនគួរព្យាយាមធ្វើកិច្ចការតែមួយដូចគ្នាទេ។

យើងទាំងអស់គ្នាត្រូវបានបង្គាប់ថា «ត្រូវមានចិត្តគំនិតតែមួយ និងរួមសុខទុក្ខជាមួយគ្នា។ ត្រូវមានចិត្តស្រឡាញ់គ្នាទៅវិញទៅមកដូចបងប្អូនបង្កើត មានចិត្ត

អាណិតមេត្តា និងសុភាព» (១ ពេត្រុស ៣:៨)។ ចិត្តអាណិតមេត្តា និងសុភាពរហ័សនឹងរៀន ពីមនុស្សដទៃទៀត ដែលមានបុគ្គលិកលក្ខណៈ អំណោយទាន និងយុទ្ធសាស្ត្រផ្សេងគ្នា។ យើងត្រូវការចិត្តសុភាព ចិត្តអត់ធ្មត់ សេចក្តីស្រឡាញ់ សន្តិភាពនិងការរួបរួមគ្នានៅក្នុងព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ (អេភេសូរ ៤:១-៦)។

អស់រយៈពេលជាច្រើនឆ្នាំដែលខ្ញុំបានដឹកនាំជំនួបប្រជុំអ្នកដឹកនាំគាំទ្រជីវិតរៀងរាល់ពីរខែម្តង ហើយអ្នកដឹកនាំទាំងនោះមកពីក្រុមផ្សេងៗគ្នា។ យើងចាប់ផ្តើមស្គាល់ យល់ និងរៀនពីគ្នាទៅវិញទៅមក។ យើងបានរកឃើញសកម្មភាពដែលយើងអាចសហការជាមួយគ្នាបាន ហើយបានរកឃើញថា យើងកំពុងព្យាយាមផលិតមេរៀន និង កម្មវិធីដែលក្រុមដទៃទៀតមានរួចទៅហើយ។ មនុស្សជាច្រើននិយាយប្រាប់ខ្ញុំថា ពួកគេមិនដែលយល់អំពីក្រុមដទៃទៀត ហើយធ្លាប់សង្ស័យចំពោះវិធីសាស្ត្ររបស់ក្រុមទាំងនោះ។ ពួកគេមានអារម្មណ៍ប្រកួតប្រជែងគ្នា។ ប៉ុន្តែ នៅពេលដែលពួកគេស្គាល់មនុស្សទាំងនេះ ពួកគេបានមើលឃើញចិត្តរបស់អ្នកទាំងនេះ និងបានយល់អំពីគោលបំណងរបស់អ្នកទាំងនេះ។ ពួកគេស្រឡាញ់ និងគោរពបងប្អូនប្រុសស្រីដែលព្រះជាម្ចាស់បានត្រាស់ហៅឱ្យបម្រើព័ន្ធកិច្ចគាំទ្រនៅផ្នែកផ្សេងៗ។

ចូររកមើលអង្គការដែលស័ក្តិសមជាមួយជីវប្រវត្តិ បុគ្គលិកលក្ខណៈអំណោយទាន និងការត្រាស់ហៅរបស់ព្រះជាម្ចាស់សម្រាប់លោកអ្នក។ មានព័ត៌មានទំនាក់ទំនងជាច្រើនអំពីអង្គការផ្សេងៗដែលគាំទ្រជីវិតទាំងនៅតាមមូលដ្ឋាន នៅតាមប្រទេស និងនៅតាមតំបន់[២]។ ប្រសិនបើលោកអ្នកត្រូវការជំនួយក្នុងការរកក្រុមដែលគាំទ្រជីវិតនៅក្នុងតំបន់របស់លោកអ្នក សូមទំនាក់ទំនងមកការិយាល័យរបស់យើងដើម្បីសុំជំនួយ[៣]។

## អ្វីដែលលោកអ្នកអាចធ្វើបាន

ប្រសិនបើលោកអ្នកគឺជាសមាជិកនៅក្នុងក្រុមជំនុំដែលផ្ចង់ចិត្តទៅរកព្រះគ្រិស្ត និងបង្រៀនព្រះគម្ពីរ សូមទំនាក់ទំនងអ្នកដឹកនាំរបស់លោកអ្នក ហើយសួរអំពីព័ន្ធកិច្ចគាំទ្រជីវិតនៅក្នុងក្រុមជំនុំ និងសហគមន៍របស់លោកអ្នក (ប្រសិនបើលោកអ្នកមិនមែនជាសមាជិកក្រុមជំនុំ សូមចូលជាសមាជិកក្រុមជំនុំណាមួយ)។ យើងត្រូវតែតយុទ្ធជាមួយនឹងគំនិតដែលថា «ខ្ញុំគ្រាន់តែជាមនុស្សម្នាក់។ យើងគ្រាន់តែជាក្រុមជំនុំតូចមួយ។ យើងមិនអាចបំផ្លាស់បំប្រែបានទេ»។ លោកអ្នកមិនអាចលុបបំបាត់ចោលសេចក្តីត្រូវការបានទេ ប៉ុន្តែព្រះជាម្ចាស់អាចប្រើលោកអ្នកដើម្បីបំពេញសេចក្តី

ត្រូវការតាមរបៀបយ៉ាងអស្ចារ្យ។ តើលោកអ្នកជួយមនុស្សរាប់លាន់នាក់ដែលត្រូវការជំនួយបានយ៉ាងដូចម្តេច? ម្នាក់ម្តងៗ។

ខាងក្រោមនេះមិនមែនជាកិច្ចការដែលមនុស្សគ្រប់គ្នាគួរតែធ្វើទេ ប៉ុន្តែគ្រាន់តែជាបញ្ជីសម្រាប់ឱ្យជ្រើសរើសអ្វីដែលស័ក្តិសមជាមួយនឹងអំណោយទាន និងធនធានរបស់លោកអ្នកៈ

*១. ទទួលឱ្យស្នាក់នៅក្នុងផ្ទះៈ* ជួយក្មេងស្រីដែលមានផ្ទៃពោះ ឬទទួលយកកូន«ដែលគេមិនចង់បាន»មកថែរក្សា ឬចិញ្ចឹមជាកូន ឬលះបង់ពេលវេលាមួយថ្ងៃក្នុងមួយសប្តាហ៍ជួយមើលកូនឱ្យម្តាយដែលឪពុកកូននោះមិននៅជាមួយ។

*២. លះបង់ពេលវេលា ទេពកោសល្យ និងការបម្រើៈ* ថែទាំស្ត្រីដែលមានផ្ទៃពោះ ទារកដែលកើតមក កុមារកំព្រា មនុស្សពិការ ចាស់ជរា មនុស្សនៅតាមចិញ្ចើមផ្លូវ និងមនុស្សដទៃទៀតដែលត្រូវការជំនួយ។ ចូរឱ្យជាពេលវេលា ឧបករណ៍ គ្រឿងសង្ហារឹម សម្លៀកបំពាក់ ជំនាញវិជ្ជាជីវៈ និងលុយដល់មជ្ឈមណ្ឌលថែរក្សាគភ៌ ព័ន្ធកិច្ចឱ្យកូនយកទៅចិញ្ចឹម ផ្ទះសម្រាប់ស្ត្រី អង្គការផ្នែកនយោបាយ និងផ្នែកអប់រំដែលគាំទ្រជីវិត ព្រមទាំងក្រុមគាំទ្រជីវិតដទៃទៀត។ កាត់ស្មៅឱ្យពួកគេ ជួយសំអាត ជួសជុលបំពង់បង្ហូរទឹក រៀបចំគេហទំព័រឱ្យពួកគេ និងជួសជុលកុំព្យូទ័រឱ្យពួកគេ។

*៣. ធ្វើជាអ្នកផ្តួចផ្តើមគំនិតៈ* ប្រសិនបើគ្មានព័ន្ធកិច្ចគាំទ្រជីវិតនៅក្បែរនោះទេ សូមពិចារណាបង្កើតមួយកន្លែង។ បង្កើតក្រុម ជួលកន្លែងដែលនៅក្បែរនឹងមន្ទីររំលូតកូន ឬការិយាល័យ សម្រាប់គម្រោងធ្វើជាឪពុកម្តាយ។ បង្កើតមន្ទីរប្រឹក្សាយោបល់អំពីការមានផ្ទៃពោះ ឬមជ្ឈមណ្ឌលព័ត៌មានគាំទ្រជីវិត។ បង្កើតរូបភាពស្រស់ស្អាតអំពីទារកដែលមិនទាន់កើតមក ប្រហែលជាក្នុងរូបរាងជាសួនផ្កាកូលាបដាក់នៅក្នុងបរិវេណក្រុមជំនុំ ឬសហគមន៍របស់លោកអ្នក[៤]។

*៤.ដឹងព័ត៌មានលំអិតៈ* ដឹងការពិត ដើម្បីឱ្យលោកអ្នកអាចហាត់ឆ្លើយតបទុកជាមុនចំពោះមតិដែលគាំទ្រការជ្រើសរើស[៥]។ មានសៀវភៅ កាសែត និងវីដេអូល្អៗជាច្រើន ព្រមទាំងខិតប័ណ្ណដោយឥតគិតថ្លៃដែលនិយាយអំពីការគាំទ្រជីវិត។ មានគេហទំព័រល្អៗជាច្រើនដែលនិយាយអំពីការគាំទ្រជីវិត[៦]។ នៅពេលដែលការវះកាត់រំលូតកូនបានចាប់ផ្តើមថយចុះ ការរំលូតកូនដោយប្រើថ្នាំកំពុងតែកើនឡើង។ ចូរឱ្យបានដឹងព័ត៌មានអំពីថ្នាំរំលូតកូន និងថ្នាំពន្យាកំណើត ដែលពេលខ្លះនៅតែធ្វើឱ្យមានគភ៌។ ថ្នាំទាំងនេះជាធម្មតារារាំងមិនឱ្យទារកមកចាប់ទំផ្ទៃម្តាយ ដូច្នេះធ្វើ

ឱ្យមានការរំលូតកូនតាំងពីដំបូង។ ចូរឱ្យបានដឹងព័ត៌មានល្អមនឹងធ្វើការសន្និដ្ឋានផ្ទាល់ខ្លួន។

*៥. និយាយប្រាប់មិត្តភក្តិ អ្នកជិតខាង និងអ្នករួមការងារ:* លើកទឹកចិត្តអ្នកដទៃទៀតឱ្យពិចារណាឡើងវិញអំពីការគិតរបស់ពួកគេ។ ឱ្យសៀវភៅមួយក្បាលនេះទៅពួកគេ ដោយគូសចំណាំលើទំព័រមួយចំនួនដើម្បីទាក់ទាញអារម្មណ៍របស់ពួកគេ។ ចូរ សិក្សា បញ្ហា លំអិត ថែម ទៀត នៅ ក្នុង សៀវភៅ របស់ ខ្ញុំ ដែល មាន ចំណង ជើង ថា *ចម្លើយរបស់អ្នកគាំទ្រជីវិតចំពោះមតិដែលគាំទ្រការជ្រើសរើស (ProLife Answers to ProChoice Arguments)*។ ចូរចែកសៀវភៅដែលនិយាយអំពីការគាំទ្រជីវិតដូចជា *យញ្ញបូជាទារក (The Atonement Child)* ដែលសរសេរឡើងដោយ ហ្វ្រិនស៊ីន រីវើរ (Francine Rivers) *ទឹកភ្នែកនៅក្នុងដប (Tears in a Bottle)* ដែល សរសេរ ឡើង ដោយ ស៊ីលីវៀ បាំបូឡា (Sylvia Bambola) និង សៀវភៅ ដែល ខ្ញុំ សរសេរ មាន ចំណង ជើង ថា *ពេលកំណត់ (Deadline)*។

*៦. លើកស្ទួយការពិភាក្សាអំពីការរំលូតកូន:* ទៅនិយាយលេងតាមប្រព័ន្ធអ៊ិនធឺណេត ដោយនាំយកទស្សនៈគាំទ្រជីវិតទៅជាមួយ។ ទូរស័ព្ទចែកចាយតាមប្រព័ន្ធវិទ្យុ ទូរទស្សន៍ដែលបង្ហាញចេញពីគោលជំហរគាំទ្រជីវិត។ ទិញអត្ថបទគាំទ្រជីវិតយកមកចែកចាយ។ ចូរនិយាយ ដើម្បីកុំឱ្យអ្នកគាំទ្រការជ្រើសរើសចេះតែបន្តដោយគ្មានការប្រឆាំង។ ដូចដែលខ្ញុំនិយាយនៅក្នុងសៀវភៅរបស់ខ្ញុំដែលមានចំណងជើងថា *ព្រះគុណ និងសេចក្តីពិត* ជាការសំខាន់ណាស់ដែលយើងត្រូវនិយាយអំពីប្រធានបទបែបដូចជាការរំលូតកូននេះតាមរបៀបមួយដែលដូចជាព្រះគ្រិស្ត។ ព្រះយេស៊ូបានយាងមកពោរពេញដោយព្រះគុណ និងសេចក្តីពិត (យ៉ូហាន ១:១៤)។ ប្រសិនបើចង់ឱ្យមនុស្សមើលឃើញព្រះយេស៊ូនៅក្នុងយើង យើងត្រូវតែផ្តល់សេចក្តីពិតរួមជាមួយព្រះគុណ។

*៧. សរសេរសំបុត្រ:* គួរសម ច្បាស់លាស់ ត្រឹមត្រូវ និងងាយចាំ។ ដកស្រង់យកសេចក្តីយោងខ្លីៗនៅក្នុងសៀវភៅនេះ និងសៀវភៅមួយផ្សេងទៀតដែលមានចំណងជើងថា *ចំម្លើយរបស់អ្នកគាំទ្រជីវិត (ProLife Answers)*។ ប្រហែលជាមានមនុស្សរាប់រយពាន់នាក់អានសំបុត្រ ដែលយើងផ្ញើទៅនាយកនិពន្ធទស្សនាវដ្តី ឬសារព័ត៌មាន។

*៨. លើកទឹកចិត្តឱ្យមានការប្រឆាំងនឹងមន្ទីររំលូតកូន:* ទាក់ទងមនុស្សដែល

មានឥទ្ធិពល ដូចជាម្ចាស់ផ្ទះ អ្នករកស៊ី អ្នកផ្តល់ការធានារ៉ាប់រង អ្នកផ្តល់សេវាពេទ្យ និងអ្នកផ្តល់សេវាកម្មផ្សេងៗទៀត ដោយប្រាប់យ៉ាងសុភាពថា លោកអ្នកមិនអាចគាំទ្រអ្នកដែលផ្តល់សេវាកម្មសម្លាប់ទារកបានទេ។

*៩. ចូលរួមសកម្មក្នុងដំណើរការនយោបាយ ៖* ជួបជាមួយ អ្នកតំណាងរាស្ត្រ ហើយចែកចាយទស្សនៈរបស់លោកអ្នកអំពីការរំលូតកូន។ ធ្វើសេចក្តីព្រៀងផ្សព្វផ្សាយ និងចុះហត្ថលេខាលើសំណើសុំឱ្យមាននិវាធានការគាំទ្រជីវិត។ ឈរឈ្មោះសម្រាប់មុខតំណែងនៅក្នុងនយោបាយ ក្រុមប្រឹក្សាសាលា ឬប្រធានក្រុម ឬសង្កាត់។ គាំទ្របេក្ខជនដែលគាំទ្រជីវិតទាំងពេលវេលា និងថវិកា។

*១០. ចូលរួម ឬរៀបចំកម្លាំងការងារគាំទ្រជីវិតនៅក្នុងក្រុមជំនុំរបស់លោកអ្នក*។ សុំការណែនាំពីអ្នកដឹកនាំរបស់លោកអ្នក។ ចែកសៀវភៅឱ្យពួកគេ សុំពួកគេឱ្យមើលវីដេអូ។ ជ្រើសរើសមនុស្សដែលគាំទ្រព័ន្ធកិច្ចដទៃទៀតរបស់ក្រុមជំនុំ ដើម្បីជួយលោកអ្នកបង្កើត និងអនុវត្តផែនការអប់រំ និង បំផុសបំផុល។ ស្នើសុំតង្វាយពិសេសសម្រាប់ព័ន្ធកិច្ចគាំទ្រជីវិត។ ផ្តល់ខិតប័ណ្ណ និងសៀវភៅដើម្បីឱ្យក្រុមជំនុំរបស់លោកអ្នកចែកចាយនៅក្នុងអំឡុងពេលនៃសប្តាហ៍ហៅថា ភាពពិសិដ្ឋរបស់ជីវិតមនុស្ស ដែលនៅក្នុងខែមករា[៨]។ ចូររកឱ្យបានសៀវភៅដែលមានចំណងជើងថា *ហេតុអ្វីគាំទ្រជីវិត?* ឱ្យបានច្រើន ហើយចែកចាយដល់មនុស្សគ្រប់គ្នានៅក្នុងក្រុមជំនុំរបស់លោកអ្នក (ប្រាក់ទាំងអស់ដែលបានមកពីសៀវភៅនេះនឹងប្រើសម្រាប់ព័ន្ធកិច្ចគាំទ្រជីវិត មិនបានទៅអ្នកនិពន្ធទេ)។ ប្រសិនបើអ្នកដឹកនាំក្រុមជំនុំរបស់លោកអ្នកចង់បានគំនិតសម្រាប់រៀបចំសេចក្តីអធិប្បាយរបស់ពួកគេ ចូរផ្តល់ឱ្យពួកគេនូវធនធានមួយចំនួនដែលមាន[៩]។

*១១. ប្រើប្រាស់ធនធានគាំទ្រជីវិត ដែលជាធនធានល្អៗ៖* នៅក្នុងពេលថ្វាយបង្គំនៅក្នុងក្រុមជំនុំរបស់លោកអ្នក ឬថ្នាក់សិក្សាផ្សេងៗ ចូរចាក់វីដេអូគាំទ្រជីវិតដូចជា «ជីវិតគឺពិសិដ្ឋ (Life is Sacred)»[១០]។ ចូរគិតពិចារណាអំពីការចាក់វីដេអូអំពីការរំលូតកូន[១១] (រៀបចំមនុស្ស និងព្រមានជាមុនថាវីដេអូនេះមិនមែនសម្រាប់កូនក្មេងទេ)។ ចែកចាយព័ត៌មានទំនាក់ទំនងសម្រាប់ក្រុមគាំទ្រជីវិតផ្សេងទៀតនៅក្នុងសហគមន៍របស់លោកអ្នក។ បង្កើតក្រុមសម្រាប់អ្នកប្រឹក្សាយោបល់នៅតាមផ្លូវ។ ចូររៀបចំការអធិស្ឋានចាំយាម ឬការប្រឆាំង។ ចូរទំនាក់ទំនងក្រុមគាំទ្រជីវិតនៅក្នុងតំបន់របស់លោកអ្នក។ ពួកគេដឹងច្រើនអំពីអ្វីដែលលោកអ្នកមិនដឹង ហើយពួកគេរីករាយនឹងធ្វើជាធនធានសម្រាប់លោកអ្នក។

*១២. អធិស្ឋានជារៀងរាល់ថ្ងៃសម្រាប់ព័ន្ធកិច្ចគាំទ្រជីវិត ក្រុមជំនុំ អ្នកដឹកនាំក្រុមជំនុំ ម្ដាយ និងទារក:* ចូររៀបចំក្រុមអធិស្ឋានរបស់លោកអ្នក។ ដើម្បីឱ្យពន្លឺនៃសេចក្ដីពិត និងចិត្តអាណិតអាសូរយកឈ្នះភាពងងឹតនៃការសម្លាប់ទារក នោះត្រូវតែមានសង្គ្រាមខាងវិញ្ញាណ ដែលតយុទ្ធដោយការអធិស្ឋានខ្ជាប់ខ្ជួន និង បន្ទាបខ្លួន (អេភេសូរ ៦:១០-២០)។

*១៣. ឱ្យដល់ក្រុមដែលគាំទ្រជីវិត:* ខ្ញុំបានទស្សនាខ្សែភាពយន្តជាច្រើនរបស់ព័ន្ធកិច្ចគាំទ្រជីវិត។ ស្ទើរតែនៅក្នុងគ្រប់ករណី ខ្ញុំបានដើរចេញមកដោយចាប់អារម្មណ៍នឹងការខុសប្លែកដែលកំពុងតែកើតមានឡើង។ ខ្ញុំលើកទឹកចិត្តលោកអ្នក និងក្រុមជំនុំរបស់លោកអ្នកឱ្យស្វែងរកអង្គការគាំទ្រជីវិតមួយ ចំនួននៅក្នុងតំបន់របស់លោកអ្នក ឬព័ន្ធកិច្ចគាំទ្រជីវិតថ្នាក់ជាតិ ឬថ្នាក់អន្តរជាតិ ហើយឱ្យដោយសប្បុរសដល់ពួកគេ។

សួរខ្លួនលោកអ្នកថា *ប្រាំនាទីក្រោយពីខ្ញុំស្លាប់ទៅ តើខ្ញុំចង់ឱ្យខ្លួនឯងបានឱ្យអ្វីដល់អ្នកត្រូវការជំនួយ ពេលដែលខ្ញុំនៅមានឱកាសនោះ?* ហេតុអ្វីមិនចំណាយពេលដែលនៅសល់នៅក្នុងជីវិតរបស់យើងបិទភ្ជាប់គម្លាតរវាងអ្វីដែលយើងចង់ឱ្យខ្លួនឯងបានឱ្យ និងអ្វីដែលយើងកំពុងតែឱ្យទៅ?

យើងមានពេលខ្លី ជារយៈពេលរស់នៅលើផែនដីនេះ ដើម្បីនឹងប្រើធនធានរបស់យើងធ្វើឱ្យមានការខុសប្លែកស្ថិតនៅអស់កល្បជានិច្ច។ ចូរស្រមៃពេលដែលនៅស្ថានសួគ៌ ហើយគិតថា លោកអ្នកនឹងមានអារម្មណ៍បែបណាទៅ ពេលដែលមនុស្សម្នាក់មកជួបលោកអ្នក និយាយទាំងញញឹមថា «អរគុណអ្នកហើយ! អំណោយរបស់អ្នកបានជួយសង្គ្រោះជីវិតរបស់ខ្ញុំ...និងកូនរបស់ខ្ញុំ»។

# អំពីអ្នកនិពន្ធ

លោក រ៉េនឌី អាល់ខន គឺជាអ្នកស្រាវជ្រាវ និងជាអ្នកនិពន្ធសៀវភៅម្កៃក្បាល ដែលលក់ដាច់ជាងគេបំផុត។ ស្នាដៃរបស់លោករួមមាន *សេចក្ដីថ្លែងអំពីព្រះគុណនិង សេចក្ដីពិត គោលការណ៍ដ៏ជាកំណាប់ទ្រព្យ* (*The Grace and Truth Paradox*) និង *ចម្លើយគាំទ្រជីវិតចំពោះមតិគាំទ្រការជ្រើសរើស* (*ProLife Answers to ProChoice Arguments*)។ ប្រលោមលោករបស់លោក រ៉េនឌី រួមមាន *ថ្ងៃកំណត់* (*Deadline*) *ការគ្រប់គ្រង* (*Dominion*) *ការឃុបឃិតនៅអ៊ីសបិន* (*The Ishbane Conspiracy*) និង ជាអ្នកឈ្នះពានរង្វាន់មេដាយមាសសម្រាប់សៀវភៅដែលមានចំណងជើងថា *ទៅដល់ផ្ទះដោយសុវត្ថិភាព*។ លោកមានកូនស្រីពីរនាក់ ការីណា ហ្វ្រេងឃ្លីន (Karina Franklin) និង អ៊ែនជែឡា ស្តាំ (Angela Stump) ដែលអ្នកទាំងពីរបានរៀបការរួចហើយ។ លោក រ៉េនឌីរស់នៅក្នុងទីក្រុង ហ្គ្រេសហាំ រដ្ឋអរីហ្គិន ជាមួយភរិយារបស់លោក ឈ្មោះ ណែនស៊ីដែលជាមិត្តដ៏ល្អបំផុតរបស់លោកផងដែរ។ អ្នកនិពន្ធមានអង្គការមួយឈ្មោះថា ព័ន្ធកិច្ចទស្សនៈវិស័យអស់កល្ប ដែលអាចទំនាក់ទំនងបានតាមរយៈគេហទំព័រ www.epm.org, 503-668-5200, 39085 Pioneer Blvd., Suite 206, Sandy, OR 97055>

# កំណត់សំគាល់

## ជំពូកទី ១


1. "Gallup: Seventy-Two Percent of Teens Say Abortion Wrong," November 24,2003, WorldNetDaily.com.
2. "New National Abortion Poll Shows Majority of Americans Are Pro-Life," (December 2003 Zogby International Poll, posted January 16,2004,209.157.64.200/focus/fnews/1062123/posts).
3. January 23, 1994, "Young People Swell Crowd at Washington March for Life," 209.157.64.200/focus/freligion/1064531/posts.
4. See www.standupgirl.com.
5. "Abortion: Facts at a Glance" (New York: Planned Parenthoodof America), 1.
6. The Alan Guttmacher Institute website, www.agiusa.org/pubs/fb_induced_abortion.html; *Facts in Brief,* rev. February 2000.
7. Alan Guttmacher Institute, "Induced Abortion," *Facts in Brief,* February 2002.
8. James Patterson and Peter Kim, *The Day America Told the Truth* (New York: Prentice Hall Press, 1991), 32.
9. Lydia Saad, "Americans Divided Over Abortion Debate," 18 May 1999, Gallup News Service Poll Releases; www.gallup.com/content/login.aspx?ci=3847.
10. *Family Planning Perspectives,* July–August 1996, 12.
11. Randy Alcorn, *ProLife Answers to ProChoice Arguments* (Sisters, OR: Multnomah Publishers, 2000), 3 13–22; "Biblical Perspectives on Unborn Children," www.epm.org/articles/aborbibl.html.


## ជំពូកទី ២


1. "Gallup Finds Two-Thirds of Americans Believe Abortion Is Morally Wrong," June 2003, wwwiifesite.net/ldn/ 2003/jun/ 03060308.html.
2. Paul Swope, "Abortion: A Failure to Communicate," *First Things,* April 1998,31–35. See www.firstthings.com/ftissues/ ft9804/articles/swope.html.

## ជំពូកទី ៣


1. Subcommittee on Separation of Powers to Senate Judiciary Committee S-158, Report, 97th Cong., 1st Session, 1981.
2. Ibid.
3. Ibid.
4. *Lovejoy Surgi center v. Advocates for Life Ministries,* et al., 1989, testimony of Aileen Klass.
5. Alexander Tsiaras, *From Conception to Birth: A Life Unfolds* (New York: Doubleday, 2002).
6. *Missouri Revised Statutes,* chapter 1, "Laws in Force and Construction of Statutes," Section 1.205, August 28, 2003. See
7. www.moga.state.mo.us/statutes/C000-099/0010000205.htm.
8. R. Houwink, *Data: Mirrors of Science* (New York: American Elsevier Publishing Co., Inc., 1970), 104–190.
9. Lennart Nilsson, "Drama of Life Before Birth," *Life,* 30 April 1965.
10. "The Facts of Life" (Norcross, GA: Human Development Resource Council), 2.
11. Vincent J. Collins, "Fetal Pain and Abortion: The Medical Evidence," *Studies in Law and Medicine* (Chicago:
12. Americans United for Life, 1984), 6–7.
13. See *Newsweek,* June 9, 2003, "The War Over Fetal Rights," 40–47.
14. These are well-established scientific facts. See, for instance, Landrum Shettles and David Rorvik, *Rites of Life* (Grand
15. Rapids: Zondervan, 1983), 41–66.
16. Scott Klusendorf, *Pro-Life 101: A Step-by-Step Guide to Making Your Case Persuasively* (Signal Hill, CA:
17. Stand to Reason Press, 2002).
18. Justin Taylor, "Sticker Shock," *World,* January 17, 2004, 43.


## ជំពូកទី ៤


1. Leonide M. Tanner, ed., "Developing Professional Parameters: Nursing and Social Work Roles in the Care of the Induced Abortion Patient," *Clinical Obstetrics and Gynecology* 14 (December 1971): 1271.
2. Paul Marx, *The Death Peddlers: War on the Unborn* (Collegeville, MN: St.

John's University Press, 1971), 21.

3. *Feminists for Life Debate Handbook* (Kansas City, MO: Feminists for Life of America, n.d.), 3.
4. Carl Sagan and Ann Druyan, "Is It Possible to Be Pro-Life and Pro-Choice?" *Parade,* 22 April 1990,4.
5. *The First Nine Months* (Colorado Springs: Focus on the Family), 3.
6. *Preview of a Birth* (Norcross, GA: Human Development Resource Center, 1991), 4.
7. See Scott Klusendorf, "Harvesting the Unborn: The Ethics of Embryo Stem Cell Research," www.str.org/free/bioethics/ harvest. pdf.
8. "Deadline Extended for Comment to NIH on Stem Cells Harvesting," *Prolife Infonet,* 31 January 2000.
9. Thomas W. Hilgers, Dennis J. Horan and David Mall, eds., *New Perspectives on Human Abortion* (Frederick, MD: University Publications of America Inc./Aletheia Books, 1981), 351.
10. *Slate: Medical Examiner,* "Did I Violate the Partial-Birth Abortion Ban? A Doctor Ponders a New Era of Prosecution," by Dr. Warren M. Hern, October 22, 2003; http://slate.msn.com/id/2090215.

## ជំពូកទី ៥

1. Mortimer J. Adler, *Haves Without Have-Nots: Essays for the 21st Century on Democracy and Socialism* (New York: MacMillan, 1991), 210.
2. "Brain-Dead Woman Gives Birth," *The Oregonian,* 31 July 1987.
3. See www.michaelclancy.com/story.html.
4. Chuck Colson, "Life-and-Death Decisions: Praying for the Supremes," BreakPoint Commentary #000425, 25 April 2000.
5. HR 1997 was passed by a Senate roll call vote of 61-38, March 25, 2004.

## ជំពូកទី ៦

1. Madeline Nash, "Inside the Womb," *Time,* November 11, 2002, 68–77; Debra Rosenberg, "The War Over Fetal Rights," *Newsweek,* June 9, 2003,40–51.
2. Mark O'Keefe, "Activists Tout Ultrasound Images to Discourage Abortion," Newhouse News Service, www.newhouse.com/archive/ okeefe021903.html, © 2003.
3. Jennifer Kabbany, "Abortion vs. Ultrasound," *Washington Times,* October

29, 2003.

4. Audrey Stout, Marietta, GA, e-mail to Randy Alcorn, February 12, 2000.
5. See www.logiqlibrary.com/browseAction.cfm?productID=20; www.geddeskeepsake.com/showcase.html; www.clearviewultrasound.comgallery.asp;firstsightultrasound.com/4d_liveSA.htm; www.gemedicalsystems.com/ rad/us/4d/virtual.html; to find other images, enter the words *ultrasound, images,* and *unborn* into a search engine.
6. *Life,* August 1990.
7. Lennart Nilsson, *A Child Is Born* (New York: Delacorte Press, 1977).
8. See www.abortiontv.com/AbortionPictures1.htm.
9. Warren Hern, "Operative Procedures and Technique," *Abortion Practice* (Boulder, CO: Alpenglo Graphics, Inc., 1990), 154.
10. Naomi Wolf, "Our Bodies, Our Souls," *The New Republic,* October 16, 1995; www.epm.org/articles/naomiwolf.html.
11. *Care Net Report,* vol. 4, no. 5, November 2003, Sterling, VA.
12. Oregon Public Broadcasting, "To the Contrary," former Clinton administration staffer Maria Echaveste, et al., January 4, 2004.

## ជំពូកទី ៧

1. Mary Fischer, "A New Look at Life," *Reader's Digest,* October 2003, 95–103.
2. Peter Singer, *Practical Ethics* (1979), cited in "Peter Singer in His Own Words," Accuracy in Acadamia,www.academia.org/singerquotes.html.
3. Jim Newhall, cited by Maureen O'Hagan, "Cross Hairs to Bear," *Willamette Week,* 3 May 1995.
4. Associated Press, cited in Christian Action Council's *Action Line,* March–April 1991.
5. Sharon Begley, "Do You Hear What I Hear?" *Newsweek,* Special Summer Edition 1991, 12.
6. Ibid.
7. T. Verney and J. Kelley, *The Secret Life of the Unborn Child* (New York: Delta Books, 1981).
8. H. B. Valman and J. F. Pearson, "What the Fetus Feels." (This is a printed article with no reference to the publication it appeared in. Dr. Valman is consultant pediatrician at Northwick Park Hospital and Clinical Research Center in Harrow; Pearson is senior lecturer and consultant obstetrician

and gynecologist at Welsh National School of Medicine in Cardiff.)

9. John Wilke, *Abortion Questions and Answers* (Cincinnati, OH: Hayes Publishing Co., 1988), 53.
10. Begley, "Do You Hear?" 14.
11. Peter Singer, "Sanctity of Life or Quality of Life," *Pediatrics,* July 1983, 129.
12. Singer, "Taking Life: Humans," http://www.petersingerlinks.com/taking.htm; excerpted from Singer, *Practical Ethics* (New York: Cambridge University Press, 1993).
13. Charles Hartshorne, "Concerning Abortion: An Attempt at a Rational View," *The Christian Century,* 21 January 1981, 42–45.
14. David Boonin, *A Defense ofAbortion* (New York: Cambridge University Press, 2003), 5–9.
15. *Feminists for Life Debate Handbook* (Kansas City, MO: Feminists for Life of America, n.d.), 9.
16. Quoted by George Will, *The Pursuit of Happiness and Other Sobering Thoughts* (New York: Harper Colophon, 1978), 62–63.

## ជំពូកទី ៨

1. Kate Michelman, quoted in *The New York Times,* May 10, 1988.
2. *Feminists for Life Debate Handbook* (Kansas City, MO: Feminists for Life of America, n.d.), 17.
3. Rosemary Bottcher, "Feminism: Bewitched by Abortion," in *To Rescue the Future,* ed. Dave Andrusko (New York: Life Cycle Books, 1983).
4. See www.feministsforlife.org/news/commonw.htm.
5. Susan B. Anthony, *The Revolution,* July 8, 1869,4.
6. Mattie Brinkerhoff, *The Revolution,* April 9, 1868, 215–16.
7. Elasah Drogin, *Margaret Sanger: Father of Modern Society,* (CUL Publications, 1989), 11–13.
8. R. C. Sproul, *Abortion: A Rational Look at an Emotional Issue* (Colorado Springs, CO: NavPress, 1990), 117–18.
9. Guy M. Condon, "You Say Choice, I Say Murder," *Christianity Today,* June 24, 1991, 22.
10. Mary Ann Schaefer, quoted by Catherine and William Odell, *The First Human Right* (Toronto: Life Cycle Books, 1983), 39–40.
11. *The American Feminist,* Spring 2003, 14, 17.
12. "Abortion and Moral Beliefs: A Survey of American Opinion," conducted

by the Gallup Organization, 1991,4–7.
13. Willke, “Woman’s Movement,” 3.
14. Condon, “You Say Choice,” 23.
15. Robert Stone, “Women Endangered Species in India,” *The Oregonian,* March 14, 1989, B7.
16. Jo McGowan, “In India They Abort Females,” *Newsweek,* February 13, 1989.
17. *Straits Times* report, Beijing, February 7, 2000; related stories at www.lifesite.net.
18. *Medical World News,* December 1, 1975,45. See also *Newsweek,* “Brave New Babies,” February1, 2004.

## ជំពូកទី ៩

1. Mary O’Brien Drum, “Meeting in the Radical Middle,” *Sojourners,* November 1980, 23.
2. Nat Brandt, *The Town That Started the Civil War* (New York: Syracuse University Press, 1990); Thomas Clarkson, *Slavery and Commerce of the Human Species* (Miami, FL: Mnemosyne Publ. Co., 1969); Austin Willey, *The History of the Anti-Slavery Cause* (Portland, ME: Brown Thurston Publ., reprinted by Mnemosyne Publ. Co., Miami, FL, 1886).

## ជំពូកទី ១០

1. See Robert Jay Lifton, *The Nazi Doctors: Medical Killing and the Psychology of Genocide* (New York: Basic Books, 1986).
2. See www.teen-aid.org/Links.htm; www.abstinencedu.com; www.abednet.org; www.PureRevolution.com.

## ជំពូកទី ១១

1. Serrin M. Foster, “Women Deserve Better Than Abortion,” *Respect Life,* 2003.
2. Quoted by Mary Meehan, “The Ex-Abortionists: Why They Quit,” *Human Life Review* (Spring–Summer 2000), 12.
3. Elizabeth Shadigan, MD, testimony before the Senate subcommittee on science, technology, and space’s hearing to investigate the physical and

psychological effects of abortion on women; cited in "Witnesses Ask U.S. Senate for Research into Side Effects of Abortion on Women," *Culture & Cosmos,* vol. 1, no. 30, March 9, 2004.

4. Brent Rooney and Byron C. Calhoun, MD, "Induced Abortion and Risk of Later Premature Births," *Journal of American Physicians and Surgeons,* vol. 8, no. 2, Summer 2003.
5. S. Linn, "The Relationship Between Induced Abortion and Outcome of Subsequent Pregnancies," *American Journal of Obstetrics and Gynecology,* May 15, 1983, 136–40.
6. John A. Richardson and Geoffrey Dixon, "Effects of Legal Termination on Subsequent Pregnancy," *British Medical Journal* (1976): 1303–4.
7. B. Luke, *Every Pregnant Woman's Guide to Preventing Premature Birth* (New York: Times Books, 1995); E. Ring-Cassidy, *Woman's Health After Abortion* (Toronto: de Veber Institute, 2002).
8. *Family Planning Perspectives,* March–April 1983, 85–86.
9. U.S. Department of Health and Human Services, *Morbidity and Mortality Weekly Report* 42 (SS-6) 73–85 (December 17, 1993; April 1984).
10. Ann Aschengrau Levin, "Ectopic Pregnancy and Prior Induced Abortion," *American Journal of Public Health* (March 1982): 253.
11. "Ectopic Pregnancy: Prognosis for Subsequent Fertility," www.physicianeducation.org. Accessed March 1, 2004.
12. Centers for Disease Control, Press Release, May 1, 2001, "CDC Reports Highlights Selected Racial and Ethnic Pregnancy-Related Death Rates," http://www.cdc.gov/od/oc/media/pressrel/r010511.htm.
13. Allan Osser, MD, and Kenneth Persson, MD, "Postabortal Pelvic Infection Associated with Chlamydia Tracomatis and the Influence of Humoral Immunity," *American Journal of Obstetrics and Gynecology* (November 1984): 669–703.
14. Lars Heisterberg, MD, et al., "Sequelae of Induced First-Trimester Abortion," *American Journal of Obstetrics and Gynecology* (July 1986): 79.
15. Anath, CV, et al.: "The Association of Placenta Previa with History of Cesarean Delivery and Abortion: A Meta-Analysis," *American Journal of Obstetrics and Gynecology* (November 1997): 1071–78.
16. Jeffrey M. Barrett, MD, "Induced Abortion: A Risk Factor for Placental Previa," *American Journal of Obstetrics and Gynecology* (December 1981): 769.
17. David Reardon, *Aborted Women: Silent No More* (Westchester, IL: Crossway Books, 1987), 106.
18. F. Parazzini, et al., "Reproductive Factors and the Risk of Invasive and

Intraepithelial Cervical Neoplasia," *British Journal of Cancer,* 59:805–9 (1989); H. L. Stewart, et al., "Epidemiology of Cancers of the Uterine Cervix and Corpus, Breast and Ovary in Israel and New York City," *Journal of the National Cancer Institute* 37(i):1–96; I. Fujimoto et al., "Epidemiologic Study of Carcinoma in Situ of the Cervix," *Journal of Reproductive Medicine* 30(7):535 (July 1985); C. LaVecchia, et al., "Reproductive Factors and the Risk of Hepatocellular Carcinoma in Women," *International Journal of Cancer,* 52:351, 1992.

19. Dr. Joel Brind, "Comprehensive Review and Meta-Analysis of the Abortion/Breast Cancer Link"; http://members.aol.com/ DFjoseph/ brind.html.
20. Brinton LA, Hoover R, Fraumeni IF, Ir. (1983) *British Journal of Cancer,* 47:757–62.
21. Linn, "Outcome of Subsequent Pregnancies," 136–40.
22. John A. Richardson and Geoffrey Dixon, "Effects of Legal Termination on Subsequent Pregnancy," *British Medical Journal* (1976): 1303–4.
23. Herman, *Trauma and Recovery,* (New York: Basic Books, 1992), 34; "Abortion's Adverse Physical and Psychological Effects on Women" (list of studies).
24. For this and other studies see Elliot Institute, www.afterabortion.org.
25. David C. Reardon, "Major Psychological Sequelae of Abortion," 1997, Elliot Institute.
26. "Tearing Down the Wall," *LifeSupport,* Spring–Summer 1991,1–3.
27. See Alcorn, *ProLife Answers,* 118–20, 285–86.
28. Free information and counseling is available via www.lifeissues. org/men/.
29. Gissler M, Berg C, Bouvier-Colle MH, Buekens P., "Pregnancy-Associated Mortality After Birth, Spontaneous Abortion or Induced Abortion in Finland, 1987–2000," Am J Ob-Gyn 2004; 190:422–27.
30. Centers for Disease Control, *Morbidity and MortalityWeekly Report,* 52 (SS12); 1–32, "Abortion Surveillance—United States, 2000," 32.
31. James A. Miller, "A Tale of Two Abortions," *Human Life International Reports,* March 1991, 1.
32. John Wilke, *Abortion Questions and Answers* (Cincinnati, OH: Hayes Publishing Co., 1988), 99; Brian Clowes, *Facts of Life,* "Maternal Deaths Due to Abortion," Human Life International; 2nd ed. (June 2001).
33. Wanda Franz, "Abortion Associated with Heightened Mortality Rate, Study Reveals," www.nrlc.org/news/2002/ NRL09/ franz.html.
34. Elizabeth Ring-Cassidy and Ian Gentles, *Women's Health After Abortion: The Medical and Psychological Evidence,* 2nd ed. (de Veber Institute, 2003),

www.deveber.org.

35. "Key Facts About Abortion," Elliot Institute, n.d., www.afterabortion.org.

## ជំពូកទី ១២

1. Shettles and Rorvik, *Rites of Life* (Grand Rapids, MI: Zondervan, 1983), 129.

## ជំពូកទី ១៣

1. Jean Staker Garton, *Who Broke the Baby?* (Minneapolis, MN: Bethany House Publishers, 1979), 76.
2. "Who Has Abortions?" The Alan Guttmacher Institute, www.agi-usa.org/pubs/fb_induced_abortion.html.
3. "Abortion: Facts at a Glance," Planned Parenthood Federation of America, n.d., 1.
4. John Wilke, *Abortion Questions and Answers* (Cincinnati, OH: Hayes Publishing Co., 1988), 146–50.
5. Sue Reily, "Life Uneasy for Woman at Center of Abortion Ruling," *The Oregonian,* 9 May 1989, A2.
6. "Jane Roe Wants to Make Legal History Again," June 21 2003, www.theage.com.au/articles/2003/06/20/1055828492398.html
7. *Feminists for Life Debate Handbook* (Kansas City, MO: Feminists for Life of America, n.d.), 14.
8. Frederica Mathewes-Green, "Ask the Victims," *Citizen Magazine 2000,* family.org/cforum/citizenmag/features/ a0013078.cfm.

## ជំពូកទី ១៤

1. W. Peacock, "Active Voluntary Euthanasia," *Issues in Law and Medicine,* 1987. Cited by John Wilke, *Abortion Questions and Answers* (Cincinnati, OH: Hayes Publishing Co., 1988), 212.
2. National Vital Statistics Report, vol. 48, no. 3, March 28,2000.
3. March of Dimes Foundation, 2003, www.marchofdimes.com/professionals/681_1164.asp.
4. World Congress of Families Update, vol. 3, issue 1119, March 2002, www.worldcongress.org/WCFUpdate/Archive03/wcf_update_311.htm citing R. E. Gilbert, et al., "Screening for Down's Syndrome: Effects, Safety, and Cost-Effectiveness of First- and Second-Trimester Strategies";

and Euan M. Wallace and Sheila Mulvey, "Commentary: Results May Not Be Widely Applicable," BMJ 2001; 323:1–6 (25 August 2001); www.bmj.com.

5. Willke, *Abortion Questions,* 211.
6. "Born Unwanted: Developmental Consequences for Children of Unwanted Pregnancies," Planned Parenthood Federation of America, n.d.
7. The Michael Fund, 400 Penn Center, Pittsburgh, PA 15146.

## ជំពូកទី ១៦

1. Report of the National Center of Child Abuse and Neglect, U.S. Department of Health and Human Services, 1973–1982.
2. See www.acf.hhs.gov/programs/cb/publications/cm01/chapterthree.htm#victim.
3. Edward Lenoski, *Heartbeat* 3 (December 1980); cited by John Willke, *Abortion Questions and Answers* (Cincinnati, OH: Hayes Publishing Co., 1988), 140–41.
4. Nancy Michels, *Helping Women Recover from Abortion* (Minneapolis, MN: Bethany House Publishers,1988), 168.
5. Philip G. Ney, "A Consideration of Abortion Survivors," *Child Psychiatry and Human Development* (Spring 1983): 172–73.
6. Philip G. Ney, "Relationship Between Abortion and Child Abuse," *Canadian Journal of Psychiatry* (November 1979): 611–12.
7. Michels, *Helping Women Recover,* 169–70.
8. Cited by James Dobson, *Focus on the Family* radio broadcast, 21 June 1991.
9. Peter Singer, *Rethinking Life and Death* (New York: St. Martin's Griffin, 1996), 217.

## ជំពូកទី ១៧

1. Frederica Mathewes-Green, *Real Choices* (Sisters, OR: Multnomah Publishers, 1995), 19.
2. David Reardon, *Aborted Women: Silent No More* (Westchester, IL: Crossway Books, 1987), 10.
3. *1989 Adoption Factbook,* The National Council for Adoption (Washington, DC, June 1989), 158. These figures are relatively the same in 2000, per phone conversation on 5/8/00 with a representative of NCFA, confirming

at least one million couples of childbearing age constitute the minimum adoption demand for newborns in the U.S.

4. Cited by Charmaine Yoest, "Why Is Adoption So Difficult?" *Focus on the Family Citizen,* 17 December 1990, 10.
5. Testimonies of clinic workers in *The Abortion Providers,* a video produced by Pro-Life Action League, Chicago. Confirmed by former abortion clinic owner Carol Everett, in private telephone conversation between her, Frank Peretti, and the author on May 24, 1991.
6. Mathewes-Green, *Real Choices,* 14–15.
7. Yoest, "Why Is Adoption So Difficult?" 10.
8. See www.bethany.org; www.cwa.org/links.html; www.preciouskids.org/adopt/resources.html; www.adopting.com/info.html.
9. See http://encyclopedia.adoption.com. 10. Swopes, "Aborton: A Failure to Communicate," www.firstthings.com/ftissues/ ft9804/articles/swope.html.

## ជំពូកទី ១៩

1. *1. Family Planning Perspectives,* July–August 1996, 12.
2. 2. See wwwiifeservices.org/pace.htm; www.afterabortion.org/healing; call 1-888-486-HOPE for free confidential advice; resource list for postabortion needs: www.afterabortion.org/resourc.html.

## ជំពូកទី ២០

1. Care Net's option line is 1-800-395-HELP (4351); on-line help at www.optionline.org.
2. See www.catholic.net/RCC/Prolife/prolife1.html.
3. Eternal Perspective Ministries, www.epm.org, info@epm.org, (503) 668-5200, 39085 Pioneer Blvd., Suite 206, Sandy, OR 97055.
4. For information on the National Memorial for the Unborn, see www.atcmag.com/v1n4/article6.asp; church rose garden at www.epm.org/articles/rosegard.html.
5. My book *ProLife Answers to ProChoice Arguments* is a thorough response to pro-choice claims, backed up with eight hundred citations.
6. See Alcorn, *ProLife Answers,* Appendix K: ProLife Resources, 381–404; see www.epm.org/proliferesources.html. An extremely helpful information source is the Ultimate Pro-Life Resource List at www.prolife.org/ultimate. To subscribe to regular prolife information emails, send the message "subscribe" to infonet-list-request@lists.prolife.org.

7. Randy Alcorn, *Does the Birth Control Pill Cause Abortions?* (Sandy, OR: Eternal Perspective Ministries, 1997, 2000, 2004), www.epm.org/bcp.html; Drs. Walter Larimore and Joseph Stanford, "Postfertilization Effects of Oral Contraceptives and Their Relation to Informed Consent," *Archives of Family Medicine* 2000; 9:133; Dr. Walter L. Larimore, "The Growing Debate About the Abortifacient Effect of the Birth Control Pill and the Principle of Double Effect," *Ethics and Medicine Journal,* January 2000; 16 (1):23–30. Also available in updated format at www.epm.org/articles/pilldebate.html.
8. See www.family.org/pregnancy/general/A0028208.html.
9. Many pro-life resources are available on-line, including our organization's at www.epm.org/prolife.html. All articles I've written and everything at our website are freely available for church and ministry use, including a small-group Bible study lesson at www.epm.org/articles/aboleson.html, and a complete sample of a creative pro-life church service and message at www.epm.org/articles/abosergs.html.
10. *Life Is Sacred* and other pro-life resources, www.family.org/resources/itempg.cfm?itemid=1072.
11. See www.abortionno.org/pdf/order.pdf.